ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 29-Mar-2012, 15:15
CMS/CFO: Kauv Keoratanak

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៤៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វេង ហ៊ត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន
*(Mr. Michiel PESTMAN)*
លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន
លោក អាកទួរ វែកគែន
*(Mr Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម
លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*
លោក ពេជ អង្គ
លោក គីម ម៉េងឃី
កញ្ញា លី ម៉ាញៀន *(Ms.Lyma NGUYEN)*
លោកស្រី ម៉ុច សុវណ្ណារី
លោក ឡោ ជុនធី
លោក ហុង គីមសួន
លោក វ៉េន ពៅ
លោកស្រី ស៊ីន សុវ៉ន
លោក បាណាបេ ណេគ្វី
*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| កញ្ញា លី ម៉ាញៀន | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ូណូហ្វ | បារាំង |
| លោក កាំង ហ្គេកអ៊ាវ | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច**

សួរបន្តដោយលោក វីល្លៀម ស្មីត៖........................................................................ទំព័រ ០១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ នៅថ្ងៃនេះ អង្គសវនាការនឹងបន្តការស្តាប់នូវសក្ខីកម្មរបស់សាក្សីឈ្មោះ កាំង ហ្កេកអ៊ាវ ហៅឌុច ដែលនឹងតាំងសំណួរដេញដោយក្រុមសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វីណ្សៀម ស្មីត៖**

សូមគោរព លោកប្រធាន លោក លោកស្រីចៅក្រម មេធាវី ភាគី សាធារណជន និងសួស្តីលោកសាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វីណ្សៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ នៅពេលដែលយើងលើកឡើងចុងក្រោយកាលពីម្សិលមិញ យើងបានសួរថា តើក្រោយថ្ងៃ៣០ មីនា ឆ្នាំ១៩៧៦ ក្រោយពីថ្ងៃនោះ ការចាប់ខ្លួន និងការសម្លាប់មានការកើនឡើងនៅ ស-២១ដែរឬទេ បើសិនជាប្រៀបធៀបទៅលើរយៈកាលមុនថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។ យើងខ្ញុំដឹងថា លោកមកផ្តល់សក្ខីកម្មមួយសប្តាហ៍ហើយ។ ដូច្នេះយើងខ្ញុំសំណូមពរឲ្យលោកផ្តោតអារម្មណ៍ផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ។ វាមិនសូវមានច្បាស់លាស់មួយចំនួនតាមរយៈចម្លើយកាលពីម្សិលមិញ។ ដូច្នេះហើយ ខ្ញុំអាចសុំសួរលោកសំណួរមួយចំនួន ដើម្បីបញ្ជាក់បំភ្លឺ បន្ទាប់មកយើងនឹងចូលទៅដល់ប្រធានបទផ្សេង។ សំណួរដំបូងរបស់ខ្ញុំនោះ គឺថាតើថ្ងៃណាដែលស-២១ នោះចាប់ផ្តើមទទួលអ្នកទោស? កាលបរិច្ឆេទចាប់ផ្តើមហ្នឹងនៅថ្ងៃណាដែរ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ស-២១ នេះខ្ញុំជឿថាវាចាប់ផ្តើមតាំងពីថ្ងៃ១៧ មេសា ក្រោយនោះមួយថ្ងៃពីរប៉ុណ្ណឹងឯង។ វាជានគរបាលកងពល៧០៣ នេះដំបូង។ ហើយបានដល់ក្រោយមក វាទៅពង្រីកខ្លួនទៅ

ជាស-២១។ អង្កាល់នៅជានគរបាល ន៉ែ!របស់កងពល៧០៣ គេហៅថាស្ទី ៤២, ៤៣ៗ ៤៤អីគេនុ៎ង! នេះជាបញ្ហាមួយដែលលោកសួរខ្ញុំចំពោះមុខ។ ហើយម្សិលមិញ យើងនិយាយគ្នាបែបយើងច្រឡំពាក្យខ្លះ។ ស្តាប់គ្នាមិនបាន។

[០៩:០៥:១៥]

**ស៖** សូមអរគុណ។ ខ្ញុំដឹងថាលោកនឹងបញ្ជាក់បំភ្លឺជូនយើងខ្ញុំនៅថ្ងៃនេះ។ តើនៅថ្ងៃណាដែរដែលស-២១នោះបិទទ្វារឈប់ដំណើរការ?

**ឆ៖** ស-២១ បើនិយាយពីបិទទ្វារពិបាកនិយាយណាស់។ បើនិយាយអំពីបញ្ហារបស់ បងនួនមកឲ្យកម្ទេចមនុស្សឲ្យអស់ គឺប្រហែលជានៅថ្ងៃ៣ ខែមករា ១៩៧៩។ ដល់ម៉ោងដប់មួយ រថក្រោះវៀតណាម មកដល់មុខផ្ទះខ្ញុំ។ ម៉ោងបីយើងខ្ញុំចេញពីស-២១ ទៅសាលាសន្សំកុសល រត់ចេញតែម្តងអត់មានបិទទ្វារទេ រត់ចេញតែម្តង។ គេមកដល់ហើយ មេរត់ចោលបាត់។

**ស៖** សូមអរគុណ។ លោកបានឯកភាពជាមួយនឹងសក្ខីកម្មខាងដើម គឺថាបញ្ជីមួយបានបង្កើតឡើងដោយសហព្រះរាជអាជ្ញានៅក្នុងរឿងក្តីមុន ដែលក្នុងនោះបានបង្ហាញចំនួនអ្នកទោសជាង១២.០០០នាក់ ដែលបានឃុំខ្លួននិងសម្លាប់ចោលនៅស-២១។ ហើយបញ្ជីដែលបានបង្កើតឡើងកាលលើកមុននោះជាបញ្ជីមួយត្រឹមត្រូវ តើលោកឯកភាពដែរឬទេ?

**ឆ៖** ខ្ញុំឯកភាព។

[០៩:០៦:០៥]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ លោក លោកស្រីចៅក្រម បើសិនអនុញ្ញាតឲ្យខ្ញុំបញ្ជូនឯកសារមួយជូនទៅកាន់សាក្សី គឺឯកសារ D288/6.68.1។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយ លោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ប្រសិនបើលោកមើលឯកសារនុ៎ង ហើយជម្រាបអង្គជំនុំជម្រះថាតើឯកសារនេះជាឯកសារអ្វីដែរ ហើយលោកស្គាល់ដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ឯកសារនេះជាបញ្ជីអ្នកទោសស-២១ ដែលការិយាល័យសហព្រះរាជអាជ្ញាសរុប និងកែសម្រួលចុងក្រោយ។ ខ្ញុំធ្លាប់ប្រើប្រាស់បញ្ជីនេះ ក្នុងសវនាការសំណុំរឿងលេខ០០១ រួចអស់ហើយ តែខ្ញុំមិនបានរក្សាទុកបញ្ជីនេះនៅផ្ទះ-- នៅកន្លែងបន្ទប់ខ្ញុំទេ។

[០៩:០៨:០២]

**ស៖** តើលោកធ្លាប់បានពិនិត្យមើលឯកសារហ្នឹងឡើងវិញដែរឬទេ កាលពីលើកមុននោះ?

**ឆ៖** ក្នុងសំណុំរឿងលេខ០០១ ខ្ញុំមើលហូរហែ។ ខ្ញុំមើលវាហូរហែ ដល់ក្រោយមក វាចង្អៀតកន្លែងពេក ខ្ញុំយកមកទុកនៅការិយាល័យរបស់មេធាវី។

**ស៖** សូមអរគុណ។ តើលោកឯកភាពដែរឬទេ ដែលថាសំណុំឯកសារនេះគឺមាន អាយុ ភេទ ឈ្មោះ តួនាទី ថ្ងៃចូលស-២១ ចាប់មកពីណា កាលបរិច្ឆេទសម្លាប់ចោលនៅស-២១ និងមាន*កូឡោន*មួយទៀតដែលដាក់ថា កំណត់សម្គាល់។ តើលោកឯកភាពទេនៅលើឯកសារហ្នឹងមានចំណុចទាំងអស់ហ្នឹង?

**ឆ៖** អរគុណ ខ្ញុំឯកភាព។

**ស៖** បញ្ជីនេះមានឈ្មោះអ្នកទោសជាង១២.០០០នាក់ ដែលត្រូវបានសម្លាប់ចោលនៅស-២១។ តើអាចជម្រាបអង្គជំនុំជម្រះដែរឬទេ អ្នកទោសស្ទើរតែទាំងអស់នេះ គឺត្រូវបានគេសម្លាប់ចោលនៅមុនថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦ ឬក៏ត្រូវបានគេសម្លាប់ចោលក្រោយថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦?

[០៩:០៩:៥៩]

**ឆ៖** អ្នកទោសនៅក្នុងបញ្ជីនេះ ចាប់តាំងពីថ្ងៃ១៧ មេសា មក អាចចាប់តាំងពីថ្ងៃ១៧ មេសា តាំងពីកងពល៧០៣ នៅជានគរបាលកងពល៧០៣។

**ស៖** គ្រាន់តែប្រហែលទៅ ថាតើមានអ្នកទោសប៉ុន្មាននាក់ដែរ ដែលត្រូវបាននាំចូលមក ស-២១ មកត្រឹមថ្ងៃ៣០ មីនា ឆ្នាំ៧៦? ដូច្នេះលោកអាចផ្តល់តួលេខប្រហាក់ប្រហែលមក តើមុនឆ្នាំ៧៦ ថ្ងៃទី៣០ ខែមីនា ៧៦ តើមានចំនួនអ្នកទោសប៉ុន្មានដែរ ដែលចូលមកស-២១ ចំនួនប្រហាក់ប្រហែល?

**ឆ៖** ចំនួនប្រហាក់ប្រហែល បើនិយាយអំពីអ្នកនេសាទថៃ វា៣០០ ឬក៏ ៦០០ ទេ ខ្ញុំមិនដឹងទេ ភ្លេចហើយ។ ដូច្នេះ មិនលើសពី១.០០០ ទេ, ពី ៦០០ ទៅ ១.០០០។

**ស៖** ដូច្នេះ អ្នកទោសដែលនៅសល់ដកចំនួនអម្បាញ់មិញហ្នឹង គឺត្រូវបានចាប់ខ្លួនចូលមកស-២១ ក្រោយថ្ងៃ៣០ មីនា ឆ្នាំ៧៦ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

[០៩:១១:៤៥]

**ស៖** សូមអរគុណ។ យើងអាចទុកបញ្ជីនេះឈប់ពិនិត្យមើល ហើយនៅពេលនេះខ្ញុំសូមចូលទៅដល់ឯកសារមួយ ដែលយើងបានមើលកាលពីម្សិលមិញ ឯកសារលេខ E3/12 សេចក្តីសម្រេចរបស់បក្សពាក់ព័ន្ធទៅនឹងបញ្ហាមួយចំនួន ដែលក្នុងនេះចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៦។ ចំណុចទីមួយនៅលើឯកសារនេះ មុនពេលដែលខ្ញុំសួរបន្ត តើលោកសាក្សីមានឯកសារហ្នឹងមួយច្បាប់នៅចំពោះមុខដែរឬទេ?

**ឆ៖** ខ្ញុំមាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

លោកប្រធាន ប្រសិនបើអនុញ្ញាត ខ្ញុំសូមឱ្យខាងមន្ត្រីតុលាការដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់។

**ស៖** ចំណុចទីមួយគឺនិយាយថា សិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ។ ដូច្នេះសូមឱ្យលោកអានកថាខណ្ឌទីមួយ នៅក្នុងនេះ បន្ទាប់មកខ្ញុំនឹងសួរឱ្យលោកពន្យល់ តើក្នុងនេះគេមានន័យយ៉ាងម៉េច?

**ឆ៖** "មួយ សិទ្ធិសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ។ សំណូមពរ៖ ១) ឱ្យមានក្របខ័ណ្ឌក្នុងកិច្ចអនុវត្តផ្តាច់ការបដិវត្តន៍របស់យើង។ ២) ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង"។

[០៩:១៣:៤៣]

ទាំងអស់នេះ ដើម្បីពង្រឹងរដ្ឋអំណាចរបស់យើង។ បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច។ ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច។ កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច។ សូមចប់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

**លោក អាកទ្បរ វែកគែន៖**

សូមអរគុណលោកប្រធាន។ អ្វីដែលកំពុងតែប្រព្រឹត្តទៅនេះ គឺថាមានភាពធ្ងន់ធ្ងរណាស់។ ដូច្នេះខាងមេធាវីការពារក្តី ខៀវ សំផន ថាមិនអាច ថាមិនធ្វើប្រតិកម្មបានទេ។ សូមបញ្ជាក់ថា សូមជំទាស់ទៅនឹងដំណើរការដែលកំពុងតែប្រព្រឹត្តទៅនេះ។ តុលាការនេះ បណ្តោយឱ្យសហព្រះរាជអាជ្ញាបង្ហាញនូវសាក្សីមួយ-- ជូនទៅដល់សាក្សីមួយនូវឯកសារ ដែលខ្លួនបានទទួលស្គាល់ថា ខ្លួនមិនស្គាល់ឯកសារ

នេះទេ នៅពេលសម័យកើតអង្គហេតុនោះ។ ហើយឯកសារនោះ ក៏មិនដែលបានបង្ហាញច្បាប់ដើមដែរ ហើយក៏មិនដែលបានបង្ហាញជូនសហចៅក្រមស៊ើបអង្កេត និងអ្នកស៊ើបអង្កេត ឬក៏បង្ហាញជូនតុលាការនេះ ហើយអ្នកទាំងអស់នៅទីនេះ ក៏មិនបានស្គាល់ឯកសារនេះដែរ។ ដូច្នេះ យថាភាពនៃឯកសារនេះ អាចត្រូវតែបានផ្ដល់ឲ្យដោយខាងអង្គការខាងក្រៅ ដែលបម្រើការឲ្យតុលាការនេះ។ ហើយអង្គជំនុំជម្រះអនុញ្ញាតឲ្យតុលាការ-- ឲ្យសហព្រះរាជអាជ្ញាសួរសំណួរសាក្សីដោយប្រើឯកសារនេះ ដោយធ្វើហាក់ដូចជាឯកសារនេះ គឺជាឯកសារច្បាប់ដើមអ៊ីចឹង។

[០៩:១៥:៥០]

ដូច្នេះ វាជាបញ្ហាធ្ងន់ធ្ងរណាស់ចំពោះខ្ញុំ។ ដូច្នេះយើងមិនអាចធ្វើបានដូច្នេះទេ។ ដូច្នេះហើយខាងមេធាវីការពារក្ដីសូមជំទាស់នៅក្នុងការធ្វើរបៀបនេះ។ ដើម្បីឲ្យកាន់តែច្បាស់ជាងនេះទៅទៀតនោះ ខ្ញុំមិនជំទាស់ក្នុងការដែលសហព្រះរាជអាជ្ញា ព្យាយាមចង់ទទួលបាននូវព័ត៌មានមួយចំនួនពីឯកសារទាំងអស់នេះនោះទេ គឺគាត់ព្យាយាមពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាន ដែលមាននៅក្នុងឯកសារនោះ ដែលគាត់និយាយថាកើតនៅសម័យនោះ។ ហើយព័ត៌មានដែលលោកសហព្រះរាជអាជ្ញានឹងទទួលបាននោះ គឺអាចនឹងប្រើនៅពេលក្រោយ ដើម្បីព្យាយាមក្នុងការផ្ដល់សុពលកម្មទៅលើយថាភាពនៃឯកសារនេះ។ ដូច្នេះនេះគឺជារឿងធម្មតាទេ ក៏ប៉ុន្តែនៅថ្ងៃនេះ-- គឺបានន័យថា អ្វីដែលធ្វើនេះ គឺមានន័យថា ឯកសារហ្នឹងមានភាពច្បាប់ដើម-- មានយថាភាពទៅហើយ។ ដូច្នេះ យើងមិនអាចអះអាងថា យើងបានមើលច្បាប់ដើមនៃឯកសារនោះទេ។ នេះជាការលំបាកនៅទីនេះ។ ក៏ប៉ុន្តែទោះជាមានការចេញសេចក្ដីសម្រេចកាលពីម្សិលមិញហើយក៏ដោយ។

[០៩:១៧:២៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីជាតិការពារក្ដីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមទៅលើសហភាតារបស់ខ្ញុំ។ ចំពោះការជំទាស់នេះគឺថា តំណាងសហព្រះរាជអាជ្ញាបានលើកនូវសំណួរមួយ ដែលឲ្យសាក្សីអានអត្ថបទនេះ ហើយឲ្យសាក្សីពន្យល់ តើលោកយល់យ៉ាងម៉េចចំពោះខ្លឹមសារនៅក្នុង អាចំណុចដែលសហព្រះរាជអាជ្ញាបានគូសបញ្ជាក់នេះ។ ដូច្នេះការធ្វើអត្ថាធិប្បាយរបស់សាក្សី វាបង្ហាញយ៉ាងច្បាស់អំពីការយល់ជាលក្ខណ:ផ្ទាល់ខ្លួន

ពីព្រោះការធ្វើអត្ថាធិប្បាយនេះ មិនមែនសំដៅទៅលើអង្គហេតុទេ គឺសំដៅទៅលើទស្សនៈជាលក្ខណៈបុគ្គល។ ដូច្នេះ ការធ្វើបែបនេះមិនអាចធ្វើបានទេ។ សូមជំទាស់។ សូមអរគុណ។

[០៩:១៨:២៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែក្រោកឈរ ដើម្បីគាំទ្រមេធាវី ខៀវ សំផន។ ខ្ញុំសូមបញ្ជាក់អ្វីដែលយើងព្រួយបារម្ភតែប៉ុណ្ណោះ។ បញ្ហាយថាភាពនៃឯកសារនេះ មិនទាន់បានបញ្ជាក់ឲ្យបានត្រឹមត្រូវចំពោះអង្គហេតុ ដែលបានដាក់ជូនអង្គជំនុំជម្រះនៅឡើយនោះទេ។ ដូច្នេះហើយយើងមិនទាន់ដឹងអំពីយថាភាពនៃឯកសារនេះនៅឡើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន លោកលោកស្រីចៅក្រមជាទីគោរព!

ប្រហែលជាសេចក្តីសម្រេចចុងក្រោយមួយ ដែលអង្គជំនុំជម្រះបានធ្វើឡើងគឺអនុញ្ញាតឲ្យសាក្សីរូបនេះយោងទៅលើឯកសារនេះ។ ខ្ញុំនឹងធ្វើពាក្យសុំនៅព្រឹកនេះតែម្តង យើងខ្ញុំស្នើសុំមួយម៉ោងកន្លះបន្ថែមដើម្បីដេញដោលទៅលើសាក្សីរូបនេះ ដោយសារតែម្សិលមិញ គឺមានការជំទាស់ច្រើនណាស់ដែលបានលើកឡើង ហើយការជំទាស់ទាំងអស់នោះ គ្មានប្រសិទ្ធភាព។ ដូច្នេះហើយការសុំម៉ោងបន្ថែមនេះអនុញ្ញាតឲ្យខាងសហព្រះរាជអាជ្ញា គឺបន្តដេញដោលលើសាក្សីរូបនេះ។ ការជំទាស់ម្សិលមិញនោះនៅថ្ងៃនេះ គឺលើកឡើងម្តងទៀតហើយ។ យើងខ្ញុំសូមឲ្យច្រានចោលការជំទាស់នេះ។ កាលពីម្សិលមិញអង្គជំនុំជម្រះបានធ្វើសេចក្តីសម្រេច ហើយប្រសិនបើអង្គជំនុំជម្រះធ្វើសេចក្តីសម្រេច ភាគីសហព្រះរាជអាជ្ញា ឬក៏ភាគីណាមួយនោះ ឡើងក្រោកឈរ ឡើងជំទាស់ម្តងទៀតនោះ អង្គជំនុំជម្រះតុលាការរបស់យើងមិនអាចបន្តនីតិវិធីទៅមុខនោះទេ។ ដូច្នេះ ហើយខ្ញុំសូមឲ្យច្រានចោលការជំទាស់នេះ ដោយសារតែកាលពីម្សិលមិញ មានការធ្វើសេចក្តីសម្រេច ហើយពិភាក្សាលើបញ្ហានេះ កាលពីម្សិលមិញរួចមកហើយ ហើយឲ្យខ្ញុំបន្តសួរសាក្សីរូបនេះ។ មេធាវីការពារក្តី ខៀវ សំផន ប្រហែលជាភ្លេច ប្រហែល

មិនបានមើលសំណុំរឿង។ ឯកសារមួយនេះ បានដាក់នៅចំពោះមុខសាក្សី នៅក្នុងពេលដំណាក់កាលស៊ើបសួរ។ ឯកសារនេះ បានពិភាក្សាយ៉ាងលម្អិតទៅលើខ្លឹមសារនៃឯកសារនេះ។ អ្វីដែលមេធាវី ខៀវ សំផន លើកឡើងនោះ គឺថានេះជាលើកទីមួយ ដែលឯកសារនេះ លេចចេញមក ហើយមិនដែលបានដាក់នៅចំពោះមុខចៅក្រមស៊ើបអង្កេត។ ករណីហ្នឹង គឺមិនពិតទេ។

[០៩:២១:១៦]

ចំណុចទីពីរ ពាក់ព័ន្ធទៅនឹងបញ្ហាលើឯកសារនេះ សហព្រះរាជអាជ្ញាបានដឹងយ៉ាងពេញលេញអំពីការទទួលខុសត្រូវ ដែលឲ្យសាក្សីផ្តល់ចម្លើយនៅក្នុងតុលាការ។ មិនមែនថា គ្រាន់តែយោងឯកសារនោះ វាមិនអាចធ្វើទៅបាននោះទេ។ សាក្សី ត្រូវបានយើងស្នើសុំឲ្យពន្យល់ ថាតើពាក្យនៅក្នុងឯកសារនោះ មានន័យយ៉ាងម៉េច? ដោយសារតែយើងដឹងហើយថា សាក្សីធ្វើការងារនៅក្នុងរបបនោះ ដោយគាត់ដឹងអំពីពាក្យពេចន៍ឃ្លោងឃ្លាដែលប្រើប្រាស់។

[០៩:២១:៥៤]

ការដែលយើងសួរ គឺដើម្បីឲ្យពន្យល់ទិដ្ឋភាពមួយចំនួនតែប៉ុណ្ណោះ។ យើងឯកភាពជាមួយនឹងមេធាវី ខៀវ សំផន ដែលថាសវនាការនេះវាគ្របដណ្តប់ទៅលើទិដ្ឋភាពផ្សេងៗគ្នា។ ដូច្នេះ វាសំខាន់ណាស់ ហើយយើងត្រូវគិតអំពីទម្ងន់ទៅលើឯកសារ។ ក៏ប៉ុន្តែអ្វីដែលខ្ញុំសូមជំទាស់ទៅលើការលើកឡើងរបស់មេធាវីការពារក្តី គឺសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានធ្វើឡើងកាលពីម្សិលមិញនោះហើយ។ ដូច្នេះយើងមិនអាចមកក្រោកឈរនៅទីនេះ ហើយតវ៉ាឲ្យអង្គជំនុំជម្រះសម្រេចច្រានចោលសេចក្តីសម្រេចរបស់ខ្លួនកាលពីម្សិលមិញនោះទេ។

**កញ្ញា លី ម៉ាញឿន៖**

សូមគោរពលោក លោកស្រីចៅក្រម ភាគី។ ខ្ញុំគ្រាន់តែគាំទ្រនូវអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង។ វាច្បាស់លាស់ហើយ កាលពីម្សិលមិញ ចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់អំពីសេចក្តីសម្រេចទៅលើឯកសារនេះ ថាសេចក្តីសម្រេចនេះ មិនមែន-- គឺផ្តោតទៅលើការដឹងអំពីឯកសារនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះទេ។ ចៅក្រម ខាតវ៉ាយថ៍ បានបញ្ជាក់យ៉ាងច្បាស់ថា សាក្សីត្រូវអាចសួរ ថាតើធ្លាប់ឃើញឯកសារនេះពីមុនដែរឬទេ? ហើយថាភាពមិនអាច មិនចាំបាច់បញ្ជាក់តាមរយៈសាក្សីរូបនេះទេ ដោយសារតែឯកសារនេះ បានដាក់នៅមុខចំពោះអង្គជំនុំជម្រះកាលពីលើកមុននោះរួចមកហើយ។ ដូច្នេះ បញ្ហានៃការជំទាស់នេះ មិនអាចលើកឡើងសាជាថ្មីនោះឡើយ។ សូម

អរគុណ។

[០៩:២៣:២៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីជាតិតំណាង-- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ បញ្ហាដដែលៗនេះ ត្រូវបានលើកដោយខាង *ឌីហ្វែន* ខាងការពារក្តី នៅពេលដែលលោក លោកស្រីចៅក្រម បានសម្រេចពីបញ្ហាដដែលនេះរួចមកហើយ។ យើងខ្ញុំគ្រាន់តែលើកជាបន្ថែមទៀតថា ឯកសារដែលបានបញ្ជូនតាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបអង្កេត ត្រូវបានសន្មតថាឯកសារទាំងអស់នោះអាចទទួលបាន។ ក៏ប៉ុន្តែប្រសិនបើភាគីខាងការពារក្តីជំទាស់ ភាគីការពារក្តីមានសិទ្ធិជំទាស់ដោយរកហេតុផលប្រាកដប្រជាជាក់ច្បាស់ ដើម្បីជំទាស់។ ហើយស្ថានភាពនៃឯកសារដែលត្រូវបានជំទាស់នោះ សួរថាតើត្រូវមានលក្ខន្តិកៈ-- លក្ខណៈរបស់វាយ៉ាងដូចម្តេច? ថាតើយើងមិនមានសិទ្ធិនៅក្នុងការយកឯកសារនោះ មកពិភាក្សា ដោយសារតែមូលហេតុនៃការជំទាស់នោះទេ។

[០៩:២៤:២៩]

កន្លែងនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីយល់ថា ឯកសារទាំងអស់នោះ គួរតែទុករក្សាស្ថានភាពដដែល ដែលចាត់ទុកថាជាឯកសារដែលត្រូវមានលទ្ធភាពនៅក្នុងការយកមកពិនិត្យពិចារណា ហើយចាត់ទុកថាជាឯកសារ ដែលអាចទទួលបានរហូតទៅដល់ពេលដែលមានចៅក្រមបានសម្រេចផ្សេងពីនេះ ថាឯកសារទាំងអស់នោះ ជាឯកសារដែលមិនអាចទទួលយកបាន។ ដូច្នេះ ឯកសារ ៣០ ខែមីនា ឆ្នាំ៧៦ នេះ មិនទាន់មានការសម្រេចជាក់ច្បាស់ពីលោក លោកស្រីចៅក្រមនៅឡើយ ថាជាឯកសារដែលត្រូវទាត់ចោល ហើយមិនអាចយកមកពិចារណាបាន។

ដូច្នេះ គួរតែជាឯកសារដែលអាចយកមកពិចារណានៅចំពោះមុខលោក លោកស្រីចៅក្រមបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់នូវសេចក្តីជំទាស់របស់ក្រុមមេធាវីពីរក្រុម ហើយនិងបានស្តាប់នូវសេចក្តីតបរបស់ក្រុមសហព្រះរាជអាជ្ញា ហើយនិងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ

សម្រេចថាសេចក្ដីជំទាស់របស់ក្រុមមេធាវីការពារក្ដីមិនមានប្រសិទ្ធភាព។

ដូច្នេះតំណាងសហព្រះរាជអាជ្ញាអាចតាំង-- បន្តការសួរដេញដោលចំពោះសាក្សីនៅលើឯកសារដែលអង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញ។ ប៉ុន្តែទន្ទឹមនឹងនេះអង្គជំនុំជម្រះក៏សូមរំឭកផងដែរថា ការសួរគប្បីប្រើងប្រែងបញ្ចៀសនូវការតាំងសំណួរឯណានាំឲ្យសាក្សីផ្ដល់នូវចម្លើយដែលជាលក្ខណៈបង្ហាញនូវទស្សនៈយល់ដឹងផ្ទាល់ខ្លួន។ បញ្ហាទីពីរគឺអំមិញនេះអាចមានការភ័ន្តច្រឡំដែរ ដោយសារសំណួរសួរទៅអាចគោលដៅផ្សេង ហើយឆ្លើយគឺឆ្លើយយកបញ្ហាផ្សេងទៀតមកឆ្លើយ ដោយមិនឆ្លើយតបទៅនឹងសំណួរដែលបានសួរឡើយ។ ដូច្នេះមានការប្រុងប្រយ័ត្នទាំងអស់គ្នា ទាំងការសួរ ទាំងការឆ្លើយ។ លោកសាក្សី ដើម្បីឲ្យស្ដាប់ឲ្យបាននូវខ្លឹមសារនៃចម្លើយ អំនៃសំណួរ នាំឲ្យឆ្លើយតបហ្នឹងឲ្យចំបញ្ហាតែម្ដង។ យើងចៀសវាងការរឿងច្រំដែល ហើយចៀសវាងការអូសបន្លាយពេលវេលានៅក្នុងកិច្ចដំណើរការសវនាការ។

[០៩:២៦:៥៨]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ដើម្បីឲ្យច្បាស់លោកសាក្សី ឯកសារនេះលោកមិនបានឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ តើពិតជាដូច្នោះដែរឬទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** គឺពិត!

**ស៖** ហើយលោកទើបតែបានពិនិត្យអាននៅក្នុងដំណាក់កាលស៊ើបអង្កេត របស់ចៅក្រមស៊ើបអង្កេតនេះតែប៉ុណ្ណោះ។ តើមែនដែរឬទេ?

**ឆ៖** មែន!

**ស៖** ប្រសិនបើយើងមើលទៅលើសំណួមពរ ដែលយើងទើប-- ដែលលោកទើបតែអានអម្បាញ់មិញ គឺថាពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង។ តើលោកអាចពន្យល់ទេតាមអ្វីដែលដឹង? ក្របខ័ណ្ឌគោលការណ៍នៅសម័យនោះ គឺយ៉ាងម៉េចដែរ? ក្របខ័ណ្ឌនៅសម័យនោះយ៉ាងម៉េចដែរ ដើម្បីឲ្យយើងយល់ទាំងអស់គ្នា។

[០៩:២៨:២១]

**ផ៖** មួយឲ្យមានក្របខ័ណ្ឌ គឺឲ្យមានអ្នកណាដែលមានសមត្ថកិច្ច។ ក្របខ័ណ្ឌហ្នឹង កំណត់ថាអ្នកណាដែលមានសមត្ថកិច្ចក្នុងការអនុវត្តសិទ្ធិសម្រេចកម្មេចនេះ។

**ស៖** លោកបានលើកឡើងខាងដើមអំពីរចនាសម្ព័ន្ធនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើគណៈអចិន្ត្រៃយ៍ នោះមានទីតាំងមូលដ្ឋាននៅឯណាដែរ? ហើយពឹងផ្អែកទៅលើក្របខ័ណ្ឌអ្វីដែរ?

**ផ៖** អចិន្ត្រៃយ៍បោះទីតាំងនៅភ្នំពេញ។ នេះគិតតាំងពីថ្ងៃ១៧ មេសា រហូតដល់៧ មករា ១៩៧៩។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា គឺរចនាសម្ព័ន្ធគណៈកម្មាធិការ។ យើងដឹងហើយថានៅក្នុងប្រទេសនេះ គេបែងចែកចេញទៅជាភូមិភាគ តើមែនដែរឬទេ?

**ផ៖** ត្រឹមត្រូវហើយ ក្នុងប្រទេសនេះគេបែងចែកជាភូមិភាគ។

**ស៖** តើមានភូមិភាគប្រហែលជាប៉ុន្មានដែរ ដែលប្រទេសនេះបានបែងចែកនៅក្នុងសម័យកាលនោះ?

**ផ៖** ខ្ញុំសូមរាប់ឈ្មោះទៅ ពីសាន បូព៌ា និរតី បស្ចិម ភូមិភាគកណ្តាល ភូមិភាគពាយ័ព្យ។ ហើយក្រោយមកប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៧ បង្កើតភូមិភាគមួយទៀតឈ្មោះភូមិភាគឧត្តរថ្មី ឬភូមិភាគ៨០១។

[០៩:៣១:០៤]

**ស៖** តើគោលបំណងនៃការបែងចែកប្រទេសឲ្យទៅជាភូមិភាគនោះ តើមានមូលហេតុអ្វីសម្រាប់គាំទ្រទេ?

**ផ៖** បើតាមវគ្គឧទ្ទេសនាមភូមិភាគនេះ ជារូបភាពចាត់តាំងបណ្តោះអាសន្ន។ កាលណាបក្សមានកម្លាភិបាលគ្រប់គ្រាន់ភូមិភាគនេះ គេលុប។

**ស៖** តាមអ្វីដែលលោកដឹងនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ថាតើភូមិភាគទាំងអស់នោះត្រូវបានលុបដែរឬទេ?

**ផ៖** នេះគ្រាន់ជាទ្រឹស្តីដែលបង្រៀន ហើយគ្រាន់តែប្រាប់ថាភូមិភាគជារូបភាពចាត់តាំងបណ្តោះអាសន្ន តែមិនទាន់ភូមិភាគណាមួយត្រូវលុបទេ។ ៧៧ បង្កើតថែមភូមិភាគមួយទៀត គឺភូមិភាគឧត្តរថ្មី ឬហៅថា ៨០១។

**ស៖** ហើយ បាទ សូមអរគុណ។ បែបនេះយើងយល់បានពីរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា តើអ្នកណាជាអ្នកគ្រប់គ្រងភូមិភាគ? អ្នកណាជាអ្នកចាត់ចែង តើក្រុមមនុស្សប្រភេទណា?

[០៩:៣៣:០៨]

**ឆ៖** អ្នកដែលគ្រប់គ្រងភូមិភាគមានពីរនាក់ជាសមាជិកអចិន្ត្រៃយ៍ គឺ សោ ភឹម និង អ៊ុង ជឿន ហៅម៉ុក ក្រៅពីនោះ គឺសុទ្ធតែជាសមាជិកមជ្ឈិមពេញសិទ្ធិ។ ដោយឡែកភូមិភាគពិ្លសាន ក្រោយពីចាប់យ៉ា មកមិនដឹងទេ។ ខ្ញុំក្តាប់មិនបានទេ អ្នកណាក្តាប់ទេ ច្បាស់លាស់ទេ។

**ស៖** ដូច្នេះនៅក្នុងភូមិភាគនីមួយៗជាពិសេសនិយាយពីតំបន់ភូមិសាស្ត្រភូមិនោះ តើមានគណៈអចិន្ត្រៃយ៍របស់ភូមិភាគនោះដែរឬទេ សម្រាប់ភូមិភាគនីមួយៗ?

[០៩:៣៤:១១]

**ឆ៖** សម្រាប់ភូមិភាគនីមួយៗវាមានគណៈអចិន្ត្រៃយ៍របស់វា។ ឧទាហរណ៍ នៅខាងបូព៌ាមាន សោ ភឹម ជាលេខាអចិន្ត្រៃយ៍ភូមិភាគ បន្ទាប់មកវាមានអ្នកផ្សេងទៀត។ ឧទាហរណ៍ ភួង ជាដើម។

**ស៖** តើលោកអាចនិយាយបានទេថា តើមានមនុស្សប៉ុន្មាននាក់ដែលនៅក្នុងគណៈអចិន្ត្រៃយ៍ភូមិភាគនោះបាទ?

**ឆ៖** ខ្ញុំស្គាល់គេមិនច្បាស់ទេ។ ដោយឡែកនៅខាងភូមិភាគបស្ចិមលេខា ជូ ជេត ហៅ ស៊ី, អនុលេខា ហួត ហេង ហៅ ប៉ាល់។ បន្ទាប់មកមានអ្នកផ្សេងទៀត ដូចយ៉ាង អ្ហែ! ខ្ញុំមិនដូចយ៉ាងទេ ដូចតែដឹងពីរហ្នឹងទេ។

**ស៖** សូមអរគុណ។ ប៉ុន្តែខ្ញុំចង់សួរថាប្រហែលជាមានមនុស្សប៉ុន្មាននាក់នៅក្នុងគណៈអចិន្ត្រៃយ៍ភូមិភាគ។ បាទ ជាចំនួនប្រមាណ ប៉ាន់ប្រមាណ គឺខ្ញុំមិនចង់បានឈ្មោះទេ?

**ឆ៖** ដូចជាមិនលើសពីប្រាំនាក់។

**ស៖** លោកបានផ្តល់សក្ខីកម្មពីម្សិលមិញ ហើយពីថ្ងៃមុននោះទៀតដែលនិយាយថាសមាជិកនៃភូមិភាគ ក៏ជាសមាជិកនៃគណៈអចិន្ត្រៃយ៍ផងដែរ តើត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់បញ្ហានេះឡើងវិញឲ្យបានច្បាស់ ហើយឲ្យបានចំ។ លេខាអចិន្ត្រៃយ៍ភូមិភាគបូព៌ានេះមួយ គឺ សោ ភឹម, លេខាភូមិភាគនិរតីនេះពីរ គឺ អ៊ុង ជឿន ហៅ ម៉ុក ជាសមាជិកអចិន្ត្រៃយ៍មជ្ឈិម ក្រៅពីនោះជាសមាជិកមជ្ឈិមពេញសិទ្ធិ។ ដូចយ៉ាង កែ ពក ត្រឹមតែជាសមាជិកមជ្ឈិមពេញសិទ្ធិទេ កែ ពក, រស់ ញឹម, ជូ ជេត ហៅស៊ី, កង ចាប។

[០៩:៣៧:០៦]

**ស៖** តើលោកដឹងទេ ហេតុអ្វីបានភូមិភាគនីមួយៗមានសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍? ហេតុអ្វីបានជាគេបង្កើតរចនាសម្ព័ន្ធបែបនោះបាទ?

**ឆ៖** បញ្ហានេះ ហួសការយល់ដឹងរបស់ខ្ញុំហើយ។

**ស៖** សូមអរគុណ។ ថាតើនៅក្នុងភូមិភាគនោះត្រូវបានបែងចែកទៅជារចនាសម្ព័ន្ធរដ្ឋបាលតូចៗបន្តទៀត ឬទេ?

**ឆ៖** អរគុណ។ ភូមិភាគនីមួយៗត្រូវបែងចែកជាតំបន់។

**ស៖** ថាតើតំបន់នីមួយៗមានគណៈ ៗរបស់គេដើម្បីទទួលបន្ទុកក្នុងតំបន់ហ្នឹងឬទេ?

**ឆ៖** ក្នុងតំបន់នីមួយៗមានគណៈកម្មាធិការរបស់គេទទួលភារកិច្ចក្នុងតំបន់នោះ។

**ស៖** ហើយយើងបាននិយាយទៅរកគណៈកម្មាធិការរបស់បក្សកុម្មុយនីស្តកម្ពុជា តើត្រូវឬទេ?

**ឆ៖** សំណួរនេះ ខ្ញុំស្តាប់មិនទាន់បានទេ។ សូមអនុញ្ញាតសួរម្តងទៀត។

**ស៖** លោកនិយាយថា តំបន់មួយៗមានគណៈកម្មាធិការ អ៊ីចឹងតើច្បាស់ទេ ដែលថាគណៈកម្មាធិការហ្នឹង ជាគណៈកម្មាធិការរបស់បក្សកុម្មុយនីស្តកម្ពុជា សួរថាតើត្រូវឬទេ?

**ឆ៖** ត្រឹមត្រូវទៅហើយ។

**ស៖** ដូច្នេះ អង្គជំនុំជម្រះបានយល់អំពីរចនាសម្ព័ន្ធឲ្យបានច្បាស់ទៀត ហើយតំបន់នោះត្រូវបានបែងចែកទៅជាអង្គភាពរដ្ឋបាលតូចៗទៀតដែរឬទេ? ប្រសិនបើមាន ថាតើគេបែងចែកតំបន់ទៅជាអ្វីខ្លះ?

**ឆ៖** អរគុណ។ តំបន់ត្រូវបែងចែកទៅជាស្រុក។

[០៩:៤០:០០]

**ស៖** ថាតើស្រុកនីមួយៗមានគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជារបស់គេ ដើម្បីគ្រប់គ្រងឬក៏កាន់កាប់នៅក្នុងស្រុកនោះដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។ ស្រុកនីមួយមានគណៈកម្មាធិការរបស់បក្សកុម្មុយនីស្តកម្ពុជាចាត់ចែង និងគ្រប់គ្រងគ្រប់ការងារនៅទីនោះ។

**ស៖** ថាតើស្រុកនីមួយៗត្រូវបានបែងចែកទៅជាអង្គភាពតូចៗនៃរដ្ឋបាលទៀតដែរឬទេ?

**ឆ៖** អរគុណ។ ស្រុកនីមួយៗត្រូវបែងចែកទៅជាអង្គភាពតូចៗទៀត។ អង្គភាពតូចៗនេះ ដើមឡើយគេហៅថា “ឃុំ” ក្រោយមកគេហៅថា “សហករណ៍”។

[០៩:៤១:១៥]

**ស៖** ហើយមុខងារនីមួយៗនៅក្នុងគណៈកម្មាធិការនោះគេមានតំណែងដែរឬទេ អ្នកដែលជាសមាជិកនៃគណៈកម្មាធិការនៅក្នុងថ្នាក់នីមួយៗ នៅក្នុងអង្គភាពភូមិសាស្ត្រហ្នឹង តើគេមានជាតំណែងមុខងារអ្វីខ្លះដែរឬទេ?

**ឆ៖** បើនិយាយតាមផ្លូវបក្ស សហករណ៍នីមួយៗគ្រប់គ្រង ដោយគណៈកម្មាធិការបក្សសហករណ៍ ឬក៏គេហៅថា "គណៈកម្មាធិការសាខាបក្សសហករណ៍"។

**ស៖** ហើយសមាជិកទាំងអស់នោះ គេកាន់តំណែងអ្វីទេនៅក្នុងគណៈកម្មាធិការនីមួយៗ ជាពិសេសនិយាយពីមុខងារនាទីរបស់គេ នៅថ្នាក់គណៈកម្មាធិការនៅក្នុងថ្នាក់ផ្សេងៗដែលយើងទើបបាននិយាយអម្បាញ់មិញនេះបាទ?

**ឆ៖** ការបែងចែកដែលខ្ញុំយល់ដឹងបាន ពេលនោះ កម្លាំងសំខាន់គេហៅថា "កងចល័ត"។ គឺកម្លាំងយុវជន យុវនារីដែលប្រមូលផ្តុំគ្នាសម្រាប់ទៅរ៉ែបុកទំនប់ ទៅរ៉ែបុកប្រឡាយទឹកអីៗហ្នឹង គឺនៅកងចល័ត។ កងចល័តគ្រប់គ្រងដោយសាខាបក្ស។ នេះខ្ញុំក្តាប់បានតែប៉ុណ្ណឹង ក្រៅពីហ្នឹងមកវាមានពួកចង្ក្រានបាយ វាមានពួកអីៗទៀត។ ដូច្នេះ ខ្ញុំសូមនិយាយបានតែប៉ុណ្ណឹង។

**ស៖** សូមអភ័យទោស ប្រហែលជាខ្ញុំសួរទៅធ្វើឲ្យលោកច្រឡំ។ ចំពោះគណៈកម្មាធិការមួយៗថាតើមានប្រធានគណៈកម្មាធិការដូចជា កម្មាភិបាលជាអ្នកទទួលបន្ទុកហ្នឹង គេ-- អ្នកទទួលបន្ទុកហ្នឹងគេមានឋានៈស្អី ចង់សួរអ៊ីចឹងវិញបាទ?

[០៩:៤៣:៣៩]

**ឆ៖** លេខាគណៈកម្មាធិការសហករណ៍ គឺជាបក្ខជន។ ដូច្នេះ មនុស្សនៅក្នុងគណៈកម្មាធិការនេះត្រូវតែជាបក្ខជន។

**ស៖** តើលេខានីមួយៗនៅក្នុងគណៈកម្មាធិការនោះ គេមានអនុលេខាគ្រប់ទាំងអស់ដែរឬទេ?

**ឆ៖** ខ្ញុំមិនឆ្លើយទេ បើឆ្លើយវាចូលទៅផ្លូវស្មាន ប៉ុន្តែដូចជាអាចនឹងមាន ដូច្នេះខ្ញុំមិនឆ្លើយទេ។

**ស៖** សូមអរគុណ។ បាទ គឺថាលោកមិនឆ្លើយគឺថាលោកមិនចង់ស្មាន។ លោកសាក្សី កាលពីថ្ងៃមុនលោកបានពន្យល់តុលាការ គឺនិយាយអំពីគោលការណ៍នៃការរាយការណ៍នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា លោកបានយោងទៅរកមាត្រា៦.៥ ដែលថាថ្នាក់ក្រោមត្រូវតែរាយការណ៍ទៅថ្នាក់លើអំពីសភាពការណ៍ ហើយនិងការងារដែលត្រូវបានធ្វើ។ តើលោកនៅចាំអំពីគោលការណ៍ទូទៅនោះទេ នៅក្នុង

លក្ខន្តិកៈបក្សនោះ?

[០៩:៤៥:០៩]

**ឆៈ** អរគុណ។ ខ្ញុំនៅចាំ។

**សៈ** បើដូច្នោះមែន តាមរយៈការសិក្សាលក្ខន្តិកៈនៅសម័យនោះ ហើយតាមការសង្កេតនិងការបទពិសោធន៍របស់លោក ជាពិសេសថា ស-២១ ជាកងវរមួយឯករាជ្យ តើលោកអាចពន្យល់តុលាការបានទេ ថាតើគោលការណ៍ដែលថែងថា អ្នកថ្នាក់ក្រោមត្រូវរាយការណ៍ទៅថ្នាក់លើ តើគេយកទៅអនុវត្តដូចម្ដេចនៅថ្នាក់តំបន់ នៅក្នុងភូមិភាគ នៅក្នុងស្រុក ហើយនិងសហ-- អ៎! នៅក្នុងឃុំ ដូចជាសហករណ៍ជាដើមហ្នឹងបាទ?

**ឆៈ** អរគុណ។ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាជាឯកសារតែមួយគត់ ដែលទាំងអស់គ្នាគោរព។ ដូច្នេះរបបរាយការណ៍ពីក្រោមឡើងលើ ជារបបដែលទូទាំងបក្សត្រូវគោរព។ ខ្ញុំសូមនិយាយអំពីគណៈកម្មាធិការសេនាធិការដើម្បីស្រួលយល់ ព្រោះខ្ញុំឃើញ ហើយអាចលើកឧទាហរណ៍បានច្បាស់។ គណៈកម្មាធិការសេនាធិការវាមានអចិន្ត្រៃយ៍របស់គេ ហើយនិងសមាជិកពេញសិទ្ធិរបស់គេ។ ដល់និយាយពីគណៈកម្មាធិការសេនាធិការបើកទូលាយ វាត្រូវរួមទាំងលេខាកងពលគ្រប់កងពលទៅទៀត។ នេះគេហៅ គណៈកម្មាធិការសេនាធិការបើកទូលាយ។

[០៩:៤៦:៤៩]

ដូច្នេះ ពេលត្រូវការប្រជុំចាំបាច់ គេត្រូវការអាទូលាយហ្នឹងក៏មាន គេត្រូវការអាមិនទូលាយធម្មតាហ្នឹងក៏មាន។ ខាងក្រោមរាយការណ៍ខាងលើ លេខាកងពលរាយការណ៍ជូនលេខាសេនាធិការ។ ដូច្នេះនៅក្នុងសហករណ៍ក៏ដូច្នោះដែរ។ កងចល័តវារាយការណ៍ជូនលេខាសហករណ៍។ លេខាសហករណ៍មួយវាជាសមាជិកគណៈស្រុក ដែលបើកទូលាយ វារាយការណ៍ជូនគណៈស្រុកតាមខ្សែរបស់អីចឹង។ ដូច្នេះចេះតែតអីចឹងតទៅ។ នេះគឺខ្ញុំធ្វើការសរុបតាមទម្រង់ហ្នឹង។ ព្រោះនិយាយឡើងវិញរបបរាយការណ៍ពីក្រោមឡើងលើ ជារបបដែលបក្សកំណត់ ទូទាំងបក្សត្រូវតែអនុវត្ត។

**សៈ** ដូច្នេះ បើយើងតាមពិនិត្យទៅ គឺថាគណៈកម្មាធិការស្រុកក៏ត្រូវរាយការណ៍ទៅគណៈកម្មាធិការតំបន់ តើអីចឹងឬទេ?

**ឆៈ** អរគុណ គឺត្រឹមត្រូវ ត្រូវតែរាយការណ៍ទៅលើ។

**សៈ** ថាតើនៅគណៈកម្មាធិការតំបន់នោះត្រូវរាយការណ៍ទៅណាតទៅទៀត? ទៅភូមិភាគឬក៏

ទៅណា?

[០៩:៤៨:១៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! ឥឡូវមានការជំទាស់ពីមេធាវីការពារក្តី។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំសូមជំទាស់នឹងសំណួរនេះ។ សំណួរនេះគឺមិនច្បាស់លាស់ថាតើក្នុងរយៈពេលណា សម័យកាលណាទេ។ ហើយក៏យើងមិនដឹងថា តាមទ្រឹស្តីក្របខ័ណ្ឌនោះមិនច្បាស់ថាពេលណា។ តើក្នុងស្ថានភាពណាមួយ? តើយើងនិយាយអំពីតួអក្សរឬក៏ថា លិខិតអ្វីដែលចេញនៅក្នុងពេលនោះ ដែលថាសាក្សីគាត់មិនអាចឆ្លើយបានទេ។ គាត់ជាប្រធានស-២១ ទេ ជាលេខានៃកងវរសេនាធំ។ ដូច្នេះហើយ បើយើង-- តាមដែលយើងយល់គឺថា គាត់មិនអាចយល់អ្វីលើសពីហ្នឹងទេ។ គាត់មិនអាចដឹងថា អ្វីកើតឡើងនៅក្នុងភូមិភាគ ឬក៏ស្រុកនោះបានទេ។

[០៩:៤៩:២០]

**លោក វីណ្ឌៀម ស្មីត៖**

ខ្ញុំមិនបានសួរថា តើអ្វីកើតឡើងនៅក្នុងថ្នាក់ស្រុក ថ្នាក់តំបន់នោះទេ។ ខ្ញុំសួរគាត់ថាតើ តើគេតម្រូវឲ្យអនុវត្តតាមលក្ខន្តិកៈដូចម្តេចចំពោះរចនាសម្ព័ន្ធនោះ? ហើយគាត់និយាយថា លក្ខន្តិកៈហ្នឹងគឺកំណត់ឲ្យអ្នកទាំងនោះអនុវត្តទូទាំងបក្ស ហើយគាត់ក៏បានយល់អំពីចេតនានៃលក្ខន្តិកៈហ្នឹងតាមរយៈវគ្គសិក្សា។ ដូច្នេះហើយសាក្សីរូបនេះក៏អាចនឹងជម្រាបជូនតុលាការបានអំពីអត្ថន័យ អំពីគោលដៅនៃលក្ខន្តិកៈនេះបាន ដោយសារថា គាត់មានការយល់ដឹងអំពីលក្ខន្តិកៈបក្សនេះ។ យើងមិននិយាយប្រាប់សាក្សីថា វាមានរឿងកើតអីចឹងនៅក្នុងភូមិភាគ យើងមិនបាននិយាយអីចឹងទេ។ អ្វីដែលយើងនិយាយនេះគឺថា តើគោលបំណងនៃលក្ខន្តិកៈហ្នឹងមានដូចម្តេច? ហើយសាក្សីរូបនេះ គាត់ជាបុគ្គលដ៏ល្អក្នុងការពន្យល់ថាតើមានគោលបំណងយ៉ាងម៉េច ដោយសារគាត់បានចូលវគ្គសិក្សា គាត់បានដឹងច្រើនពីរឿងហ្នឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

[០៩:៥០:៣២]

**លោក ម៉ែខល ផេសមិន៖**

ប្រសិនបើសហព្រះរាជអាជ្ញាមានចេតនាចង់សួរបែបហ្នឹង។ ចង់ឲ្យលោករៀបពាក្យសំណួរឡើងវិញ ដើម្បីកុំឲ្យលាបព័ត៌មានមួយ ដើម្បីឲ្យសាក្សីគាត់ធ្វើការស្មាន ឬក៏និយាយដោយមិនច្បាស់នោះ។

**ប្រធានអង្គជំនុំ៖**

ជំទាស់របស់មេធាវីការពារក្តីគ្មានប្រសិទ្ធភាព។ លោកតំណាងសហព្រះរាជអាជ្ញាអាចបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះតទៅទៀត ហើយគ្រាន់តែសុំឲ្យមានការគិតគូរពិចារណាក្នុងការរៀបចំនូវការតាំងសំណួរ ដើម្បីជៀសវាងនូវ-- ឲ្យផុតនូវសំណួរណាដែលច្បាប់ហាមឃាត់។

**លោក វីណ្ស៊ៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ហើយខ្ញុំនឹងព្យាយាមពិនិត្យមើលនូវរចនាសម្ព័ន្ធរបស់ភូមិភាគ ហើយនិងថ្នាក់ជាតិ។ ខ្ញុំមានសំណួរតែពីរបីទេនៅក្នុងករណីនេះបាទ ហើយនិងខ្ញុំចូលទៅប្រធានបទផ្សេង។

**សួរដោយលោក វីណ្ស៊ៀម ស្មីត៖**

**ស៖** លោកសាក្សី ដែលលក្ខន្តិកៈតម្រូវ ដែលលោកជឿជាក់ថា លក្ខន្តិកៈតម្រូវបែបនោះថាតើអ្នកណាជាអ្នកដែលគណៈកម្មាធិការតំបន់ត្រូវរាយការណ៍បន្ទាប់ទៅលើទៀតមួយនោះ ទៅថ្នាក់ណា? ខ្ញុំមិនឲ្យលោកសន្និដ្ឋានទេ គឺថាតាមអ្វីដែលលោករៀនពីលក្ខន្តិកៈហ្នឹង ថាតើគណៈកម្មាធិការតំបន់នោះត្រូវរាយការណ៍ទៅថ្នាក់លើមួយទៀតនោះ ថ្នាក់ណា?

[០៩:៥២:១៤]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ គណៈកម្មាធិការតំបន់ត្រូវរាយការណ៍ឡើង ដល់គណៈកម្មាធិការភាគ។

**ស៖** តើគណៈកម្មាធិការភូមិភាគត្រូវរាយការណ៍ ទៅកម្រិតណាមួយទៀតដែរឬទេ ចំពោះស្ថានការណ៍ទូទៅនោះ?

**ឆ៖** នៅខាងលើផ្ទាល់របស់ភូមិភាគនីមួយៗ គឺអចិន្ត្រៃយ៍មជ្ឈិម និយាយឲ្យចំគឺ លេខា និងអនុលេខាមជ្ឈិម។

**ស៖** លោកបានបញ្ជាក់ពីខាងដើមថា ពីម្សិលមិញនោះ គណៈមជ្ឈិម អចិន្ត្រៃយ៍មជ្ឈិមហ្នឹង គឺថានៅក្នុងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា តើត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** លោកក៏បានប្រាប់តុលាការដែរថា គណៈមជ្ឈិម ត្រូវបានបែងចែកទៅជាបួនផ្នែក ប្រហែលជាអ៊ីចឹង ហើយសមាជិកពេញសិទ្ធិ សមាជិកត្រៀម ហើយពួកសមាជិកមួយប្រភេទទៀត ដែលថាបម្រុង ហើយនិងគណៈអចិន្ត្រៃយ៍។ តើត្រូវដូច្នេះដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ដូច្នេះដើម្បីឲ្យយើងច្បាស់ នៅក្នុងគណៈមជ្ឈិមនោះ ថាតើអ្នកណាខ្លះនៅក្នុងផ្នែកទាំងបួននេះ។ គណៈកម្មការផ្សេងៗទៀតនោះ ផ្នែកណាមួយដែលថាមានអំណាចខ្លាំងជាងគេ តាមអ្វីដែលលោកបានដឹង ឬក៏តាមការសិក្សារបស់លោកទៅលើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** អចិន្ត្រៃយ៍មានអំណាចជាងគេ។

**ស៖** ហើយយើងក៏បានយោងទៅរកអង្គការចាត់តាំងរបស់បក្ស មិនត្រូវរាយការណ៍ទៅលើតែមួយមុខទេ តែត្រូវរាយការណ៍ទៅក្រោមវិញផងដែរ យើងបានពិភាក្សាផ្នែកនេះ មាត្រា៦.៥ គឺថា មានពេលខ្លះ ថ្នាក់លើត្រូវរាយការណ៍ទៅថ្នាក់ក្រោមវិញទាក់ទងទៅនឹងស្ថានភាពទូទៅ ហើយនិងស្ថាន-ការណ៍រួមអំពីសេចក្តីណែនាំជាទិសការងារផ្សេងៗ។ តើលោកបានចាំថា មានធ្លាប់ធ្វើការពិភាក្សាពីបញ្ហានេះទេនៅក្នុងសម័យនោះ?

**ឆ៖** អរគុណ។ ថ្នាក់លើត្រូវតែរាយការណ៍សភាពការណ៍រួមឲ្យថ្នាក់ក្រោមយល់ ដើម្បីធ្វើ--ជំរុញថ្នាក់ក្រោមឲ្យយល់សភាពការណ៍ ហើយធ្វើការឲ្យសកម្ម។ នេះជាការចាំបាច់។ ក៏ប៉ុន្តែ ខ្ញុំមិនទាន់ឃើញឯកសារណាកំណត់ឲ្យច្បាស់លាស់ថា ថ្នាក់លើត្រូវរាយការណ៍ឲ្យថ្នាក់ក្រោមយ៉ាងម៉េចទេ ឃើញតែកាលហ្នឹង គាត់ហៅយើងទៅធ្វើការ គាត់កំណត់របៀបវារៈ គាត់ចុះសភាពការណ៍ឲ្យយើង។

[០៩:៥៧:០០]

**ស៖** នៅពេលដែលលោកនិយាយថា តាមទម្លាប់នោះគឺថា លោកបានធ្វើការនៅស-២១ ហើយយើងក៏យល់ដែរថា លោកបានចូលរួមវគ្គសិក្សាអប់រំ ហើយយើងក៏យល់ដែរថា លោកបានសង្កេតថាតើបក្សកុម្មុយនីស្តកម្ពុជាអនុវត្តការងារជាទូទៅដូចម្តេច? តើលោកអាចនិយាយបានទេថា គោលការណ៍ទាំងនេះ លាក់ការណ៍ទាំងនេះ ហើយនៅក្នុងលក្ខន្តិកៈនោះ គឺថាវាមានការរាយការណ៍ពីក្រោមទៅលើ ហើយពីលើទៅក្រោម តើលោកអាចនិយាយបានទេ? តាមពិតគេយកទៅអនុវត្តដែរឬទេ គឺទៅក្នុងការសន្ទនាផ្សេងៗ ដូចជា ក្នុងការងារប្រជុំ ពេលការងាររបស់លោកនៅក្នុងសម័យកាលនោះ?

**ជ៖** ខ្ញុំសូមបញ្ជាក់ថា គោលការណ៍នេះវាជាគោលការណ៍ ដែលមានចែងក្នុងលក្ខន្តិកៈ ដែលជាច្បាប់តែមួយគត់សម្រាប់ទូទាំងបក្ស។ ដូច្នេះថ្នាក់លើវាយការណ៍ឲ្យខាងក្រោម វាមានរូបភាពរបស់វាវគ្គសិក្សាដែលគេចុះសភាពការណ៍ឲ្យយើង វាជារូបភាពមួយដែលខាងលើវាយការណ៍ឲ្យខាងក្រោម ហើយឆ្នាំនេះ លន់ នល់ ឈ្នះយ៉ាងម៉េច? យើងឈ្នះយ៉ាងម៉េច? ហ្នឹងខាងលើគេវាយការណ៍ឲ្យខាងក្រោម ឲ្យសភាពការណ៍រួម ដើម្បីខាងលើគេជំរុញទិសតទៅទៀត តើត្រូវធ្វើស្អី? ដូច្នេះ អាទស្សនៈសភាពការណ៍ដែលគេចុះឲ្យរាល់ឆ្នាំហ្នឹងហើយ ដែលខាងលើវាយការណ៍ឲ្យខាងក្រោមយល់ តាមកាលកំណត់។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។

[០៩:៥៨:៥១]

**ស៖** សូមអរគុណ។ យើងសុំអនុញ្ញាតត្រឡប់មកសេចក្តីសម្រេចរបស់គណៈមជ្ឈិមទាក់ទងទៅនឹងសិទ្ធិក្នុងការកម្ទេចនៅក្នុងជួរ និងក្រៅជួរបក្ស នៅក្នុងជួរ ដែលចែងថា បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច។ តើឃ្លានេះមានន័យដូចម្តេច ទាក់ទងទៅនឹងសិទ្ធិក្នុងការ-- សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ នៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេចនោះ?

**ជ៖** ដំបូងខ្ញុំសូមបញ្ជាក់ប្រាប់ថា ក្របខ័ណ្ឌមូលដ្ឋាន១ មិនមែនភ្នំពេញហើយក៏មិនមែនកងទ័ព។ ឯចំណែកក្រឹត្យក្រមនៃការកម្ទេច ខ្ញុំធ្លាប់អនុវត្តតាំងពី៧១ មក គ្រប់កិច្ចកម្ទេចនៅក្នុងភូមិភាគ ត្រូវតែលេខាភាគសម្រេច តាំងពី៧១មក រហូតមក។ ដូច្នេះ គោលការណ៍នេះ វាមានកំណើតវាតាំងពី៧១មកនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

[១០:០០:២៧]

**ស៖** ដូច្នេះ តាមអ្វីដែលខ្ញុំយល់ លោកត្រឹមត្រូវនោះ គឺថាប្រសិនបើខ្មាំងស្ថិតនៅក្នុងតំបន់ភូមិសាស្ត្រណាមួយរបស់ភូមិភាគ។ ពេលនោះភូមិភាគ ឬគណៈអចិន្ត្រៃយ៍ភូមិភាគអាចចាប់សម្លាប់ ឬក៏កម្ទេចជននោះ តើត្រូវឬទេ?

**ជ៖** គឺទាល់តែអចិន្ត្រៃយ៍ភាគសម្រេច ទើបបានចាប់បាន។ ពីព្រោះទាល់-- តែកាលណាចាប់ហើយ គឺត្រូវតែកម្ទេច។

**ស៖** ដូច្នេះអំណាចក្នុងការកម្ទេច គឺផ្ទេរទៅឲ្យគណៈអចិន្ត្រៃយ៍ភូមិភាគ តើត្រឹមត្រូវដែរឬទេ?

**ជ៖** ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ គោលបំណងដែលខ្ញុំសូមសួរសំណួរនេះ គឺដើម្បីឲ្យយើងខ្ញុំយល់ ថាតើ

រចនាសម្ព័ន្ធរដ្ឋបាលនៃបក្សកុម្មុយនីស្តកម្ពុជានោះ ដំណើរការដោយរបៀបណា? លោកបានពន្យល់អំពីរចនាសម្ព័ន្ធនៅទូទាំងប្រទេស។ នៅពេលនេះ ខ្ញុំសូមសួររចនាសម្ព័ន្ធដែលសេចក្ដីសម្រេចនេះ បានបញ្ជូនទៅដល់រចនាសម្ព័ន្ធទាំងអស់នោះ។ សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ ដូច្នេះសំណួរទីមួយរបស់ខ្ញុំនោះ គឺតើលោកបានដឹងដែរឬទេ ថានៅពេលនោះ ទោះបីលោកមិនបានឃើញឯកសារនេះក៏ដោយ តើមានបញ្ហាអ្វីខ្លះ ដែលកើតមាននៅជុំវិញមន្ទីរមជ្ឈិម? ហើយពាក្យថា "មន្ទីរមជ្ឈិម" នេះ មានន័យយ៉ាងម៉េចដែរ?

[១០:០២:៥៣]

**ឆ៖** មន្ទីរមជ្ឈិម ខ្ញុំបានរាយការណ៍នៅក្នុងពេលសាកសួរ ពេលស៊ើបសួរ ស៊ើបអង្កេត។ មន្ទីរមជ្ឈិមនេះ ខ្ញុំបានសម្គាល់ថាមួយផ្នែកទៀត គេហៅថា ការងារផ្សេងៗជុំវិញមន្ទីរមជ្ឈិម។ ដូចជាខាងតេអូ ខាងនីរសារ ខាងការពារ។ នេះ ខ្ញុំសម្គាល់អ៊ីចឹង។ ឯចំណែក នៅពេលនោះ ខ្ញុំសម្គាល់ថា ដែលហៅថា "គណៈមន្ទីរមជ្ឈិម" គឺសំដៅអ្នកដែលជួយការងារលេខា អនុលេខាផ្ទាល់។ នេះ ខ្ញុំសម្គាល់ឃើញអ៊ីចឹង។ ដូច្នេះដែលហៅថា មន្ទីរមជ្ឈិម គឺអង្គភាពទាំងឡាយណា ដែលមជ្ឈិមចាត់តាំងឡើងដើម្បីជួយការងាររបស់ខ្លួន តាមមុខសញ្ញានីមួយៗ។ នេះ ខ្ញុំយល់ឃើញអ៊ីចឹង។

**ស៖** ត្រូវសម្រេច ពាក្យថា ត្រូវគណៈមជ្ឈិម-- ត្រូវគណៈមន្ទីរមជ្ឈិមសម្រេចនោះ តើមានន័យយ៉ាងម៉េច? ដូច្នេះ មន្ទីរមជ្ឈិមនោះ នៅក្នុងអំឡុងរបបសម័យនោះ តើវាមានន័យយ៉ាងម៉េច?

[១០:០៤:៥៥]

**ឆ៖** សូមជម្រាបថា មន្ទីរមជ្ឈិមសម័យនោះ ខ្ញុំពន្យល់មិនបានត្រឹមត្រូវ ហើយឲ្យចំទេ។ ព្រោះវាឆ្ងាយពីខ្ញុំពេក ក៏ប៉ុន្តែខ្លឹមសារឯកសារនេះទាល់តែលេខាគណៈកម្មាធិការមន្ទីរមជ្ឈិមបានសម្រេចបាន នេះជាទ្រឹស្ដី។ ក្នុងការអនុវត្តជាក់ស្ដែង តើគាត់សម្រេចយ៉ាងម៉េច អីយ៉ាងម៉េច? អាហ្នឹងបញ្ហាមួយផ្សេងទៀត។ ដូច្នេះជាទ្រឹស្ដីគឺលេខាគណៈកម្មាធិការមន្ទីរមជ្ឈិមទើបសម្រេចបាន។ នេះជាទ្រឹស្ដី ខ្ញុំនិយាយប៉ុណ្ណឹង។

**ស៖** ប្រសិនបើយើងមើលក្រុមទីបី ដែលមានសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ ដែលក្នុងនេះចែងថា តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច។ លោកបាននិយាយអំពីតំបន់ដែលស្ថិតនៅក្រោមភូមិភាគ។ ដូច្នេះខ្ញុំចង់សួរ "តំបន់ឯករាជ្យ" នេះមានន័យយ៉ាងម៉េច? ពាក្យហ្នឹង? ហើយជាពិសេសនោះ តើលោកគិតថាចំពោះលោកនោះ តំបន់ឯករាជ្យនោះមានន័យយ៉ាងម៉េចនៅក្នុងរបបកម្ពុជាប្រជាធិប-

តេយ្យ? តំបន់ឯករាជ្យនេះ តើអត្ថន័យវាយ៉ាងម៉េចដែរ?

[១០:០៦:៣៩]

**ឆ៖** អរគុណ។ ពាក្យ "ឯករាជ្យ" មួយម៉ាត់នេះ គឺវាមិនឡើងផ្ទាល់ ទៅលើផ្ទាល់ទេ។ ឧទាហរណ៍ស-២១ វាជាវរសេនាធំឯករាជ្យ វាអត់ឡើងទៅកងពលណាមួយទេ វាឡើងផ្ដោះទៅដល់សេនាធិការ។ តំបន់ឯករាជ្យក៏អ៊ីចឹង វាមិនឡើងទៅភូមិភាគណាមួយទេ គឺវាឡើងផ្ដោះទៅដល់អចិន្ត្រៃយ៍មជ្ឈិម ទៅដល់លេខា និងអនុលេខាហ្នឹងតែម្ដង។ ដូច្នេះតំបន់ឯករាជ្យ គឺវាអ៊ីចឹង។ វាយការណ៍គ្រប់បញ្ហា គឺវាឡើងទៅដល់លេខា និងអនុលេខា។ ឯចំណែកតំបន់ឯករាជ្យមានស្អីខ្លះ ខ្ញុំវង្វេងហើយ ក្ដាប់មិនបានទេ។

**ស៖** តើលោកដឹងដែរឬទេថា តើមានតំបន់ឯករាជ្យណាខ្លះដែលគេបង្កើតឡើងនៅក្នុងរបបនុ៎ង? តើលោកស្គាល់ឈ្មោះតំបន់ឯករាជ្យមួយចំនួន ដែលគេបង្កើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរឬទេ?

**ឆ៖** ខ្ញុំមិន-- ខ្ញុំចាំមួយពីរទេ ដំបូងសៀមរាប សៀមរាបអង្គរនេះជាតំបន់ឯករាជ្យ គឺឡើងមកលេខា និងអនុលេខាមជ្ឈិមផ្ទាល់។ ដូចជាខាងក្រចេះ ៥០៥ ក្រចេះនេះ ប៉ុន្មានទេ។ ខាងក្រចេះនេះ ជាតំបន់ឯករាជ្យមួយទៀត។ ដូច្នេះប្រហាក់ប្រហែលជាពីរ ឬក៏បីប៉ុននុ៎ងទេ។ ក្រុងកំពង់សោមមួយផង។

[១០:០៨:៥៣]

**ស៖** តាមការដឹងរបស់លោកនៅសម័យនោះ ហេតុអ្វីបានជាតំបន់ឯករាជ្យត្រូវបានបង្កើតឡើង ហើយតំបន់ឯករាជ្យនេះមិនចាំបាច់រាយការណ៍ទៅភូមិភាគទេ តែបែរជារាយការណ៍ទៅមជ្ឈិមវិញ ហើយតើមូលហេតុអ្វីបានជាគេបង្កើតតំបន់ឯករាជ្យ?

**ឆ៖** ខ្ញុំមើលទៅមកពីសារៈសំខាន់នៃកន្លែងនុ៎ង។ ឧទាហរណ៍ សៀមរាប មានអង្គរវត្ត។ នេះខ្ញុំសូមនិយាយខ្លីប៉ុណ្ណឹង។

**ស៖** ដើម្បីឲ្យយើងបានដឹងថាតើលោកដឹងព័ត៌មាននេះមកពីណាដែរ? លោកបានលើកឡើងថា ស-២១ គឺជាកងវរសេនាធំឯករាជ្យមួយ។ តើលោកបាននិយាយដូច្នេះដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយវរសេនា-- ស-២១ វាជាវរសេនាធំឯករាជ្យ។

**ស៖** នៅពេលដែលលោកនិយាយដូច្នេះ លោកចង់បានន័យថាស-២១ គឺស្ថិតនៅក្នុងរចនាសម្ព័ន្ធយោធារបស់បក្សកុម្មុយនីស្ដកម្ពុជា តើត្រឹមត្រូវដែរឬទេ?

**ផ៖** ត្រឹមត្រូវ។ ស-២១ ស្ថិតនៅក្នុងរចនាសម្ព័ន្ធយោធា យោធាមជ្ឈិម។

**ស៖** នៅស-២១ ជាយោធាមជ្ឈិមក្នុងរចនាសម្ព័ន្ធយោធាដូច្នោះ។ ដូច្នេះ តើលោកបានទទួលឯកសារពីយោធាមជ្ឈិម ពីមជ្ឈិមពាក់ព័ន្ធទៅនឹងបញ្ហាយោធាដែរឬទេ នៅក្នុងអំឡុងពេលដែលស-២១ នេះមានអត្ថិភាពនោះ?

[១០:១១:២១]

**ផ៖** ខ្ញុំបានជម្រាបបញ្ជាក់រួចហើយ។ ខ្ញុំបានទទួលឯកសារមជ្ឈិមមានទង់បដិវត្តជាដើម ទៀងទាត់។ ឯចំណែករបបហូបចុករបស់កងទ័ព ខោអាវ អាវុធយុទ្ធភ័ណ្ឌ ស្ថិតនៅក្រោមការគ្រប់គ្រងសេនាធិការ។ ដែលឯករាជ្យមិនស្ថិតក្រោមការគ្រប់គ្រងសេនាធិការតែចម្លើយសារភាពរបស់អ្នកទោសតែប៉ុណ្ណោះ។ ដើម្បីស្រួលយល់ខ្ញុំសូមបន្ថែមទៀតចុះ។ កងទ័ពមជ្ឈិមវាមានវរសេនាធំឯករាជ្យដូចតទៅ៖ ទីមួយ ស-២១។ ទីពីរ កងរថក្រោះ។ ទីបី កងកាំភ្លើងធំ។ ទីបួន កងទ័ពជើងទឹកជ្រោយចង្វា។ ទីប្រាំ កាត់ដេរ។ ទីប្រាំមួយ ពេទ្យ។ ដូច្នេះវាមានលក្ខណៈពិសេសៗរបស់វាអ៊ីចឹង មួយៗដាច់ដោយឡែកពីគ្នា មិនអាចស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលណាមួយបាន។

**ស៖** សូមអរគុណ។ បញ្ហាយោធានេះខ្ញុំចង់សុំសួរលោកចំណុចមួយចំនួន តើរចនាសម្ព័ន្ធយោធានោះ គេបង្កើតឡើងដោយរបៀបណានៅក្នុងសម័យនោះ? លោកបានលើកឡើងអំពីសេនាធិការ តើសេនាធិការនេះមានទីតាំង ដាក់ទីតាំងនៅឯណាដែរ? ហើយមន្ទីររបស់សេនាធិការកន្លែងណាដែរ?

**ផ៖** អរគុណ។ សេនាធិការនេះ វាមានទីតាំងរបស់វាសម្រាប់ សុន សេន ធ្វើការ។ កន្លែងសម្រាប់ សុន សេន ធ្វើការ គឺនៅប្លង់ដែលខ្ញុំរាយការណ៍ជូនត្រង់អក្សរ "បេ" ហ្នឹងឯង។ ដែល សុន សេន គាត់តែងហៅខ្ញុំទៅធ្វើការ នេះទីតាំង។ ក៏ប៉ុន្តែគ្មានស្នាកទេ។

[១០:១៣:៥៥]

**ស៖** ទាក់ទងទៅនឹងភូមិសាស្ត្រទីក្រុងភ្នំពេញ ថាតើវាស្ថិតនៅត្រង់ម្តុំណា? នៅជិតកន្លែងទីតាំងណាមួយ? ជិតទន្លេ ជិតវិមានឯករាជ្យ? នៅតាមផ្លូវនរោត្តម មហាវិថីនរោត្តម មានចំណុចសម្គាល់ណាមួយដែលថាទីតាំងហ្នឹងនៅជិតកន្លែងណាជាក់លាក់ដែរឬទេ? ដើម្បីឲ្យយើងអាចយល់ច្បាស់អំពីទីតាំងហ្នឹងនៅកន្លែងណា?

**ផ៖** ខ្ញុំជឿថា ព្រះរាជអាជ្ញាក៏ដូចជាប្រជាជនកម្ពុជាស្គាល់បុរីកីឡាច្បាស់ជាងគេ។ ខាងជើងបុរីកីឡាប្រហែលពីរផ្លូវ នេះអក្សរ "បេ" នៅនុ៎ង។

**ស៖** លោកនិយាយថា សុន សេន ជាអគ្គសេនាធិការ តើមានអ្នកណាផ្សេងទៀតដែលជាសមាជិករបស់សេនាធិការដែរឬទេ?

**ឆ៖** អ្នកដែលជាសមាជិករបស់សេនាធិការរបស់គេពេញសិទ្ធិនោះ ដំបូងមានបី។ ទីមួយ គឺ សុន សេន, ទីពីរ គឺ ម៉ែន សាន ហៅ យ៉ា, ទីបី គឺ ស៊ាត ឆែ ហៅ ទុំ។

**ស៖** យ៉ា និង ស៊ាត ឆែ អ្នកទាំងពីរអ្នកនេះ តើនៅរស់ដែរឬទេ នៅចុងសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** យ៉ា ធ្វើការនៅក្នុងអគ្គសេនាធិការហ្នឹងបានតែមួយរយៈខ្លី ត្រូវផ្លាស់ទៅនៅធ្វើជាលេខាភូមិភាគីឦសាន ហើយក៏ក្រោយមកចាប់យកមន្ទីរស-២១។ របៀបរបបសួរចម្លើយយ៉ា ព្រះរាជអាជ្ញាឱ្យខ្ញុំពន្យល់ ដែលខ្ញុំសរសេរសំបុត្រចុះឡើងជាមួយមិត្តប៉ុន។ ឯចំណែកទីពីរ ស៊ាត ឆែ ហៅ ទុំ ដល់ក្រោយមក ក៏ត្រូវចាប់ដែរ។ គាត់នៅនឹងសេនាធិការហ្នឹងរហូត រហូតដល់ថ្ងៃចាប់ខ្លួន។

[១០:១៦:៥៣]

**ស៖** ដូច្នេះហើយ អ្នកទាំងពីរហ្នឹងត្រូវបានសម្លាប់ចោលនៅស-២១ ទាំងពីរនាក់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ។

**ស៖** តើអគ្គសេនាធិការហ្នឹងមានតួនាទីអ្វីដែរ? តើអគ្គសេនាធិការហ្នឹងចាត់ចែងការអ្វីខ្លះ?

**ឆ៖** ខ្ញុំឆ្លើយមិនរួចទេ។ ក្នុងពេលសន្តិភាព ក្នុងពេលធម្មតា ខ្ញុំឃើញតែចាត់តាំងកម្លាំងធ្វើស្រែនៅជុំវិញភ្នំពេញ។ នេះជាបញ្ហាមួយ។ ឯចំណែកបញ្ហាដោយឡែក ខាងកងទ័ពជើងទឹកជ្រោយចង្វារគេខំធ្វើកប៉ាល់ពីឈើ នាវាប្រដេញពីឈើ។ ខាងស-២១ នេះធ្វើការរបស់ខ្លួនទៅ ឯចំណែកខាងរថក្រោះខំបង្រៀនអ្នករថក្រោះទៅ។ ឯចំណែកខាងកាំភ្លើងធំ គេបង្រៀនអ្នកកាំភ្លើងធំទៅ។ ហើយខាងតេអូ គេហៅគមនាគមន៍យោធាហ្នឹង គេបង្រៀនតាមនុំងទៅ។ ដូច្នេះ គេបង្ហាត់បង្រៀនបច្ចេកទេស។ ទន្ទឹមនឹងហ្នឹងបង្កបង្កើនផល ឧបត្ថម្ភខ្លួន។

[១០:១៨:៣៥]

**ស៖** សូមអរគុណ។ នៅក្នុងលក្ខន្តិកៈមាត្រា២៧ ចែងថា "កងទ័ពបដិវត្តន៍កម្ពុជាទាំងបីប្រភេទ ស្រួច តំបន់ ឈ្លប ត្រូវស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជា"។ សំណួររបស់ខ្ញុំ ចង់សុំសួរលោក គឺថាតាមអ្វីដែលលោកដឹង នៅក្នុងជួរយោធានាពេលនោះ

តើកងទ័ពត្រូវបានបែងចែកជាស្រួច តំបន់ និងឈ្លប ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈបក្សដែរឬទេ?

**ឆ៖** ត្រឹមត្រូវ! គឺបែងចែកតាមនុំងមែន ជាឈ្លប តំបន់ និងស្រួច។

[១០:១៩:៤០]

**ស៖** សូមអរគុណ។ នៅក្នុងពេលដែលលោកផ្ដល់សក្ខីកម្ម លោកបាននិយាយអំពីកងពលធំមួយចំនួននៅក្នុងជួរកងទ័ព។ តើលោកអាចពន្យល់បានដែរឬទេ មានកងពលធំចំនួនប៉ុន្មានកងពលដែរនៅក្នុងកងទ័ពស្រួចនាសម័យនោះ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! មានការជំទាស់ពីមេធាវីការពារក្ដី។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាសួរឲ្យបានជាក់លាក់បន្តិចអំពីនៅពេលដែលសួរអំពីរចនាសម្ព័ន្ធកងទ័ពនៅពេល-- ហើយថាតើកងទ័ពនោះត្រូវបានគេរៀបចំឡើងវិញយ៉ាងម៉េចនៅក្នុងឆ្នាំ១៩៧៦? ឲ្យសហព្រះរាជអាជ្ញានោះសួរឲ្យបានជាក់លាក់បន្តិច តើគាត់សួរក្នុងឆ្នាំណាដែរ អំពីបញ្ហាកងទ័ព? តើសួរឆ្នាំ៧៦ មុន៧៦ ឬក៏ក្រោយ ៧៦?

**លោក វីល្លៀម ស្មីត៖**

ខ្ញុំរីករាយក្នុងការសួរសំណួរឡើងវិញ ជាជាងមកជជែកគ្នាឲ្យឡើងជជែកគ្នាទៅលើចំណុចហ្នឹង។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** យើងដឹងហើយថា កងទ័ពបានរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនឡើងវិញ មុនពេលសម័យនុំង។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ-- ប្រហែល ៗជាខ្ញុំសួរអ៊ីចេះវិញ មុនថ្ងៃ១៧ ខែមេសា ៧៥ តើកងទ័ពនេះត្រូវបានគេរៀបចំរចនាសម្ព័ន្ធនៅទូទាំងប្រទេសនេះដោយរបៀបណាដែរ? បែងចែកជាអ្វីខ្លះ?

[១០:២១:៤៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ មុន១៧ មេសា កងទ័ពទូទាំងប្រទេស ប្រមូលផ្ដុំស្ថិតនៅក្រោមការគ្រប់-- ស្ថិតនៅក្រោមការកាន់កាប់ និងបញ្ជាផ្ទាល់របស់ភូមិភាគ លេខាភូមិភាគ។ ក៏ប៉ុន្តែ ក្រោមការគ្រប់គ្រងនិងចាត់ចែងដាច់ខាត និងទាំងស្រុងដោយអចិន្ត្រៃយ៍បក្ស ជានិយាយជាពិសេស គឺដោយលេខា និង

អនុលេខាបក្ស ចូលសម្រុកភ្នំពេញ ក៏ជាផែនការរបស់លេខា និងអនុលេខាបក្ស។ វាយភ្នំពេញ។ ក្រោយឈ្នះភ្នំពេញ ទើបបានលេខា និងអនុលេខាបក្សសុំពីភូមិភាគ មួយភូមិភាគពីរកងពល បីកងពល យកមកតម្រៀបជាកងពលមជ្ឈិម។ កងពលមជ្ឈិមនេះ ចាប់កំណើតឡើងនៅខែកក្កដា ១៩៧៥។ ដូច្នេះសេនាធិការក៏វាមានតួនាទីពីពេលនោះមកដែរ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១០:២៣:១៨]

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយអំពីលេខា និងអនុលេខាបក្ស គឺលោកចង់សំដៅទៅលើ ប៉ុល ពត និង នួន ជា មែនដែរឬទេ?

**ឆ៖** ពិតជាអ៊ីចឹង។

**ស៖** ដើម្បីឲ្យយើងយល់ច្បាស់ មុន៧៥ កងទ័ពគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនៅទូទាំងប្រទេស ហើយក្រោយកក្កដា ៧៥ កងទ័ពនេះត្រូវបានរៀបចំរចនាសម្ព័ន្ធបង្កើតជាកងពលហើយគ្រប់គ្រងដោយមជ្ឈិម ឬក៏ដោយអគ្គសេនាធិការ។ ដូច្នេះអ្វីដែលខ្ញុំសង្ខេបនេះត្រឹមត្រូវតាមអ្វីដែលលោកឆ្លើយដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ដើម្បីឲ្យស្រួលស្តាប់។ ភូមិភាគនីមួយៗមានភារកិច្ចកសាងកងទ័ពតាំងពីដើមមក។ ដល់ឆ្នាំ១៩៧៤ កងទ័ពគ្រប់ភូមិភាគកសាងបាន ប្រមូលផ្តុំបាន ជាកម្រិតកងពល។ ដូច្នេះកងទ័ពបង្កើតឡើងផ្ទាល់ដោយភូមិភាគ ក៏ប៉ុន្តែក្រោមការគ្រប់គ្រង និងដឹកនាំដាច់ខាត និងទាំងស្រុងអំពីលេខា និងអនុលេខាបក្ស។ ក្រោយឯករាជ្យ ទើបយកកងពលពីភូមិភាគមួយចំនួនទុកឲ្យមួយចំនួន យកមួយចំនួនហ្នឹងយកមកប្រមូលផ្តុំបង្កើតទៅជាកងទ័ពមជ្ឈិម ដែលមានប៉ុន្មានកងពលនោះ ហើយនិងប៉ុន្មានវរសេនាធំឯករាជ្យហ្នឹង។

**ស៖** ដូច្នេះលោកបាននិយាយថា ក្រោយ កក្កដា ឆ្នាំ១៩៧៥ ក្រោយពីការរៀបចំរចនាសម្ព័ន្ធឡើងវិញនោះ កងពលមួយចំនួនស្ថិតនៅក្រោមការគ្រប់គ្រងភូមិភាគ ហើយកងពលមួយចំនួនទៀតបានបង្កើតស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការ តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** សូមអរគុណ។ នៅពេលដែលកងទ័ពត្រូវបានគេរៀបចំរចនាសម្ព័ន្ធឡើងវិញ ហើយបង្កើតទៅជាកងពលដាក់នៅក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការ តើនៅពេលនោះមានកងពលចំនួនប៉ុន្មានដែរដែលគេបង្កើតឡើង? សូមឲ្យលោកប្រាប់ចំនួនប្រហែល។

[១០:២៦:១៩]

**ឆ៖** ខ្ញុំឆ្លើយសំណួរ-- ខ្ញុំឆ្លើយចំនួនមិនកើតទេ ខ្ញុំសូមរាប់ឈ្មោះកង-- លេខកងពល។ កងពល ១៧០ មកពីបូព៌ា, កងពល២៩០ មកពីបូព៌ា, កងពល៣១០ មកពីឧត្តរ, កងពល៤៥០ មកពីឧត្តរ កងពល៩២០ មកពីឧត្តរ, កងពល៨០១ មកពីនិរតី, កងពល៥០២ បញ្ចូលថែម ក៏ប៉ុន្តែភាគច្រើន មកមូលដ្ឋានមកពីនិរតីចាស់ កងពល១៦៤ មកពីនិរតីសុទ្ធសាធ។ នេះរាប់ទៅឃើញដូចប្រាំបីកងពល អាចនៅខ្វះមួយក៏មិនដឹង ហើយនិងវរសេនាធំឯករាជ្យប៉ុន្មាន ដែលខ្ញុំរាយការណ៍អំមិញហ្នឹង។

**លោក វីណ្ណៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំមានសំណួរមួយចំនួនតូចទៀត ខ្ញុំចង់សុំសួរអំពីរចនាសម្ព័ន្ធយោធា ហើយតើគេ ដំណើរការយ៉ាងម៉េច។ មុនពេលដែលខ្ញុំបន្តនោះគឺ ម៉ោងជិតដប់កន្លះហើយ ហើយខ្ញុំមានពាក្យសុំសំណើ សុំមួយ សុំពេលវេលាបន្ថែម។ នៅពេលនេះលោកចៅក្រម ឲ្យខ្ញុំបន្តសួររហូតត្រឹមពេលអាហារថ្ងៃត្រង់ ថ្ងៃព្រហស្បតិ៍ ហេតុដូច្នេះហើយ ទើបខ្ញុំសូមសួរសំណួរបញ្ចប់រហូតទៅដល់ថ្ងៃព្រហស្បតិ៍ពេលល្ងាចតែ ម្តង។ យើងឃើញថា ការជំទាស់មួយចំនួនបានលើកឡើងច្រើនពេក ដូច្នេះហើយជាហេតុសមហេតុផល ឲ្យយើងខ្ញុំមានពេលវេលាបន្ថែម។ ការជំទាស់មួយចំនួន ហើយវែង ហើយមិនត្រូវបានតម្កល់ ឬចាត់ទុក ថា មានសុពលភាពនោះទេ។ ដូច្នេះហើយដោយពិចារណាទៅលើពេលវេលាចំណាយទៅលើការជំទាស់ ដែលបានលើកឡើង យើងខ្ញុំស្នើសុំថា ឲ្យសហព្រះរាជអាជ្ញា គួរតែប្រើប្រាស់រយៈពេលប្រាំថ្ងៃ ដែល យើងត្រូវបានប្រគល់ដោយអង្គជំនុំជម្រះ។

យើងដឹងថា ការជំទាស់មួយចំនួនត្រូវបានចាត់ទុកថា មានសុពលភាពផងដែរ ហើយសហ ព្រះរាជអាជ្ញា ក៏បានគិតពិចារណា ទៅលើចំណុចទាំងអស់នេះ។ ដូច្នេះ ដោយពិចារណាទៅលើការគុណ គណនាពេលវេលាបូកដកនោះ គឺយើងខ្ញុំសហព្រះរាជអាជ្ញាសុំសួរដេញដោលសំណួរនេះ រហូតដល់ បញ្ចប់ថ្ងៃព្រហស្បតិ៍តែម្តង ដោយយើងពិចារណាទៅលើរយៈពេលប្រហែលជាពីរម៉ោងម្សិលមិញ ដែល យើងដេញដោលទៅលើបញ្ហានៃការជំទាស់។

លោក លោកស្រីចៅក្រមជាទីគោរព! នៅពេលនេះគឺជិតម៉ោងដប់សាមសិបនាទីរួចទៅហើយ។ ខ្ញុំអាចបន្តសួរសំណួរទៅមុខបានទៀត ឬក៏យើងអាចឈប់សម្រាកសិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ពេលវេលាសមល្មមនឹងសម្រាកហើយ។

សូមអញ្ជើញលោកមេធាវី!

[១០:២៩:៣៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់លើកឡើងថា យើងមិនជំទាស់ការស្នើសុំពេលវេលាបន្ថែមដោយសហព្រះរាជអាជ្ញាសួរដេញដោល ទៅលើសាក្សីរូបនេះនោះទេ។ យើងដឹងហើយថា មិនត្រឹមតែសហព្រះរាជអាជ្ញាទេ ភាគីផ្សេងទៀត គួរតែមានពេលវេលាបន្ថែមសម្រាប់ការដេញដោលទៅលើសាក្សីរូបនេះ។ ហើយភាគីផ្សេង ប្រសិនបើចង់បានអាច គួរតែអាចអនុញ្ញាតដោយអង្គជំនុំជម្រះផងដែរ។ សហព្រះរាជអាជ្ញាមិនគួរធ្វើការចោទប្រកាន់ អំពីភាគីណាដែលបានលើកឡើង ទៅលើបញ្ហានៃការជំទាស់នោះទេ។ សូមអរគុណ។

**លោក វីណ្ស៊ៀម ស្មីត៖**

យើងមិនមែនបន្ទោសទេ អ្វីដែលយើងលើកឡើងនេះ គឺជាការពិតជាក់ស្តែងដែលកើតឡើងនៅទីនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ដោយសារបញ្ហាសុខភាពដដែល លោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់នៅថ្ងៃនេះ។ ប៉ុន្តែសូមចូលរួមសវនាការនេះ ដោយប្រយោលពីបន្ទប់រង់ចាំខាងក្រោម សម្រាប់ថ្ងៃនេះទាំងស្រុងតែម្តង។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណា និងសម្រេច។ សូមអរគុណ។

[១០:៣១:០០]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការ ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ សម្រាប់ពេញមួយថ្ងៃនេះ។ ដោយបញ្ហាមូលហេតុមាន

បញ្ហាសុខភាព ដែលមិនអាចបន្តការអង្គុយតាមដានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះបាន។ អង្គជំនុំជម្រះសម្រេចយល់ព្រម អនុញ្ញាតតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ ក្នុងការលះបង់សិទ្ធិមិនចូលរួមតាមដានកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់ពេញមួយថ្ងៃនៃសវនាការថ្ងៃនេះ។ តែអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី អៀង សារី ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ អៀង សារី ដែលមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃជាក់ច្បាស់ពីលោក អៀង សារី ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់ថ្ងៃនេះ។

[១០:៣២:២១]

ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឲ្យអញ្ជើញលោក កាំង ហ្គេកអ៊ាវ ទៅសម្រាកនៅបន្ទប់សម្រាប់--រៀបចំសម្រាប់ការសម្រាករបស់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះឲ្យបានមុនអង្គជំនុំជម្រះចូលកាន់អាសនៈ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ខាងក្រោម ដែលមានរៀបចំសម្រាប់រូបគាត់។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១០:៥៤ នាទី)*

[១០:៥៤:១៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅភាគី អង្គ

ជំនុំជម្រះសូមឆ្លើយតបទៅនឹងសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានស្នើសុំពេលវេលាក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច។ មួយពេលល្ងាចថ្ងៃស្អែកទៀត ដោយបង្ហាញមូលហេតុនៃការខាតបង់បង់ពេលវេលានៅក្នុងអំឡុងពេលពិភាក្សាដេញដោលរយៈពេលកន្លងមកនេះ។ ហើយមេធាវីការពារក្តី នួន ជា ក៏មិនយល់ទាស់បញ្ហានេះដែរ។ អ៊ីចឹងអង្គជំនុំជម្រះយល់ព្រមផ្តល់ពេលវេលាតាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអំពីការសុំបន្ថែមពេលវេលា។

មុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ-- សូមអញ្ជើញមេធាវីការពារក្តីលោក នួន ជា ដែលឃើញឈរអម្បាញ់មិញនេះ តើលោកមានបំណងចង់និយាយអំពីបញ្ហាអ្វីទៅ? សូមអញ្ជើញ!

[១០:៥៥:៤១]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ជាបឋម ខ្ញុំសូមកែតម្រូវខ្លួនឯងវិញ ខ្ញុំបាននិយាយមុនពេលសម្រាកនោះ ថាខ្ញុំជឿជាក់ថាសេនាធិការត្រូវបានបង្កើត គឺហើយពេលដែលមានការរៀបចំឡើងវិញនូវពាក់កណ្តាលឆ្នាំ១៩៧៦ ប៉ុន្តែតាមពិតសាក្សីបានបញ្ជាក់ពីរឿងនេះ ហើយការពិភាក្សាព្រឹកនេះ គឺថាដូចជាពីល្ងាចម្សិលមិញការពិភាក្សាអំពីឯកសារដែលមិនទាន់មានយថាភាព។ ខ្ញុំសូមពេលបីនាទីដើម្បីជម្រាបជូនតុលាការ។

យើងបានជំទាស់ទៅនឹងយថាភាពនៃឯកសារដែលបង្ហាញកូនក្តីរបស់ខ្ញុំក៏បានបញ្ជាក់បែបនោះដែរ ហើយយើងរង់ចាំសេចក្តីសម្រេច។ ជាពិសេសឯកសារថ្ងៃទី៣០ មីនា ឆ្នាំ៧៦ នេះ។ គឺថាមានឯកសារជាច្រើន ហើយទទួលការអនុញ្ញាតឲ្យជំទាស់នូវឯកសារអំពីតម្លៃភស្តុតាងនៅក្នុងដំណាក់កាលណាមួយនៃនីតិវិធី។ នេះហើយជាពេលសមស្របដែលយើងធ្វើការជំទាស់។ បាទ ជាពិសេសឯកសារមួយដែលបានបង្ហាញនេះឯង។

[១០:៥៦:៥៥]

តាមការជាក់ស្តែងយើងបានដឹងព្រឹកមិញនេះ ហើយពីម្សិលមិញតាមរយៈសាក្សី ហើយគាត់មិនមែនជាបុគ្គលដែលអាចបញ្ជាក់យថាភាពឯកសារនេះបានទេ។ គាត់គ្រាន់តែស្គាល់ ឬមិនស្គាល់ ឬបានឃើញពីមុនតែប៉ុណ្ណោះ។ ហើយយើងមើលក្នុងសំណុំរឿង យើងបានកត់សម្គាល់ឃើញថា ប្រធាន

ឌី.ស៊ី.ខេម គាត់ក៏បានពន្យល់ពីឯកសារ ពីសារៈសំខាន់នៃឯកសារ នៅថ្ងៃទី៦ តុលា។ ខ្ញុំមិនសូវច្បាស់ពីកាលបរិច្ឆេទទេ ប៉ុន្តែគាត់និយាយថាឯកសារ D311/2 សហចៅក្រមស៊ើបអង្កេតបានសួរដេញដោលថាតើឯកសារនោះមកពីណា? ហើយគាត់ឆ្លើយថា ឌី.ស៊ី.ខេម មិនមានឯកសារដើមនៃឯកសារនេះទេប្រហែលថា ប្រហែល ឌី.ស៊ី.ខេម ទទួលបានឯកសារនេះពីលោក ដេវីត ឆេនដ័ល័រ។ ដូច្នេះខ្សែសង្វាក់នោះ គឺថាវាមិនច្បាស់លាស់ ហើយមុនមានឯកសារច្បាប់ដើមនោះទៅទៀត។

ជាអកុសល ឯកសារនេះ គឺត្រូវបានយកមកបង្ហាញសាក្សីឲ្យពិនិត្យមើល ហើយដោយគាត់ឆ្លើយថាមិនបានឃើញពីដើម។ មុននឹងមានការចេញនូវ អ៎!សូមអភ័យទោស! បាទ ខ្ញុំអាចលឿនបន្តិចខ្ញុំនឹងព្យាយាមនិយាយឲ្យយឺតបន្តិច។ ជាអកុសល ដែលថាឯកសារមួយនេះត្រូវបានយកមកបង្ហាញជូនសាក្សីរូបនេះ មុនពេលការចេញសេចក្តីសម្រេចអំពីយថាភាពរបស់វា។

[១០:៥៨:៣៦]

បាទ ប៉ុន្តែខ្ញុំមិនទាន់ជំទាស់នៅពេលនេះទេ ប៉ុន្តែហេតុការណ៍នេះ ឬក៏ឧប្បត្តិហេតុនេះបង្ហាញថាបង្ហាញនូវឲ្យអង្គជំនុំជម្រះពិនិត្យឃើញថា ត្រូវធ្វើសេចក្តីសម្រេចឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ ទៅលើសំណើសុំដែលយើងបានប្តឹងនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០១១ អ៎ ១២ សូមកែតម្រូវ។ ដែលតម្រូវឲ្យមានការពិនិត្យ សូមឲ្យមានការបំភ្លឺអំពីការផ្ទេរ ផ្លាស់ប្តូរ ហើយនិងខ្សែសង្វាក់គ្រប់គ្រងនៃឯកសាររបស់ ឌី.ស៊ី.ខេម ដើម្បី-- ហើយយើងក៏មានសំណើឲ្យអង្គជំនុំជម្រះចេញសេចក្តីបង្គាប់ឲ្យឌី.ស៊ី.ខេម ហើយនិងសហព្រះរាជអាជ្ញានៅផ្តល់ឲ្យយើងខ្ញុំ ហើយនិងភាគីនូវព័ត៌មានដែលមានចែងនៅក្នុងអ្វីៗដែលហៅថាសៀវភៅ 317 ហើយនិង316 នោះផងដែរ នៅក្នុងឯកសាររបស់ ឌី.ស៊ី.ខេម មជ្ឈមណ្ឌលឯកសារកម្ពុជា។ ដែលព័ត៌មាននោះអាចជួយឲ្យយើងខ្ញុំ នឹងយល់បានអំពីខ្សែសង្វាក់នៃការគ្រប់គ្រងឯកសារទាំងអស់នោះ ប្រភពឯកសារទាំងអស់នោះ ហើយនិងយើងអាចនឹងពិនិត្យមើលឯកសារទៅលើថា ឯកសារនោះវាជាឯកសារដើមដែរឬទេ? យើងខ្ញុំស្នើអង្គជំនុំជម្រះឲ្យដោះស្រាយបញ្ហានេះឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីចេញសេចក្តីសម្រេចឲ្យបានឆាប់ ដើម្បីចៀសវាងការពិភាក្សាវែងបន្លាយពេលដោយនៅ បញ្ហានេះរង់ចាំការសម្រេចដដែលពីឯកសារនេះ។ សូមអរគុណលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

សូមអញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន!

[១១:០០:៤៥]

**លោក អាកទួរ វែកគែន៖**

បាទលោកប្រធានគ្រាន់តែចង់រំឭកដល់អង្គជំនុំជម្រះថា មេធាវីការពារលោក ខៀវ សំផន ក៏បានដាក់សំណើមួយដែលមានទិសដៅដូចដែលមេធាវី សហភាតារបស់ខ្ញុំដែលជាមេធាវីរបស់លោក នួន ជា ផងដែរ គឺថាៗឯកសារ E168 ហើយយើងនៅតែចាំចម្លើយអំពីសំណាក់អង្គជំនុំជម្រះដដែល។ ហើយមានប្រធានបទមួយទៀតដែលប្រហាក់ប្រហែលគ្នានេះដែរ ដែលបានលើកឡើងកាលពីម្សិលមិញ ក្នុងការពិភាក្សាលើឯកសាររបស់សហព្រះរាជអាជ្ញា។ ខ្ញុំឆ្លៀតឱកាសនេះ សូមរំឭកថា យើងក៏បាន ដាក់សំណើមួយទៀតដែលសំដៅចង់ឲ្យអង្គជំនុំជម្រះបំភ្លឺលើការដាក់លេខសម្គាល់ E ហ្នឹង តើលេខសម្គាល់ហ្នឹងមានន័យយ៉ាងម៉េច? គឺថាE3 ចំពោះឯកសារដែលយើងប្រើនៅចំពោះមុខតុលាការនេះ។ ម្សិលមិញនៅពេលដែលយើងពិភាក្សាគ្នានោះ សហព្រះរាជអាជ្ញាបានលើកឡើងថា ជាហាក់ដូចជា អំណះអំណាងដែលថាអាចគាំទ្រដល់ការប្រើប្រាស់នូវកំណត់ហេតុ ដែលចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧។

ចំពោះយើង យើងថាមានការពិបាកក្នុងការផ្ដល់លេខសម្គាល់នេះ។ ដូច្នេះសូមឲ្យអង្គជំនុំជម្រះបំភ្លឺដើម្បីឲ្យយើងដឹងច្បាស់ថា តើលេខសម្គាល់ E3 ហ្នឹងមានន័យយ៉ាងម៉េច? កុំឲ្យយើងទាំងអស់គ្នាហ្នឹងខាតពេលវេលាដោយជជែកដែលឥតប្រយោជន៍ទាក់ទងនឹងតម្លៃឯកសារ និងតម្លៃលេខសម្គាល់នៃឯកសារនេះ។

[១១:០២:៤២]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន។

អញ្ជើញមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរអស់លោកទាំងអស់គ្នា ខ្ញុំគ្រាន់តែចង់ថា ជម្រាបថាខ្ញុំភ្ញាក់ផ្អើលណាស់ដែលថាអង្គ--ខាងការពារក្ដីសូមឲ្យយើងបង្កើតពិភាក្សាគ្នាលើការដែលយើងធ្លាប់បានពិភាក្សាគ្នាហើយ ហើយចប់ហើយ។ ហើយសូមឲ្យយើងបើកពិភាក្សាលើបញ្ហាដែលដោះស្រាយរួចហើយ។ សម្រេចរួចហើយ។ ហើយរាល់សវនាការហ្នឹងនិយាយតែរឿងដដែលលើឯកសារនេះ។ គឺថាមួយម៉ោងមុន ឬក៏មួយថ្ងៃមុននេះ

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរួចមកហើយ ហើយយើងទាំងអស់គ្នាក៏ចង់ឲ្យការជម្រះសេចក្តីនេះទៅមុខដែរ ហើយខ្ញុំគិតថាគោលជំហររបស់ភាគីការពារក្តីដែលថា លើកយកមកចោទជាបញ្ហានៅការសម្រេចហើយ រួចហើយនោះ។ ដូច្នេះ គឺថាអង្គជំនុំជម្រះត្រូវតែបញ្ចេញប្រតិកម្មឲ្យរឹងប៉ឹង បើមិនអ៊ីចឹងទេ គឺថាយើងចំណាយពេលរាប់ខែ រាប់ឆ្នាំហ្នឹងវាមិនចេះចប់មិនចេះហើយទេ។

[១១:០៣:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមជម្រាបជូនភាគីជាពិសេសម្ចាស់សំណើបានជ្រាប ហើយនិងបានយល់ថា ដោយចរិតលក្ខណៈនៃសំណុំរឿងក្តីនេះវាមានទំហំធំធេង មានស្ថានភាពស្មុគស្មាញ ហើយឯកសារជាច្រើនដែលទំនងមិនតិចជាង ១លានទំព័រទេ នៅក្នុងសំណុំរឿងក្តីដែលឆ្លងកាត់ការពិភាក្សាអំពីបញ្ហាឯកសារកន្លងមកនេះ។ គ្រាន់តែ ស៊ី.ឌី.ខេម ដែលបានទាក់ទង ទំនាក់ទំនងស្នើសុំភាគីទាំងអស់ដែលពាក់ព័ន្ធគឺមានជាងដល់ទៅ ៥០ម៉ឺនឯកសារទៅហើយ។ ហើយឯកសារពីប្រភពផ្សេងៗ និងការបង្កើតឡើងដោយខ្លួនឯងនេះអង្គភាពដែលពាក់ព័ន្ធក្នុងការចាត់ការរឿងក្តី។

[១១:០៤:៤៦]

បញ្ហាមួយទៀត គឺអង្គជំនុំជម្រះនៅក្នុងអំឡុងពេលទាំងត្រៀមរៀបចំដំណើរការសវនាការ ក៏ដូចជាបាននឹងកំពុងដំណើរការសវនាការ ដោយចរិតលក្ខណៈនៃបញ្ហា នៃសំណុំរឿងវាធំធេង វាស្មុគស្មាញដូច្នេះ ភាគីដទៃទៀតបានដាក់នូវសំណើសុំ បានដាក់នៅបណ្តឹងសុំ បានដាក់នូវ ការទាមទារផ្សេងៗជាច្រើនសន្ធឹកសន្ធាប់។ តែទោះបីជាយ៉ាងនេះក៏ដោយ កន្លងមកអង្គជំនុំជម្រះបានប្រឹងប្រែងដោះស្រាយបញ្ហានេះជាហូរហែ។ ពីព្រោះមិនមែនកំណត់ពេលវេលាដែលមានរយៈពេលដែលមានកាលបរិច្ឆេទជាក់លាក់ ដែលហាមឃាត់ភាគីមិនឲ្យដាក់នូវសំណើសុំ មិនអាចឲ្យប្តឹងសុំនូវបញ្ហាផ្សេងៗនោះឡើយ។

[១១:០៥:៣៥]

ដូច្នេះ នៅក្នុងអំឡុងពេលនៃដំណើរការនេះ អង្គជំនុំជម្រះបានត្រៀម បានរៀបចំនូវ ដោះស្រាយនូវសំណើសុំផ្សេងៗ ទាំងការដោះស្រាយរួច ទាំងបានកំពុងតែពិនិត្យពិភាក្សាដើម្បីត្រៀមរៀបចំដើម្បីដោះស្រាយ។ ប៉ុន្តែបញ្ហាខ្លះមិនអាចដោះស្រាយបានមួយពេល ឬក៏ពីរពេលនេះទេ។ ជាក់ស្តែងនៅសប្តាហ៍មុនអង្គជំនុំជម្រះបានប្រកាសជម្រាបភាគី និងសាធារណជនរួចហើយថា អង្គជំនុំជម្រះ គឺមិនធ្វើសវនាការទេ ដោយសារមូលហេតុបញ្ហាប្រឈមជាច្រើន ដែលត្រូវពិភាក្សា ដោះស្រាយបញ្ហា

នូវការការប្ដឹងសុំ នូវសំណើសុំ នូវបញ្ហាផ្សេងៗទៀត ដែលភាគីបានដាក់មកអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះត្រូវតែធ្វើកិច្ចការនេះ។

អង្គជំនុំជម្រះសង្ឃឹម និងជឿជាក់ថា ភាគីយល់អំពីបញ្ហានេះច្បាស់លាស់ថា មិនទាន់មានសំណើសុំណាមួយ ឬក៏ប្ដឹងទាមទារណាមួយដែលអង្គជំនុំជម្រះមិនលើកយកមកពិចារណា ដោះស្រាយឡើយ។ ដូច្នេះសូមឲ្យភាគីមានការអត់ធ្មត់ ហើយនិង និងទទួលនូវការដោះស្រាយឆ្លើយតបទៅនឹងសំណើសុំ ឬក៏ការប្ដឹងសុំរបស់ភាគីទាំងអស់ក្នុងពេលឆាប់ៗនេះ ទៅកាលវេលា និងទៅតាមចរិតលក្ខណៈនៃបញ្ហាដែលដាក់ចំពោះមុខអង្គជំនុំជម្រះ។

[១១:០៦:៥៥]

ហើយទំនងជាដោយសាររំខាន ឬដោយសារមានការជ្រៀតជ្រែក ជ្រៀតដាក់នូវបញ្ហាផ្សេងៗនៅចំពោះមុខអង្គជំនុំជម្រះដូច្នេះ ទំនងជាសហព្រះរាជអាជ្ញាអាចស្នើសុំពាក្យពេលវេលាបន្ថែមទៀតអាចប្រហែលជាអាចសប្ដាហ៍ អ៊ំ ស្អែកនេះ ទំនងមិនចប់ទេនូវការសួរដេញដោល ដោយសហព្រះរាជអាជ្ញាអំពីបញ្ហាការសួរដេញដោលចំពោះសាក្សីរូបនេះ។

អង្គជំនុំជម្រះសង្ឃឹមថា ភាគីនឹងមិនចំណាយពេលវេលារំខានដល់កិច្ចពិភាក្សាទេ ពីព្រោះអង្គជំនុំជម្រះយល់ច្បាស់អំពីបញ្ហាមុខងារ ភារកិច្ចរបស់ខ្លួនត្រូវដោះស្រាយបញ្ហាអស់ទាំងនោះហើយ។ គ្រាន់តែដូចអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ បញ្ហាវាមានលក្ខណៈស្មុគស្មាញ ហើយនិងវាច្រើនលើសលប់នៃបញ្ហាដែលដាក់ចំពោះមុខខ្លួន។ ហើយត្រូវលៃពេលវេលា ទាំងពេលវេលាសម្រាប់មកដេញដោលតាមកាលបរិច្ឆេទដែលបានកំណត់ទុកផង ក្នុងន័យដើម្បីឲ្យជំរុញល្បឿននៃកិច្ចដំណើរការសវនាការបានឆាប់រហ័ស និងមានប្រសិទ្ធភាពផង ហើយនិងលៃពេលវេលាដើម្បីទៅពិភាក្សា ទៅសិក្សាស្រាវជ្រាវស្វែងយល់ ដើម្បីរកសិក្សាអំពីអង្គហេតុ អង្គច្បាប់ ភស្តុតាងនានា ដូចជាយុត្តិសាស្ត្រអន្តរជាតិជាដើម ដើម្បីដោះស្រាយបញ្ហាឲ្យបានសមស្របបំផុត ឆ្លើយតបទៅនឹងពាក្យប្ដឹងសុំ ឬក៏សំណើសុំរបស់ភាគីពាក់ព័ន្ធ។

[១១:០៨:២៦]

សូមផ្ដល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ បាទ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ក្រោយពីពន្យល់នោះហើយ មិនចាំបាច់ឲ្យខ្ញុំធ្វើការឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើងនោះទេ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុនពេលដែលយើងឈប់សម្រាក មុនពេលដែលយើងពិភាក្សា លោកបានពន្យល់ជូនអង្គសវនាការពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធយោធា រចនាសម្ព័ន្ធកងទ័ពនៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ ក្រោយពីការរៀបចំឡើងវិញ-- ការរៀបចំរចនាសម្ព័ន្ធនេះឡើង ក្រោយពីកម្ពុជា ប្រជាធិបតេយ្យកាន់កាប់អំណាច និងមុនពេលនោះ។ ខ្ញុំមានសំណួរមួយចំនួនចង់សួរលោក នៅក្នុងការ បកប្រែជាភាសាអង់គ្លេស លោកបាន-- ខ្ញុំបានស្តាប់ឮថា កងពល៦៤ ឬក៏លោកនិយាយកងពល១៦៤? សូមឲ្យលោកជួយពន្យល់។

[១១:០៩:៤៥]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** អរគុណ។ ប្រហែលជាខ្ញុំភ្លេចក៏មិនដឹង ពិតមែនទែនកងពល១៦៤ កលពលជើងទឹក។ ហើយសូមបញ្ជាក់បន្ថែមថា ខ្ញុំភ្លេចរាប់កងពលមួយ កងពល៦០៣ ដែលមករំលាយបញ្ចូល ទៅក្នុង ភស្តុភារសេនាធិការ ហើយនិងមួយផ្នែកទៀតបញ្ចូលទៅខាង៥០២ កប៉ាល់ហោះ។

**ស៖** លោកបានលើកឡើងនៅក្នុងសក្ខីកម្មរបស់លោកខាងដើមអំពីកងពល៧០៣។ ដូច្នេះ តើ កងពល៧០៣ហ្នឹង ស្ថិតនៅក្នុងរចនាសម្ព័ន្ធកងទ័ពនេះយ៉ាងម៉េចដែរ តាមអ្វីដែលលោកពន្យល់?

**ឆ៖** កងពល៧០៣ នេះ វាជាកងពលមួយកងរបស់កងទ័ពមជ្ឈិម ដូចកងទ័ពប្រាំពីរកងពល ផ្សេងទៀត។

[១១:១១:១៣]

**ស៖** សូមអរគុណ។ លោកនិយាយអំពីបុគ្គលបីនាក់នៅក្នុងអគ្គសេនាធិការ គឺ សុន សេន, ម៉ែន សាន (យ៉ា), ស៊ាត ឆែ ហៅ ទុំ។ តើ ម៉ែន សាន ហៅ យ៉ា នេះមកពីភូមិភាគណាដែរ?

**ឆ៖** ម៉ែន សាន ហៅ យ៉ា នេះ ខ្ញុំមិនច្បាស់ប្រភពគាត់ទេ។ ក៏ប៉ុន្តែ ក្រោយដែលចូលបម្រើ ការងារក្នុងអគ្គសេនាធិការនេះបានមួយរយៈ ប៉ុន្មានខែទេ ត្រូវផ្លាស់ទៅធ្វើជាលេខាភូមិភាគឦសាន។

**ស៖** តើនរណាគេជំនួស យ៉ា ក្រោយពីគេចាប់ យ៉ា នោះ? តើមាននរណាជំនួស យ៉ា ដែរឬទេ

នៅអគ្គសេនាធិការក្រោយពេលចាប់ខ្លួន យ៉ា?

**ឆ៖** ក្រោយ តាំងពី យ៉ា ចេញទៅធ្វើលេខាភូមិភាគព្រៃសាន ស៊ាត ឆែ ហៅ ទុំ ឡើងជាអនុប្រធានសេនាធិការ។

**ស៖** ក្រៅពីបុគ្គលបីនាក់ដែលលោកបានលើកឡើង តើលោកដឹងថាមាននរណាផ្សេងមកចូលរួមធ្វើការនៅសេនាធិការនេះដែរឬទេ? ឬក៏អត់មានទេ មានតែបីនាក់នេះទេ?

**ឆ៖** មានជំនួយការសេនាធិការ ក្នុងនោះមានពីរនាក់ជាប់លាប់ គឺ សោម ឈ្មោះដើម ពេជ ឆន ហើយនិង ណាត អតីតលេខាស-២១។

[១១:១៣:៥២]

**ស៖** លោកឆ្លើយថា ណាត ត្រូវបានគេចាប់ខ្លួន និងសម្លាប់ចោលនៅស-២១។ ចុះមានអ្វីកើតឡើងចំពោះ ពេជ ឆន?

**ឆ៖** ពេជ ឆន ហៅ សោម ក៏ត្រូវគេចាប់ ហើយនិងកម្ទេចនៅស-២១ ដែរ។

**ស៖** តាមអ្វីដែលលោកដឹង តើមានអ្នកណានៅសល់ក្រៅពី សុន សេន ទេនៅចុងក្រោយនោះ?

**ឆ៖** នៅចុងក្រោយ ក្រៅពីសុន សេន នៅសល់ប្រធានកងពល លេខាកងពល។

[១១:១៥:០០]

**ស៖** តើលោកអាចនិយាយបានដែរឬទេ? តើប្រធានកងពលនោះជួបជុំគ្នារយៈពេលប៉ុន្មានដងដែរ ហើយជាញឹកញយប៉ុនណាដែរ ពួកគេជួបជុំគ្នានោះ?

**ឆ៖** ខ្ញុំគ្រាន់តែអាចបញ្ជាក់បានថា ប្រធានកងពលនីមួយៗមិនអាចជួបគ្នាបានស្រេចនឹងចិត្តទេ។ ទាល់តែមេកោះហៅមកធ្វើការ បានមកធ្វើការតាមមេបញ្ជា។ ហើយខ្ញុំទៅសេនាធិការនុ៎ងដែលមេហៅទៅ ជួនអីជួបពេលដែល ម៉េត ចេញ ឬក៏ជួនអីពេលដែល មិត្តអឿន កងពល៣១០ចេញ។ ឯចំណែក មាស មុត គាត់នៅឆ្ងាយ ខ្ញុំមិនដែលជួបគាត់នៅនឹងកន្លែងនុ៎ងទេ។

**ស៖** សូមអរគុណ។ លោកក៏និយាយអំពីកងវរសេនាធំឯករាជ្យនៅក្នុងជួរកងទ័ព។ តើលោកអាចជម្រាបអង្គជំនុំជម្រះទេ តើកងវរសេនាធំនេះគឺជាអ្វីដែរ?

**ឆ៖** កងវរសេនាធំឯករាជ្យនីមួយៗវាមានភារកិច្ចវាដោយឡែក។ ឧទាហរណ៍ ពេទ្យវាមានភារកិច្ចមួយទៅ ដោយឡែក។ កងជើងទឹកជ្រោយចង្វារវាមានភារកិច្ចរបស់វាមួយ ដោយឡែក។ កងគមនាគមន៍យោធាវាមានភារកិច្ចរបស់វាមួយ ដោយឡែក។ ដូច្នេះទាំងអស់ប្រហែលជាប្រាំពីរ--

ប្រាំមួយ-ប្រាំពីរកងវរសេនាធំឯករាជ្យ រួមទាំងស-២១ ផង។

[១១:១៧:២០]

**ស៖** តើលោកធ្លាប់ចូលរួមប្រជុំជាមួយនឹងមេកងពល ឬក៏បុគ្គលិកមកពីសេនាធិការដែរឬទេ ក្នុងពេលដែលលោកធ្វើការនៅស-២១ នោះ?

**ឆ៖** មានៗ កំណត់ហេតុនៅសល់ ពីរឿងឲ្យស-២១ រង់ចាំទទួលមនុស្សដែលខាងលើ ដែលគណៈកម្មាធិការទូលាយរបស់សេនាធិការ សម្រេចចាប់ខ្សែ ចក្រី ចេញពីកងពល១៧០ និង២៩០។ មានខ្ញុំជួបប្រជុំម្ដង។ កំណត់ហេតុនៅមាន។ ក្រៅពីនោះ បើនិយាយអំពីកិច្ចការបង្កបង្កើនផល ខ្ញុំមិនដែលចូលរួមទេ។ ខាងលើហៅ មិត្តហ៊ុយ ទៅចូលរួម។ កំណត់ហេតុមាន។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបបានដែរឬទេ ថាតើមានព័ត៌មានច្រើនប៉ុនណាដែរ ដែលប្រធានកងពលនោះ បញ្ជូនទៅដល់បុគ្គលិកក្រោមបង្គាប់របស់ពួកគេ?

**ឆ៖** ព័ត៌មានប្រចាំថ្ងៃ ឬប្រចាំអាទិត្យធម្មតាចេះតែមាន ព្រោះភារកិច្ចវាចេះតែទៅមុខ។ ដូច្នេះត្រូវការមេណែនាំ ប៉ុន្តែមុននឹងណែនាំកិច្ចការអី មេតែងតែឧទ្ទេសនាមសភាពការណ៍រួមឲ្យកូនចៅដឹងខ្លះខានមិនខាន ដើម្បីជំរុញការធ្វើការងារឲ្យបានសកម្មគ្រប់តែគ្នាអ៊ីចឹង។

[១១:១៩:៤០]

**ស៖** នៅពេលដែលលោកមើលបញ្ជីអ្នកទោស លោកបានឯកភាពទៅនឹងចំនួនអ្នកទោសដែលបានកត់ត្រាចូលស-២១។ ខ្ញុំមិននិយាយអំពីអ្នកទោសដែលមិនបានកត់ត្រានោះទេ។ ក្នុងចំណោមអ្នកទោសជាង១២.០០០នាក់ មានអ្នកទោសជាង៥.០០០នាក់ ត្រូវចាប់មកពីជួរកងទ័ពបដិវត្តន៍កម្ពុជា។ ដូច្នេះតាមការយល់របស់លោកចំនួនអ្នកទោសនៅស-២១ នោះ គឺជាង៥.០០០នាក់ ចាប់មកពីជួរកងទ័ពបដិវត្តន៍កម្ពុជា តើត្រឹមត្រូវដែរឬទេ? ហើយត្រឹមត្រូវនឹងអ្វីដែលលោកបានចងចាំចំពោះអ្នកទោសដែលចាប់ចូលស-២១ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចងចាំទេ ក៏ប៉ុន្តែខ្ញុំជឿសេចក្ដីសរុបនេះទាំងស្រុង អត់ប្រកែក។

**ស៖** ប្រហែលជាយើងអាចកុំសួរ អំពីតើលោកចងចាំឬ មិនចងចាំ។ ថាតើមានជួរកងទ័ព-- សមាជិកជួរកងទ័ពត្រូវបានចាប់មកចូលស-២១ ដែរឬទេ?

**ឆ៖** មាន! ពិតជាមាន។

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជាសមាជិកក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជានោះ ចំនួនច្រើន

ណាស់ត្រូវបានគេចាប់ចូលក្នុងស-២១ ហើយសម្លាប់ចោល?

**ធ៖** ដោយមូលហេតុចោទថា "ក្បត់បក្ស"។

**ស៖** សូមអរគុណ។ លោកបាននិយាយថា មេកងពលរាយការណ៍ទៅអគ្គសេនាធិការ។ ចុះអគ្គសេនាធិការ តើរាយការណ៍ឡើងទៅណា ប្រសិនបើគាត់ត្រូវរាយការណ៍នោះ?

**ធ៖** អគ្គសេនាធិការ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្ស គឺត្រូវរាយការណ៍ទៅប៉ុល ពត និង នួន ជា។

**ស៖** តើមានគណៈកម្មាធិការកងទ័ពនៅក្នុងគណៈកម្មាធិការមជ្ឈិមដែរឬទេ?

**ធ៖** បញ្ហានេះ យើងឃើញឯកសារថ្ងៃ០៩ តុលា ១៩៧៥ សរសេរថា លេខាទទួលរួម យោធា និងសេដ្ឋកិច្ច។ អនុលេខាទទួលការងារបក្ស។ ក៏ប៉ុន្តែបើនិយាយអំពីគណៈកម្មាធិការយោធាមជ្ឈិមបក្ស អាហ្នឹងវាបញ្ហាមួយផ្សេងទៀត។

**ស៖** សូមអរគុណ។ លោកបានជម្រាបខាងដើមថា មុនពេលរៀបចំរចនាសម្ព័ន្ធកងទ័ពសាជាថ្មី ជួរកងទ័ពស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនីមួយៗ។ ក្នុងអំឡុងពេលនោះ រហូតមកដល់រដ្ឋប្រហារក្នុងសម័យ លន់ នល់ និងរហូតមកដល់ខែមេសា ឆ្នាំ៧៥។ តើជួរកងទ័ពបដិវត្តន៍កម្ពុជានោះ គេដាក់ឈ្មោះអ្វី ក្នុងចន្លោះឆ្នាំ៧០ ទៅដល់ឆ្នាំ៧៥ តាមអ្វីដែលលោកដឹង?

[១១:២៥:១២]

**ធ៖** សូមញែកបញ្ហានេះជាពីរ។ ក្រោយពីកំណើតរណសិរ្សរួមរួបជាតិកម្ពុជា ថ្ងៃ២៣ ខែមីនា ១៩៧០ ក៏មានកំណើតកងទ័ពមួយ ដែលគេដាក់ឈ្មោះជាចំហលើផ្ទៃអន្តរជាតិ។ ជាពិសេសក្នុងជាតិគ្មានឥទ្ធិពលអីទេ។ គេដាក់ថា កងកម្លាំងប្រដាប់អាវុធរណសិរ្សរំដោះជាតិកម្ពុជា-- អ៎ "រណសិរ្សរួបរួមជាតិកម្ពុជា" នេះឈ្មោះគេអ៊ីចឹង។ ក៏ប៉ុន្តែក្នុងអនុវត្តជាក់ស្តែង យើងខ្ញុំធ្លាប់ឮថា កងឈ្លបឃុំ កងទ័ពស្រុក កងទ័ពតំបន់ ហើយនិងកងទ័ពភាគ។ ព្រោះភូមិភាគនីមួយៗកសាងកងទ័ពរបស់ខ្លួន ក្រោយការគ្រប់គ្រង និងដឹកនាំផ្តាច់មុខរបស់បក្ស។ នេះគឺបញ្ហាវាមានពីរអ៊ីចឹង។

**ស៖** កងទ័ពគឺលោកបានរៀបរាប់ហើយ គឺស្ថិតនៅក្រោយការគ្រប់គ្រងរបស់ភូមិភាគ ថាតើមានកងពលណាមួយដែលស្ថិតនៅក្រោយការគ្រប់គ្រងផ្តាច់មុខនៅក្នុងជួរកងទ័ពក្នុងភូមិភាគដែរឬទេ?

**ធ៖** ខ្ញុំមិនយល់ពីសំណួរនេះទេ។

**ស៖** តើលោកឮកងកម្លាំងប្រដាប់អាវុធរំដោះប្រជា-- កងកម្លាំងប្រដាប់អាវុធរួបរួមជាតិកម្ពុជា

តើលោកធ្លាប់ឮឈ្មោះហ្នឹងពីមុនមកដែរឬទេ? បាទ កងទ័ពប្រជាជនរំដោះជាតិកម្ពុជា។ តើលោកធ្លាប់ឮឈ្មោះហ្នឹងពីមុនដែរឬទេ?

**ឆ៖** ខ្ញុំមិនឮទេ។ ឮតែកងកម្លាំងប្រដាប់អាវុធរណសិរ្សរួបរួមជាតិកម្ពុជា។ នេះ បើតាមខ្ញុំចាំ។ ឈ្មោះនេះផ្សាយតាមវិទ្យុ។

[១១:២៨:១៥]

**ស៖** ថាតើមានបុគ្គលណាម្នាក់ជាអ្នកគ្រប់គ្រងទៅលើជួរកងទ័ពពីចន្លោះរហូតមកដល់ឆ្នាំ៧៥ ដែរឬទេ? មានបុគ្គលណាម្នាក់ជាអ្នកគ្រប់គ្រងរួមដែរឬទេ ដល់ឆ្នាំ៧៥?

**ឆ៖** ខ្ញុំសូមបញ្ជាក់ថា លក្ខន្តិកៈបក្សឆ្នាំ១៩៧១ សរសេរថា “កងទ័ពគឺជាកូនបង្កើតដ៏ជំនិតរបស់បក្ស”។ ដូច្នេះ កងទ័ពស្ថិតនៅក្រោមការគ្រប់គ្រង ចាត់ចែងផ្តាច់មុខដាច់ខាតរបស់លេខា និង អនុលេខាបក្ស។

**ស៖** លោកបានផ្តល់សក្ខីកម្មនាពេលមុនថា លោកបានធ្លាប់ឮឈ្មោះ ខៀវ សំផន នៅមុនឆ្នាំ៧៥ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[១១:២៩:៥៣]

**ស៖** តើនៅពេលណាដែលជាលើកដំបូងលោកស្តាប់ឮឈ្មោះ ខៀវ សំផន នេះ?

**ឆ៖** ខ្ញុំឮឈ្មោះ ខៀវ សំផន យូរហើយ។ ប្រសិនបើសិនឱ្យខ្ញុំនិយាយវែងបន្តិច។ នៅឆ្នាំ១៩៥៨ ខ្ញុំក្មេងៗ គេកែនខ្ញុំឱ្យទៅធ្វើបាតុកម្មប្រឆាំង ឡាបស៊ែវ៉ាទ័រ របស់ ខៀវ សំផន។ ធ្វើបាតុកម្មនៅសាលាខេត្តកំពង់ធំ។ ដល់ក្រោយមក រឿងល្បីល្បាញរឿង ខៀវ សំផន អីណាផ្សេងទៀត អាហ្នឹងខ្ញុំសូមនិយាយកាត់ទៅចុះ។ ដល់ឆ្នាំ ១៩៦៧ ខៀវ សំផន បាត់ខ្លួនពីរនាក់ ហ៊ូ យន់ ដល់ក្រោយមកបាន ហ៊ូ នឹម ចេញរួច។ ជនចម្រើនទាំងអស់ ជាពិសេស ដែល-- ខ្ញុំហៅថាអនុធននោះ គិតថា ខៀវ សំផន គឺជាកូនសិស្សដែល ប៉ុល ពត បង្រៀន។ នៅពេលដែលចូលទៅនៅជាមួយ ប៉ុល ពត ខ្ញុំបានទទួលដំណឹងជាពិសេសពួកបញ្ញាជនដូចគ្នាហ្នឹង ថា ខៀវ សំផន ទៅទទួលភារកិច្ចពិតប្រាកដជាប្រធានមន្ទីរមជ្ឈិម ឯចំណែកភារកិច្ចផ្សេងទៀត ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយនិងជាអគ្គបញ្ជាការកងកម្លាំងប្រដាប់អាវុធប្រជាជន អ៎សូមទោស! កងកម្លាំងប្រដាប់អាវុធរណសិរ្សរួបរួមជាតិកម្ពុជាអីនុំង ជាភារកិច្ចឧបកិច្ចទេ គ្មានតួនាទី ខៀវ សំផន ទេ អត់ចេះបញ្ជាទ័ពទេ មនុស្សនេះ។ នេះ

ខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

[១១:៣១:៥៦]

**ស៖** ដូច្នេះលោក ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រីនៃរាជ-- បាទរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តើត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** តើលោកដឹងថាបែបនេះ ដោយវិធីណា?

**ឆ៖** តាមខ្ញុំចាំគឺវិទ្យុផ្សាយឲ្យដឹងមុនគេ។

**ស៖** ថាតើរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានោះគឺត្រូវបានបង្កើតឡើងនៅពេលណាដែរ?

**ឆ៖** ថ្ងៃខែពិតប្រាកដខ្ញុំមិនច្បាស់ទេ អាចក្រោយរណសិរ្សរួបរួមជាតិកម្ពុជាក៏ថាបាន ឬអាចដំណាលគ្នាក៏ថាបាន។ ខ្ញុំមិនច្បាស់ទេ។

**ស៖** តើលោកថា និយាយពីកាលបរិច្ឆេទដែលលោកដឹងហ្នឹង គឺថារណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងត្រូវបានបង្កើតឡើងតាមដែលលោកចាំហ្នឹងក្នុងកាលបរិច្ឆេទណាដែរ?

[១១:៣៣:៣៦]

**ឆ៖** តាមខ្ញុំៗចាំ កម្មវិធីនយោបាយរណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងផ្សាយពីក្រុងប៉េកាំងមកនៅថ្ងៃ២៣ ខែមីនា ១៩៧០។

**ស៖** សូមអរគុណ។ នៅពេលដែលលោកបានឮពីឈ្មោះលោក ខៀវ សំផន ដំបូងគឺឆ្នាំ១៩៥៨ តើតួនាទីរបស់គាត់កាលណោះធ្វើអ្វី? តើសកម្មភាពគាត់ៗធ្វើខ្លះកាលណោះនោះ?

**ឆ៖** កាលណោះខាងសាលាខេត្ត គេហៅកូនសិស្សឲ្យទៅធ្វើបាតុកម្មប្រឆាំង ឡុប ស៊េរ៉ាទ័រ ទាមទារឲ្យបិទ ឡុបស៊េរ៉ាទ័រ។ ហើយ ឡុបស៊េរ៉ាទ័រ ហ្នឹងមាន ខៀវ សំផន ជាចាងហ្វាងកាសែតហ្នឹង។ ដូច្នេះគាត់ធ្វើស្អី ខ្ញុំមិនច្បាស់ អត់មានឯកសារច្បាស់លាស់។

**ស៖** ថាតើលោកស្គាល់ឈ្មោះកាសែតហ្នឹងច្បាស់ទេ កាលពីនោះ?

**ឆ៖** ឈ្មោះកាសែតហ្នឹងខ្ញុំឮនៅពេលធ្វើបាតុកម្មហ្នឹងតែម្តង។ ឡុបស៊េរ៉ាទ័រ គឺជាពាក្យបារាំងឡុបស៊េរ៉ាទ័រ។

**ស៖** តើលោកដឹងអ្វីបន្ថែមហ្នឹងទេ ក្រោយពីឆ្នាំ១៩៥៨ ហើយនិង៦៧ តើសកម្មភាពរបស់គាត់ការងាររបស់គាត់អ្វីខ្លះ ក្រៅពីដឹងថាគាត់ជានាយកកាសែតនោះ?

**ឆ៖** ឆ្នាំខ្ញុំមិនចាំទេ។ ខៀវ សំផន ត្រូវ គូ រុន មេគិញវ៉ៃសម្រាតនៅក្បែរកុង្សីយ៍ លឹម គ្រី ល្បី ដូចជាក្នុងឆ្នាំ១៩៦១ ឬ៦២ នេះបើតាមខ្ញុំចាំ។

[១១:៣៦:៤៥]

**ស៖** នៅពេលដែលលោកបានឮការប្រកាសក្រោយឆ្នាំ១៩៧០ ថា ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ថាតើលោកដឹងថាគាត់មានតួនាទីអ្វីទេនៅក្នុងចលនាបដិវត្តចន្លោះឆ្នាំ១៩៧០ដល់១៩៧៥ ថាតើមានមុខងារឬក៏តួនាទីអ្វីផ្សេងទៀតខុសពីហ្នឹងទេ របស់លោក ខៀវ សំផន នោះ?

**ឆ៖** យើងខ្ញុំទាំងអស់គ្នាជាអនុធនទេ មនុស្សដែលយើងខ្ញុំចាប់អារម្មណ៍តាមដានជាងគេ គឺបុគ្គលម្នាក់ហ្នឹងឯង គឺ ខៀវ សំផន។ តួនាទីពិតប្រាកដដែលគាត់ធ្វើសកម្មភាព គឺប្រធានមន្ទីររបស់ ប៉ុល ពត។ ទាំងអស់គ្នាគឺយល់ថា ខៀវ សំផន ជាកូនសិស្សរបស់ ប៉ុល ពត។ ប៉ុល ពត បង្រៀនសព្វកិច្ចការនេះយើងខ្ញុំដឹងប៉ុណ្ណឹង។ ឯចំណែកតួនាទីជាឧបនាយករដ្ឋមន្ត្រី ជាអគ្គបញ្ជាការអីហ្នឹង គេហៅតួនាទីឧបកិច្ច។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

[១១:៣៨:០៦]

**ស៖** នៅពេលដែលលោកនិយាយថា លោក ខៀវ សំផន ជាសិស្សរបស់ ប៉ុល ពត នោះ តើគឺជាអ្វីៗដែលលោកដឹងបែបនោះក្រោយឆ្នាំ១៩៧០ ឬទេ?

**ឆ៖** ខ្ញុំដឹងក្រោយឆ្នាំ១៩៧០ មុននោះអត់ដឹងរឿងនេះទេ។

**ស៖** នៅពេលដែលលោកនិយាយថា គាត់ជាសិស្សរបស់ ប៉ុល ពត តើលោកអាចពន្យល់បានទេថាតើទំនាក់ទំនងរវាងគាត់ទាំងពីរហ្នឹងជាសិស្ស និងគ្រូដូចជានៅក្នុងថ្នាក់ ឬក៏ជាទំនាក់ទំនងការងារបែបណា? សូមលោកពន្យល់អង្គជំនុំជម្រះផង។

[១១:៣៩:០៣]

**ឆ៖** ខ្ញុំបានដឹងថា គាត់ជាសិស្សរបស់ ប៉ុល ពត គាត់គោរព ប៉ុល ពត ដោយសារខ្ញុំសួរ តូច ភឿន។ តូច ភឿន ឆ្លើយអ៊ីចឹងថា បងហែម គោរព បងប៉ុល ខ្លាំងណាស់ជាមនុស្សនៅក្នុងបន្ទប់ដូចកូនក្រមុំ។ នេះ តូច ភឿន និយាយអ៊ីចឹង។

**ស៖** ហើយ បងហែម គឺជាឈ្មោះបដិវត្តន៍របស់ ខៀវ សំផន មែនឬទេ?

**ឆ៖** ត្រឹមត្រូវ!

**ស៖** ថាតើលោកបានទទួលព័ត៌មាននេះពី តួច ភឿន ហ្នឹងនៅពេលណាដែលថា ខៀវ សំផន គោរព ប៉ុល ពត ណាស់? ថាតើលោកសន្ទនាជាមួយគាត់ហ្នឹងនៅពេលណាដែលបានដឹងព័ត៌មានហ្នឹង?

**ឆ៖** ខ្ញុំសន្ទនានេះ នៅពេលដែល តួច ភឿន ចូលទៅដល់ ស-២១ ហើយ។ នៅពេលដែលគាត់ឆ្លើយចប់ ហើយគេទុក។ ខ្ញុំឲ្យគេបំប៉នអីស្រួលបួលទៅ ដល់ពេលមួយនោះខ្ញុំទៅអង្គុយនិយាយលេងជាមួយនឹង តួច ភឿន។ សូមបញ្ជាក់ថា តួច ភឿន ហើយនិងខ្ញុំ មានកំណើតនៅកំពង់ធំដូចគ្នា។

**ស៖** សូមអរគុណ។ លោកបាននិយាយថា ខៀវ សំផន គឺជាប្រធានមន្ទីរមជ្ឈិម ឬក៏គាត់ជាឧបនាយករដ្ឋមន្ត្រីរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ថាតើមុនឆ្នាំ១៩៧៥ ឬក៏ក្រោយឆ្នាំ១៩៧៥ បាទ?

**ឆ៖** តួនាទីនេះខ្ញុំឮតាំងពីមុនឆ្នាំ១៩៧៥។

**ស៖** នៅពេលលោកនិយាយថា ប្រធានមន្ទីរមជ្ឈិមនោះ គឺប្រធានមន្ទីរមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏មន្ទីរ របស់មន្ទីរណា?

[១១:៤១:៥៥]

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា គឺមន្ទីរមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា។

**ស៖** តើលោកបានឮដែរឬទេ នៅពេលដែលខៀវ សំផន បានក្លាយទៅជាសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកពេញសិទ្ធិ ឬក៏ជាសមាជិកត្រៀម? ប្រសិនជាលោកដឹង លោកប្រាប់ថាដឹង បើមិនដឹង លោកថាមិនអាចបាទ។

**ឆ៖** ខ្ញុំដឹងដោយសារកំណត់ហេតុសួរចម្លើយរបស់ ខៀវ សំផន ឆ្លើយចំពោះសហចៅក្រមស៊ើបអង្កេត។

**ស៖** សក្ខីកម្មដែលខ្ញុំចង់ឲ្យលោកសង្កេតនោះគឺថា តាមការយល់ដឹងរបស់លោក គឺថាដែលលោកទទួលបានព័ត៌មានពីកន្លែងផ្សេង គឺថាយើងអរគុណ ដែលលោកបានទទួលព័ត៌មានពីឯកសារផ្សេង ដឹងតាមឯកសារផ្សេងនោះ។ ក្រៅពីឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា លោកបាននិយាយពីខាងដើមថា គាត់មានតួនាទីនៅក្នុងក្រសួងខាងផ្នែកការពារជាតិ។ ប៉ុន្តែមិនសកម្មណាស់ណាទេ តើលោកអាចបញ្ជាក់បន្ថែមបានទេ? តើលោកចង់និយាយដូចម្តេចឃ្លានោះ?

**ឆ៖** តួនាទី ខៀវ សំផន ជាអគ្គបញ្ជាការ។ ខ្ញុំបានបញ្ជាក់ថា ជាតួនាទីឧបកិច្ច បានន័យថាមានតែឈ្មោះទេ។ មានតែឈ្មោះទេ តាមពិតគាត់អត់ចេះបញ្ជាទ័ពផង ហើយគ្មានកងទ័ពសម្រាប់បញ្ជាទេ។ កងទ័ពទាំងអស់ជាកងទ័ព ប៉ុល ពត។

[១១:៤៤:២០]

**ស៖** ដូច្នេះ សក្ខីកម្មដែលលោកបានឮថា ខៀវ សំផន ជាអគ្គបញ្ជាការនៃកងកម្លាំងបដិវត្តន៍ រវាងឆ្នាំ១៩៧០ និង១៩៧៥ នោះ តើហ្នឹងជាសម្ដីសក្ខីកម្មរបស់លោកដែរឬទេ?

**ផ៖** ខៀវ សំផន ជាអគ្គបញ្ជាការ នេះជាសម្ដីខ្ញុំ! ប៉ុន្តែបញ្ជាការនេះមានតែឈ្មោះទេ អត់សកម្មភាព មិនមែននេះទេ គឺគ្មានសកម្មភាព គ្មានន័យអីទាំងអស់ គ្រាន់តែដាក់ដើម្បីឲ្យអន្តរជាតិគេដឹងឮទទួលស្គាល់ប៉ុននុ៎ង។

**ស៖** តើគ្រាន់តែឲ្យអន្តរជាតិជាប្រទេសមិត្តភក្តិស្គាល់ចលនាហ្នឹង តើហ្នឹងជាសក្ខីកម្មរបស់លោកមានន័យអីចឹងបាទ?

**ផ៖** ត្រឹមត្រូវ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាហេតុអ្វីបានជា ខៀវ សំផន ត្រូវបានគេជ្រើសតាំងឲ្យកាន់តំណែងហ្នឹង ដើម្បីឲ្យៗសហគមន៍អន្តរជាតិទទួលស្គាល់នូវចលនារបស់សម័យនោះបាទ?

**ផ៖** ខ្ញុំសូមបញ្ជាក់ថា ក្នុងជាតិ និងអន្តរជាតិ គេជឿទុកចិត្ត ខៀវ សំផន។ សីហនុ ខ្លួនឯងក៏ជឿទុកចិត្ត ខៀវ សំផន ហៅ ខៀវ សំផន សុទ្ធតែព្រះពុទ្ធ ជាមនុស្សដែលស្អាតស្អំបំផុត។ នេះហើយដែល ប៉ុល ពត យកឈ្មោះ ខៀវ សំផន ទៅប្រើ។ ហើយ សីហនុ ខ្លួនឯង បើរុញឈ្មោះហ្នឹងទៅគាត់មិនប្រកែកទេ។

[១១:៤៦:៤២]

**ស៖** ថាតើលោកដឹងដោយរបៀបណា ថា ខៀវ សំផន នោះគាត់ជាអគ្គបញ្ជាការកងទ័ពរបស់កងទ័ពបដិវត្តន៍កម្ពុជា? ថាតើលោកដឹងដោយរបៀបម៉េច ថាគាត់មានតួនាទីជាឧបកិច្ចនោះ ថាមិនមានតួនាទីប្រាកដនោះ តើដឹងដោយរបៀបណា?

**ផ៖** ឈ្មោះ ខៀវ សំផន ដូចបោះនៅក្នុងទស្សនាវដ្ដី ចែកក្នុងផ្ទៃក្នុងបក្ស-- អ៎ន៎ៃ ចែកនៅក្នុងតំបន់រំដោះ។ ឈ្មោះគណៈកម្មាធិការអគ្គបញ្ជាការ-- គណៈកម្មាធិការយោធាជាន់ខ្ពស់របស់កងទ័ពប្រជាជន-- មើលសូមទោស! កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជានោះ។ គេដាក់ឈ្មោះ ខៀវ សំផន ប្រធាន ហើយបានអ្នកណាទៀតទេ បានចុងបំផុតដាក់ថា សាឡុត ស សមាជិក។ លួចចេញឈ្មោះ សាឡុត ស មួយម៉ាត់នៅនុ៎ង។ នេះដែលយើងខ្ញុំសង្កេតឃើញ ហើយចងចាំទុកមក។ ឯចំណែកពាក្យដែល ខៀវ សំផន ជាអគ្គបញ្ជាឧបកិច្ចនេះ អ្វី! ដូចជាមិនកំបាំងទេ អ្នកណាក៏គេជឿ អ្នកណាក៏គេយល់

ព្រោះមនុស្សនេះមិនដែលបានចេះទាហានទេ។

[១១:៤៨:១៥]

**ស៖** សូមអរគុណ។ ប៉ុន្តែទាក់ទងទៅនឹងតួនាទីជាក់លាក់ និងជាមួយនឹងកងទ័ពនោះគឺថា ជាតួនាទីខាងនយោបាយ ដើម្បីផ្សាភ្ជាប់ទៅនឹងសហគមន៍អន្តរជាតិដែរឬទេ? បាទ តើលោកអាចនិយាយបានដូចម្ដេច?

**លោក ម៉ៃខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរនេះ ព្រោះមានការជំទាស់ពីមេធាវី។

បាទ សូមអញ្ជើញលោកមេធាវី!

[១១:៤៨:៤៣]

**លោក ម៉ៃខល កាណាវាស៖**

សូមភ័យទោសលោកប្រធាន ខ្ញុំសូមរំខាន។ គឺថាសំណួរនេះ គឺទាក់ទងទៅនឹងជនជាប់ចោទមួយទៀត។ ប៉ុន្តែយើងមានការណែនាំរំឭកគាត់ ហើយសហព្រះរាជអាជ្ញាបានសួរសំណួរដឹកមុខ នាំមុខនេះហើយជាសំណួរ។ ជាពិសេសជាសំណួរនាំមុខ គាត់បង្ហាញព័ត៌មាន ហើយគាត់បង្ខិលព័ត៌មាន ហើយគាត់ៗផ្ដល់ព័ត៌មានទៅឱ្យសាក្សី។ ហើយនេះខ្ញុំអាចធ្វើការជំទាស់ គ្រាន់តែសួរសំណួរធម្មតាទៅបានហើយ។ បើគាត់សម្រួលឃ្លា ហើយគាត់ដាក់ព័ត៌មានក្នុងនុ៎ង ហើយសួរទៅសាក្សី ហើយខ្ញុំឃើញថា មិនមានសារប្រយោជន៍សម្រាប់អង្គជំនុំជម្រះទេ។ ខ្ញុំពិនិត្យឃើញថា ការធ្វើបែបនេះ គឺថាចៅក្រមប្រកបដោយវិជ្ជាជីវៈ គឺថាតែងតែបញ្ឈប់ គឺថា គឺអាចនឹងយល់ថា ជាស្ថានភាពគ្រោះថ្នាក់ ប្រសិនបើឱ្យសហព្រះរាជអាជ្ញាបន្តពិនិត្យមើលព័ត៌មាន ហើយព្រះរាជអាជ្ញាបានផ្ដល់ព័ត៌មាន ហើយទទួលពីព្រះរាជអាជ្ញា សាក្សីឆ្លើយទៅតាមហ្នឹង។

[១១:៤៩:៤៦]

ដូច្នេះអង្គជំនុំជម្រះគ្រប់គ្រង ឬក៏ថាណែនាំសហព្រះរាជអាជ្ញា កុំឱ្យសួរសំណួរនៅក្នុងរបៀបមួយដែលដូចគាត់បានសួរអម្បាញ់មិញនេះ។ គាត់-- សុំឱ្យគាត់សួរសំណួរធម្មតាវិញ។ គាត់មិនចាំបាច់នាំមុខផ្ដល់ព័ត៌មាន ហើយឱ្យសាក្សីឆ្លើយនោះទេ។ បើធ្វើក្នុងករណីណាមួយដែលប្រកបដោយគតិបណ្ឌិត

នោះទើបបានត្រឹមត្រូវបាទ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីណ្ណៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សាក្សីបានផ្តល់ព័ត៌មានឲ្យយើងបែបនេះ ហើយយើងគ្រាន់តែព្យាយាមពន្យល់អំពីលក្ខណៈ ហើយនិងតួនាទីរបស់គាត់។ សាក្សីបានបញ្ជាក់ថា ខៀវ សំផន ត្រូវបានគេប្រើឲ្យធ្វើក្នុងតំណែងហ្នឹង ដើម្បីណែនាំចលនាឲ្យសហគមន៍អន្តរជាតិទទួលស្គាល់។ តើមែនឬទេសាក្សី?

[១១:៥០:៥២]

**ប្រធានអង្គជំនុំ៖**

កុំៗទាន់អាលឆ្លើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥១:៤៩]

សេចក្តីជំទាស់របស់ក្រុមមេធាវីការពារក្តី អៀង សារី លើរបៀបសួរសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃើញថាមានប្រសិទ្ធភាព។ ដូច្នេះសំណួរដែលមានលក្ខណៈនាំមុខ គឺអង្គជំនុំជម្រះរំឭកឡើងវិញថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យសួរទេ ហើយអង្គជំនុំជម្រះបានរំឭករួចហើយថា ការតាំងសំណួរសូមប្រយ័ត្នប្រយែង ដើម្បីជៀសឲ្យផុតពីការតាំងសំណួរ ដែលច្បាប់បានហាម។

ដូច្នេះ សំណួរអម្បាញ់មិញនេះ សូមមិនបាច់ឲ្យសាក្សីឆ្លើយតបទេ លើកលែងតែសហព្រះរាជអាជ្ញាមានការកែសម្រួលសំណួរ ដែលត្រឹមត្រូវ ដែលមិនមានលក្ខណៈជាសំណួរនាំមុខ។

**លោក វីណ្ណៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក វីណ្ណៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកដឹងដោយវិធីណា ដែលថាគាត់ជាអ្នកណែនាំចលនាបដិវត្តន៍ឲ្យអន្តរជាតិគេស្គាល់នោះ? តើលោកដឹងដោយរបៀបណា?

[១១:៥៣:១៩]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ការងាររបស់គាត់ យើងខ្ញុំដឹង ថាជាប្រធានមន្ទីររបស់ ប៉ុល ពត ជាកូនសិស្សដែល ប៉ុល ពត បង្រៀន។ សមត្ថភាពរបស់ខ្លួនគាត់ យើងខ្ញុំជាអនុធន ដែលមានចិត្តស្រលាញ់គាត់នោះ ជឿថាគាត់មិនចេះច្បាំង។ ហើយឥទ្ធិពលរបស់គាត់ក្នុងជាតិ និងក្នុងអន្តរជាតិ យើងខ្ញុំដឹងថា ជាតិ និងអន្តរជាតិ គេជឿជាក់ថា គាត់ជាមនុស្សស្អាតស្អំ ត្រឹមត្រូវ។ ដូច្នេះ លើកគាត់ឡើងធ្វើជាឧបនាយករដ្ឋមន្ត្រី លើកគាត់ឡើងធ្វើជាអគ្គបញ្ជាការនៃកងទ័ព គ្រាន់តែដើម្បីឲ្យគេជឿទុកចិត្តថា កងទ័ពនេះវាមានមេបញ្ជាការមួយស្អាតស្អំ ត្រឹមត្រូវ មានការភ្ញាក់រឭកនយោបាយខ្ពស់។ នេះគឺ យើងខ្ញុំដឹងអ៊ីចឹង អ្នកណាក៏ថាអ៊ីចឹង។ បើលើក-- គាត់មិនចេះច្បាំងផង ហើយទៅលើកឈ្មោះគាត់មិន-- ឲ្យយើងខ្ញុំថាម៉េច? គឺទាល់តែយើងខ្ញុំ-- អ្នកណាក៏ដោយ គេមើលឃើញតែម្តង ថាលើកនេះដើម្បីគ្រាន់តែឲ្យគេជឿថា កងទ័ពនេះមានមេបញ្ជាការមួយត្រឹមត្រូវ ស្អាតស្អំ។

[១១:៥៤:៤៦]

**ស៖** តើលោកដឹងថា តួនាទីរបស់លោក ខៀវ សំផន ច្បាស់លាស់នោះ ជាក់លាក់ហ្នឹងទាក់ទងទៅនឹងបក្សកុម្មុយនីស្តកម្ពុជា តើគាត់មានតួនាទីអ្វីទេរវាងឆ្នាំ១៩៧០ ដល់១៩៧៥នោះ?

**ឆ៖** តួនាទីរបស់គាត់ គឺប្រធានមន្ទីរមជ្ឈិម។

**ស៖** នៅពេលដែលលោកនិយាយថាប្រធានមន្ទីរមជ្ឈិមហ្នឹង គឺមុនឆ្នាំ១៩៧៥ ឬក៏ក្រោយឆ្នាំ១៩៧៥?

**ឆ៖** មុនឆ្នាំ១៩៧៥។

**ស៖** នៅពេលដែលលោកនិយាយថាមន្ទីរមជ្ឈិមនោះ គឺថាមន្ទីរមជ្ឈិមរបស់ស្ថាប័នណា? របស់អ្វីបាទ?

**ឆ៖** សំណួរនេះព្រះរាជអាជ្ញាសួរខ្ញុំម្តងហើយ គឺរបស់បក្សកុម្មុយនីស្តកម្ពុជា។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំចង់បាទចង់កត់សម្គាល់ដូចសាក្សីមានប្រសាសន៍អំមិញហ្នឹងថា តំណាងសហព្រះរាជអាជ្ញាសួរសំណួរដដែលៗច្រើនដងបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តសំណួរ ហើយសូមមានការប្រុងប្រយ័ត្ន ពីព្រោះសំណួរច្រំដែលក៏ជាសំណួរដែលច្បាប់ហាមដែរ។ ក្នុងភាគីដែលពាក់ព័ន្ធនៅក្នុងដំណើរការក្ដីទូទៅ ទាំងជាតិ និងអន្តរជាតិ គឺហាមឃាត់មិនឲ្យតាំងសំណួរច្រំដែលទេ ពីព្រោះវានឹងអាចចំណាយពេលវេលាឥតប្រយោជន៍។

[១១:៥៦:៥៦]

**លោក វីណ្ហៀម ស្មីត៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំនឹងបំភ្លឺជូនបន្ថែម។

**សួរដោយលោក វីណ្ហៀម ស្មីត៖**

**ស៖** នៅក្នុងឆ្នាំ១៩៧៥-- អឺ!៧០ ដល់១៩៧៥ លោកដឹងថាលោក ខៀវ សំផន រស់នៅឯណាទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ខ្ញុំដឹងថា ខៀវ សំផន នៅជាប់ជាមួយ ប៉ុល ពត។

**ស៖** តើនៅពេលណាដែលលោកបានឮពីឈ្មោះ អៀង សារី ដំបូងនោះ?

**ឆ៖** អៀង សារី ខ្ញុំឮដំបូងនៅឆ្នាំ១៩៦២។

[១១:៥៨:០២]

**ស៖** ថាតើលោកបានឮអ្វីខ្លះអំពីលោក អៀង សារី ថាគាត់ជាអ្នកណា? ហើយគាត់ធ្វើការងារអ្វីដែរឬទេ?

**ឆ៖** នៅពេលនោះ ខ្ញុំជាប់ឌីប្លូមហើយ។ ខ្ញុំទៅលេងជាមួយនឹងអគារនុរក្ស ដើម្បីលាគាត់ទៅរៀននៅសៀមរាម។ អគារនុរក្សហ្នឹងឈ្មោះ នា គឹមសី-- នា គឹមស៊ុយ។ ពីដើមធ្លាប់នៅស្មោងបង្ហាត់នៅថ្នាក់ឧត្ដមដ្ឋាន។ ដល់ខ្ញុំទៅលេងជាមួយនឹងគាត់ គាត់ប្រាប់និយាយហូរហែសព្វគ្រប់ពីនេះ ពីនោះ។ ដល់ចុងបញ្ចប់គាត់និយាយថា អៀង សារី ជាបុគ្គលដែលគួរឲ្យគោរព ជាអ្នកនយោបាយមួយរូបដែលគួរឲ្យគោរព ព្រមទាំងនោះគាត់និយាយអំពី ខៀវ កុមារ ផងដែរ។ យើងខ្ញុំឮឈ្មោះ អៀង សារី ហើយនិង ខៀវ កុមារ ពីពេលនុ៎ងមក។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ លោកប្រធាន លោក លោកស្រីចៅក្រម ឥឡូវនេះម៉ោងជិតដប់ពីរហើយ ថាតើអនុញ្ញាតឲ្យខ្ញុំបន្ត ឬក៏ត្រូវសម្រាកសម្រាប់ពិសាអាហារថ្ងៃត្រង់សិនបាទ?

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកពិសាថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងអញ្ជើញលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ទៅកាន់បន្ទប់សម្រាកសម្រាប់សាក្សី ហើយនឹងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅរសៀលនេះឲ្យបានត្រឹមម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០០:០៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតស្នើ សុំការអនុញ្ញាតឲ្យកូនក្តីរបស់ខ្ញុំទៅតាមដាននៅបន្ទប់ខាងក្រោមនៅពេលល្ងាចនេះ ហើយយើង-- គាត់ចូលរួមនៅទីនោះ ប្រសិនបើគាត់មិនអាចតាមដាននៅទីនោះទៀត ខ្ញុំនឹងជម្រាប ឬក៏ស្នើទៅអង្គជំនុំជម្រះនៅពេលនោះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់លោកជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ គឺសុំទៅបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ។ ដោយគាត់លះបង់សិទ្ធិមិនចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ។ ហើយដោយពិនិត្យស្ថានភាពជាក់ស្តែងនៃបញ្ហាសុខភាព និងវ័យរបស់ជនជាប់ចោទ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំដែលស្នើឡើងដោយមេធាវីការពារក្តីរបស់គាត់ ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះតាមប្រព័ន្ធសោតទស្សន៍រយៈពេលពេញមួយថ្ងៃនេះ-- ថ្ងៃរសៀល។ តែក្រុមមេធាវីការពារក្តីជនជាប់ចោទ ត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬក៏ផ្តិតស្រាមដៃយ៉ាងច្បាស់ពីជនជាប់ នួន ជា ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍

ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការពីចម្ងាយពីបន្ទប់ដែលបានរៀបចំរួចជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបទៅកាន់បន្ទប់សម្រាកនៅខាងក្រោម។ ហើយដោយឡែកនៅរសៀលនេះ បង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់សវនាការនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣២:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីអាចមានលទ្ធភាពក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម លោកសាក្សី សាធារណជន ជាទីគោរព។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ មុនពេលដែលយើងឈប់សម្រាក ខ្ញុំបានលើកឡើងអំពីករណីដែលថាលោកបានស្គាល់លោក អៀង សារី មុនឆ្នាំ១៩៧៥។ ក្នុងអំឡុងឆ្នាំ៧០ និង៧៥ តើលោកបានដឹងដែរឬទេ លោក អៀង សារី គាត់ធ្វើការងារអ្វីដែរក្នុងអំឡុងពេលនោះ?

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ឆ្នាំ១៩៧១ មិនដឹង ១៩៧២ មិនដឹង វិទ្យុផ្សាយថា អៀង សារី ទៅធ្វើបេសកជនពិសេសប្រចាំប៉េកាំង ដើម្បីរាយការណ៍ជូនប្រមុខរដ្ឋ ហ្នឹងផ្សាយវិទ្យុអ៊ីចឹង។

**សៈ** ពាក់ព័ន្ធទៅនឹង នួន ជា តើលោកដឹងដែរឬទេ គាត់ធ្វើការងារអ្វីនៅចន្លោះឆ្នាំ៧០ ដល់៧៥?

**ឆៈ** ឆ្នាំ១៩៧១ ខ្ញុំទៅដល់ឃុំពាម មន្ទីរស្នាក់ការ មន្ទីររបស់យុទ្ធភូមិភាគ-- របស់ភូមិភាគពិសេស ពេលហ្នឹងហើយដែលខ្ញុំឮគេនិយាយអំពី បងនួន អនុលេខាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ ព្រោះនៅហ្នឹងឃុំពាមហ្នឹង មានបងប្អូនខាងប្រពន្ធ នួន ជា នៅនុំងច្រើនដែរ។

**សៈ** សូមអរគុណ។ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកបានដឹងថា អៀង សារី, ខៀវ សំផន និង នួន ជា គាត់-- ពួកគាត់រស់នៅឯណាដែរឬទេ?

**ឆៈ** ខ្ញុំដឹងថាគាត់នៅក្នុងមន្ទីរមជ្ឈិម។

**សៈ** តើមន្ទីរមជ្ឈិមនោះមានទីតាំងនៅឯណាដែរ?

**ឆៈ** ខ្ញុំដឹងអត់ច្បាស់ទេ ប៉ុន្តែស្មាន ដោយសារឃើញចុងផ្លូវ សុធារសនោះ គេបិទស័ង្កសី ហើយព័ត៌មានពីណាទេ ប្រាប់ខ្ញុំថា ប៉ុន្មាននាក់ហ្នឹងនៅក្នុង គេហៅថាហ្លុងបាសាក់ ផ្ទះល្វែងតជាប់ៗគ្នានោះនៅនឹងជិតសាលមហាស្របចតុមុខ។ ហើយខ្ញុំក៏ចងចាំគិតអ៊ីចឹងមក រួចដល់ក្រោយមកនេះ លេចចេញឯណា ក-១, ក-២, ក-៣ ឯណា ខ្ញុំមិនដឹងទេ។ ដូច្នេះការដឹងហ្នឹងមិនពិត មិនត្រឹមត្រូវទេ។

[១៣:៣៧:១៤]

**សៈ** លោកបានលើកឡើងថា ពួកគាត់រស់នៅក្នុងក្រុម ជាក្រុមនៅក្នុងផ្ទះមួយ។ តើផ្ទះនោះគឺគាត់រស់នៅផ្ទះដោយរបស់ខ្លួនឯងរៀងៗខ្លួន ឬក៏រស់នៅផ្ទះជាមួយគ្នាតែម្តង?

**ឆៈ** ដំណឹងអង្កាល់នុំងថារស់នៅផ្ទះជាមួយគ្នា បាយជាមួយគ្នា នេះដំណឹងអង្កាល់នុំង។

**សៈ** តើលោកស្តាប់ទទួលព័ត៌មានទាំងអស់នេះមកពីនរណាដែរ? ហើយស្តាប់ទទួលព័ត៌មានទាំងអស់នេះនៅឆ្នាំណាដែរ? នៅពេលណាដែរ?

**ឆៈ** អារឿងបាយជាមួយគ្នា គឺៗរឿង សុន សេន ហ្នឹងតែម្តង។ ថ្ងៃមួយកំពុងតែធ្វើការ មាន សុន សេន, មាន ទុំ ដល់ទៅ សុន សេន-- ន៎ែ ទុំ ប្រញាប់លាទៅមុន ថាដល់ម៉ោងបាយ។ សុន សេន គាត់ខឹងគាត់។ គាត់ថាដល់ ទុំ ចេញផុតទៅ គាត់ថា ម៉ោងបាយអាម៉េច ខ្ញុំបាយហ្នឹងដែរតើ។ ព្រឹត្តិការណ៍ហ្នឹងដែលខ្ញុំគិតថា ប៉ុន្មាននាក់ហ្នឹងគឺបាយនៅជុំគ្នាៗ។ ហើយព្រឹត្តិការខ្លះទៀត គេនិយាយថា សុន សេន ហ្នឹង គាត់និយាយទៀតថា ថ្ងៃមួយនុំងគាត់ស្នើសុំចាប់មនុស្សម្នាក់ វន វ៉េត ថាអ្នែ ដូចមិនកើតទេ។ ស្រាប់តែ នួន ជា ថាអ្នែត្រូវតែចាប់។ ហ្នឹងខ្ញុំមានរាយការណ៍ចុះក្នុងកំណត់ហេតុសួរចម្លើយនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ រឿងរ៉ាវទាំងអស់ហ្នឹងហើយ ដែលខ្ញុំ នាំឲ្យខ្ញុំសន្និដ្ឋាន

ថា គាត់នៅជុំគ្នា។ ព្រឹត្តិការណ៍មួយទៀត នៅពេលដែល នួន ជា តាមរយៈ សុន សេន បញ្ជាឲ្យខ្ញុំទៅតាមដានសពអណ្តែតទឹកនោះ។ បងពីន ជូនខ្ញុំទៅ ខឹម ពីន លេខាកងពល៧០៣ ហ្នឹង។ ជិះអាកូនកាណូតគេតូចៗរបស់ពួកដើងទឹកជ្រោយចង្វាហ្នឹង ដល់ទៅភ័យនឹងមុខហ្វុងបាសាក់ហ្នឹង ទាំងអស់គ្នាថាមុខផ្ទះចាស់ៗ។ រឿងទាំងអស់ហ្នឹងហើយ ដែលធ្វើឲ្យខ្ញុំសន្និដ្ឋានខុសអីចឹង។ ហើយម្យ៉ាងទៀតខ្ញុំថាបែប ត្រង់ហ្នឹងហើយ បុកទៅវាចូលទៅក្នុងបាសាក់ ម្ល៉ោះបិទស័ង្កសីមិនឲ្យអ្នកណាចូលទៅដល់ជិតមន្ទីរមជ្ឈិម។ នេះរឿងរ៉ាវអស់នេះ ខ្ញុំនរណាប៉ានទៅសួរថាមន្ទីរមជ្ឈិមនៅឯណា? អត់ដែលប៉ានសួរទេលាក់ការណ៍សម្ងាត់។ ដូច្នេះចេះតែសន្និដ្ឋានទៅ វាទៅអីចឹង។ ដូច្នេះដល់ក្រោយមកបានជាវាលេចឯណាក-១ ឯណា ក-៣ អីឯណាហ្នឹងខ្ញុំមិនដឹងទេ។ ដូច្នេះរឿងរ៉ាវដែលដឹងមកហ្នឹងវាខុសទាំងអស់ទៅហើយ។

[១៣:៤០:៤៤]

**ស៖** តើទាមទារឲ្យក្រុមបុគ្គលមួយចំនួនរស់នៅជាមួយគ្នាៗ ហូបជាមួយគ្នា ដើម្បីទទួលបាននូវគោលនយោបាយមនោគមន៍វិជ្ជាដូចគ្នា តើវាជាគោលការណ៍ គោលនយោបាយពេលនោះដែរឬទេ ឬក៏មិនមែនទេ?

**ឆ៖** មិនមែនជាគោលនយោបាយរបៀបនុ៎ងទេ គឺបង្ខំឲ្យហូបរួមគ្នា កុំឲ្យច្រណែនគ្នា កុំឲ្យឃើញអ្នកនេះបាននេះហូបនោះ អ្នកនោះបាននោះ ហូបនោះ វាទៅជាស្អប់គ្នា។ សូម្បីតែនៅផ្ទះបាយខ្ញុំក៏ដោយ ខ្ញុំជាមួយនឹងយុទ្ធជនកម្មាភិបាលដូចគ្នាទាំងអស់។ នេះជាស្មារតីឲ្យឃើញស្មើភាព។

[១៣:៤១:៥៣]

**ស៖** សូមអរគុណ។ ខ្ញុំសូមវិលត្រឡប់ទៅក្រោយបន្តិច ហើយយើងបញ្ចប់ការពិភាក្សាលើជួរកងទ័ពហើយ។ លោកបាននិយាយថា រហូតមកដល់ឆ្នាំ១៩៧៥ អង្គភាពកងទ័ពគ្រប់គ្រងដោយភូមិភាគក្រោយឆ្នាំ៧៥ គឺមានការរៀបចំរចនាសម្ព័ន្ធយោធាឡើងវិញ ហើយគ្រប់គ្រងដោយមជ្ឈិម។ លោកក៏បានលើកឡើងថា លោកបានចូលរួមប្រជុំមួយចំនួនជាមួយនឹងជួរកងទ័ព។ នៅពេលនេះខ្ញុំសូមបង្ហាញជូនលោកនូវឯកសារ D168/3.14 ខ្ញុំមានឯកសារនេះជាក្រដាសផងដែរ ហើយខ្ញុំសូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់។ លោកសាក្សី ប្រសិនបើលោកអាចមើលឯកសារនេះ ហើយបញ្ជាក់ថា លោកធ្លាប់អានឯកសារនេះពីមុនដែរឬទេ? ហើយស្គាល់ដែរឬទេ? ហើយសូមឲ្យលោកពន្យល់ដោយខ្លីៗជូនអង្គជំនុំជម្រះថាតើឯកសារហ្នឹងជាឯកសារអ្វីដែរ?

**ឆ៖** ឯកសារនេះ ខ្ញុំសូមអានចំណងជើង “កំណត់ហេតុនៃការប្រជុំខាងមន្ទីរអង្គការ ៧០៣ និង

ស-២១" នេះចំណាងជើងវាប៉ុននុ៎ង។

**ស៖** ឯកសារនេះចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ៧៦ នៅខាងក្រោមយើងឃើញពាក្យថា សមមិត្ត ឌុច។ តើសមមិត្ត ឌុច នោះគឺសំដៅទៅលើលោកមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[១៣:៤៤:៣៦]

**ស៖** តើលោកធ្លាប់ឃើញឯកសារហ្នឹងពីមុនដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនច្បាស់លាស់ទេ នៅពេលសវនាការសំណុំរឿងលេខ០០១ ក៏ប៉ុន្តែបើនិយាយពីព្រឹត្តិការណ៍នេះខ្ញុំបានចូលរួមមែន។

**ស៖** នៅផ្នែកខាងលើគឺមានលេខៗ ៨៩, ៧១ និង សោម ហើយនិង ប.ប.ក តើសំដៅលើអ្វីដែរ?

**ឆ៖** ប.ប.ក នេះជាលេខរបស់អ្នកផ្សេងទៀត គេចុះទេ។ គេចាំណាំលេខកូដឯកសារគេ។ ខ្ញុំមិនដឹងទេ មិនដឹងជាមានន័យថាម៉េចទេ។ ប៉ុន្តែបើ ៨៩, ៨១, សោម, លេខ៤ ឯកសារ អាហ្នឹងបាន១លេខនៃការអ្នកធ្វើកំណត់ហេតុ។ ពួកសេនាធិការដែលធ្វើកំណត់ហេតុហ្នឹងមាន-- ណា៎ អ្នកដែលចូលប្រជុំខាងសេនាធិការហ្នឹងមាន បង៨៩ គឺ សុន សេន, បង៨១ គឺ ស៊ាត ឆែ ហៅ ទុំ, សោម ហ្នឹងឈ្មោះ ដើម ពេជ ឆន ដែលខ្ញុំបានរាយការណ៍ហើយ។ ហើយឯកសារហ្នឹង គឺពួកអ្នកខាងធ្វើឯកសារនេះ។

**ស៖** ប្រសិនបើលោកអាចជម្រាបខ្លី១ជូនអង្គជំនុំជម្រះនោះ ថាតើកិច្ចប្រជុំនោះប្រជុំលើអ្វី? គោលបំណងនៃប្រជុំធ្វើដើម្បីអ្វីដែរ? ហើយនៅចុងប្រជុំនោះ តើមានសម្រេចអ្វី?

[១៣:៤៦:៤៧]

**ឆ៖** ខ្ញុំចាំបាន។ ខាងមន្ទីរអង្គការដែលចូលរួមថ្ងៃណោះ គឺមិត្ត ខាំ មី ទៅចូលរួម, ៧០៣ បងពីន, ហើយខាងស-២១ នេះ ខ្ញុំ ហើយក្រោមអធិបតីភាពរបស់ សុន សេន ប្រជុំនេះ។ បញ្ហាដែលលើកឡើងយកមកប្រជុំ គឺបញ្ហាដែលខិត្តប័ណ្ណគេបាច។ ហើយខ្លឹមសារយ៉ាងម៉េច អីយ៉ាងម៉េច វាមានល្អិតនៅក្នុងនេះហើយ។ ហើយនៅចុងបញ្ចប់ វាមានមតិសរុបរបស់ បង៨៩ គឺមតិសរុបរបស់ សុន សេន ហើយនៅចុងបញ្ចប់មានវិធានការ។

**ស៖** ចំណុចដែលសរសេរនៅក្នុងខិត្តប័ណ្ណនោះ គឺគេប្រឆាំងនឹងគោលនយោបាយរបស់បក្ស តើមែនដែរឬទេ?

**ឆ៖** សូមបញ្ជាក់ ខិត្តប័ណ្ណហ្នឹង ខ្ញុំអត់បានឃើញនឹងភ្នែកខ្ញុំទេ។ ខ្ញុំអត់បានឃើញនឹងភ្នែកខ្ញុំទេ។ ខ្ញុំរាយការណ៍ជូនអង្គប្រជុំអំពីខ្សែខិត្តប័ណ្ណពីមុន យើងចាប់ អាសម្បត្តិ។ អាសម្បត្តិ ហ្នឹងគឺ យឹម សម្បត្តិ ដែលបោកគ្រាប់បែកក្រោយវាំង។ សួរ អាលាប, អាម៉ាត់ គឺខិត្តប័ណ្ណនេះពី មិត្តភួន កងពល១៧០។ ភួន ហ្នឹងអនុលេខាកងពល១៧០។ តាមសន្និដ្ឋានអាចបោះច្រើនលើមុខសញ្ញាដទៃដែរ តែបងប្អូនមិនដែល ចាប់អារម្មណ៍លើបញ្ហានេះ។ នេះខ្ញុំនិយាយពីរបីម៉ាត់ប៉ុណ្ណឹង។ ដូច្នេះ ខ្ញុំអត់បានឃើញខិត្តប័ណ្ណនេះនឹង ភ្នែកទេ ខ្ញុំនិយាយអំពីរឿងសួរចម្លើយមនុស្សប៉ុន្មាននាក់នេះ ឆ្លើយដាក់ថាម្ចាស់ខិត្តប័ណ្ណ គឺមិត្ត ភួន អនុ លេខាកងពល១៧០។

[១៣:៤៩:០៧]

**ស៖** ប្រសិនបើលោកមើលទំព័រទី២នៃកំណត់ហេតុនេះ សរសេរថា ចាំបាច់ត្រូវពិនិត្យមើលកង ១៧០, កង៧០៣ និងអង្គភាពផ្សេងទៀត។ តើគោលបំណងនៃការប្រជុំនេះ ដើម្បីស្វែងរកនរណាគេជា អ្នកបាចខិត្តប័ណ្ណ ហើយចាប់ខ្លួនអ្នកនោះ តើមែនដែរឬទេ?

**ឆ៖** ទេៗ ឥឡូវត្រង់ត្រង់ណា?

**ស៖** ប្រសិនបើលោកមើលកថាខណ្ឌទីពីររាប់ពីក្រោម។ "២) បញ្ហាចាត់តាំងសមមិត្ត ប៉ង់ និង ខាំ មី ត្រូវឃើញភារកិច្ចធ្ងន់ធ្ងរ ខំអប់រំនយោបាយ សតិអារម្មណ៍ឲ្យជាប់ ក្តាប់ប្រវត្តិរូប ក្តាប់សតិ អារម្មណ៍ឲ្យជាប់ ប្រយ័ត្នកុំឲ្យមានទំនាស់សតិអារម្មណ៍ ខាងខ្មាំងអូសបាន ទិញបាន អ្នកណាយើង សង្ស័យត្រូវយកចេញ ត្រូវខំរកដែរ ពិនិត្យហេតុភេទកន្លែងនោះ"។ ដូច្នេះមូលហេតុដែលការប្រជុំនោះ គឺដើម្បីស្វែងរក តើបុគ្គលណាដែលជាអ្នកបាចខិត្តប័ណ្ណ? តើមែនដែរឬទេ ទើបគេប្រជុំដូច្នេះ?

[១៣:៥០:៤៥]

**ឆ៖** វិធានការនេះមានលក្ខណៈពីរ។ ក្នុងបញ្ហាវិធានការហ្នឹង កថាខណ្ឌទី២ ដែលលោកអាន អម្បាញ់មិញហ្នឹង បង៨៩ គឺ សុន សេន បញ្ជាក់ហើយ។ ខាងមិត្ត ប៉ង់ និង ខាំ មី ត្រូវឃើញភារកិច្ចធ្ងន់ ធ្ងរ ខំអប់រំនយោបាយសតិអារម្មណ៍ឲ្យជាប់ ក្តាប់ប្រវត្តិរូបឲ្យជាប់ អំ ក្តាប់ប្រវត្តិរូប ក្តាប់សតិអារម្មណ៍ ឲ្យជាប់។ ប្រយ័ត្នកុំឲ្យមានទំនាស់សតិអារម្មណ៍ ខ្មាំងអូសទាញទិញបាន។ បើអ្នកណាសង្ស័យត្រូវយក ចេញ ត្រូវខំរកដែរ ដើម្បីហេតុភេទកន្លែងនោះ។

សូមបញ្ជាក់ថា ខាំ មី ហើយនិង ប៉ង់ៗ លេខាស-៧១ ខាំ មី ជាសមាជិកស-៧១ សមាជិកណា! ខាំ មី នេះគាត់កាន់កងពលការពារមន្ទីរមជ្ឈិម។ ដូច្នេះ ប៉ង់ ហើយនិង ខាំ មី នេះត្រូវមានបន្ទុកធ្ងន់ធ្ងរ

ណាស់។ ព្រឹត្តិការណ៍បាចខិត្តប័ណ្ណត្រូវពិនិត្យមើលក្នុងកងទ័ពខ្លួនឯង អប់រំ ថែបំប៉នសតិអារម្មណ៍។ នេះជាវិធានការចាំបាច់។ ហើយបានត្រូវខំរកដែរ ពេលហេតុភេទនៅកន្លែងនោះ។ បើអ្នកណាសង្ស័យត្រូវយកចេញ។ នេះជាវិធានការជំហានទីពីរទេ។ បាចក៏ដោយ មិនបាចក៏ដោយ ឲ្យតែឃើញបញ្ហាហេតុភេទអីសង្ស័យ គេឲ្យយកចេញពីកងហ្នឹង ទៅដាក់នៅឯណាទៀតទៅ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ។

[១៣:៥២:២៤]

**ស៖** សូមអរគុណ។ តើលោកជួបប្រជុំបែបនេះញឹកញាប់ប៉ុនណាដែរ? តើការជួបប្រជុំជាមួយនឹងកងទ័ពយោធាហ្នឹងញឹកដូចអ៊ីចឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** ខ្ញុំជឿថា ការប្រជុំបែបនេះសុទ្ធតែមានកំណត់ហេតុ។ កំណត់ហេតុដែលបង្ហាញមកហើយពីរឿងប្រមូលចាប់ឲ្យស-២១ ចាំទទួលកង មិត្តសុខ ដែលចាប់ពីកន្លែង ចក្រី ហើយប្រជុំលើកពីរ គឺអាហ្នឹងឯង។ ដូច្នេះថ្ងៃនោះទៅចូលរួមប្រជុំមិនមែនត្រឹមតែ ខាំ មី ទេ មាន ប៉ង់ ទៅផង អត់តែមិត្ត លីន។ ដូច្នេះខ្ញុំនឹកមិនឃើញអីទៀតទេ ប៉ុន្តែបើសិនមានប្រជុំរបៀបនេះ គឺសុទ្ធតែមានកំណត់ហេតុ។

**ស៖** សូមអរគុណ។ លោកទើបតែនិយាយឈ្មោះបុគ្គលដែលចូលរួមប្រជុំម្នាក់ឈ្មោះ ប៉ង់ ហើយលោកបានលើកឡើងថា គាត់ជាៗអ្នក-- ជាសមាជិកមជ្ឈិមនៅ៧១-- នៅស-៧១។ ដូច្នេះ ខ្ញុំសូមសួរលោក ថាតើស-៧១នេះ មានសមាជិកអ្នកណាខ្លះ? តើ ប៉ង់ ទទួលខុសត្រូវអ្វីដែរនៅស-៧១?

**ឆ៖** ស-៧១ នេះ ប៉ង់ ទទួលខុសត្រូវរួម។ គាត់ជាសមាជិកជំនួយការមជ្ឈិម បុគ្គលទីមួយ។ ជំនួយការមជ្ឈិមទាំងអស់នៅក្រោមគាត់។ បុគ្គលទីពីរ គឺមិត្ត លីន ជាជនជាតិភាគតិច ឈ្មោះដើមស្អីខ្ញុំមិនដឹងទេ។ ឯចំណែកបុគ្គលទីបី គឺមិត្ត ខាំ មី ហ្នឹងឯង ទទួលភារកិច្ចជាបញ្ជាការកង១៨០ ដែលជាកងការពារមជ្ឈិម។

**ស៖** តើ ប៉ង់ គ្រប់គ្រងនូវអ្វីដែរ? គាត់ទទួលខុសត្រូវរួមលើ ស-២១ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា តើគាត់ក្តាប់ទៅលើសកម្មភាពណាខ្លះ ក្នុងតួនាទីរបស់គាត់ជាប្រធានស-៧១?

**ឆ៖** គាត់ក្តាប់រួម មិនដឹងជាស្អីខ្លះទេ។ ក៏ប៉ុន្តែនិយាយពីក្តាប់រួម ភារកិច្ចអីក៏ដោយ ក៏គាត់រត់ដែរ។ បើទៅស-២១វិញ ប៉ង់ ចូលដល់កប់ទៅក្នុងកន្លែងឆ្លាក់រូបទៅទៀត ដល់ទៅក្នុងកន្លែងឆ្លាក់រូបទៅទៀត មិនមែនត្រឹមតែផ្ទះខ្ញុំ។ ផ្ទះខ្ញុំ ប៉ង់ ចេញចូលម៉ោងណាក៏បាន។ ដូច្នេះភារកិច្ចចំពោះមុខ ប៉ុល ពត ប្រើអី ប៉ង់ ទៅនុ៎ង។

[១៣:៥៦:០៣]

**ស៖** តើស-៧១ មានពាក់ព័ន្ធទៅនឹងមន្ទីរណាដែរឬទេ ដែលខ្លួនក្តាប់ ឬក៏មានទំនាក់ទំនងជាមួយនឹងបុគ្គលណាដែរឬទេ? ថាតើមន្ទីរស-២១ ក្តាប់ទៅលើក្រុមបុគ្គលណាខ្លះ ហើយគ្រប់គ្រងទៅលើមន្ទីរណាខ្លះ? លោកទើបតែបានលើកឡើងអំពីស-៧១ ដូច្នេះ តើប៉ង់ជាប្រធានស-៧១នោះក្តោបទៅលើមន្ទីរណាខ្លះ? ហើយបុគ្គលណាខ្លះ?

**ឆ៖** ខ្ញុំមិនដឹងទេ ប៉ុន្តែក៏ខ្ញុំបានដកស្រង់ពីបញ្ជីដែលសហព្រះរាជអាជ្ញាផ្តល់ឲ្យខ្ញុំព្រឹកមិញ បញ្ជីអ្នកទោស ស-២១។ ទៅដល់ឃើញអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់ស-៧១ មាន១៣នាក់ វាមិនដឹងដូច្នេះ ខ្ញុំបានដកស្រង់ហើយ រាយការណ៍ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតរួចហើយ។ ខ្ញុំដឹងដោយការដកស្រង់ហ្នឹងឯង។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។ យើងទុកឯកសារនេះមួយឡែកសិន ហើយប្រសិនបើខ្ញុំសូមឲ្យលោកពិនិត្យមើលឯកសារមួយទៀត គឺឯកសារ D108/3.31.4។ ប្រសិនបើអនុញ្ញាត ខ្ញុំសូមដាក់នៅលើ អេក្រង់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អនុញ្ញាត បាទ។ មន្ត្រីតុលាការយកទៅជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:៥៨:៤៩]

**លោក វីល្លៀម ស្មីត៖**

ឯកសារមួយទៀតនោះ គឺលេខ IS13.33។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកឃើញឯកសារនេះដែរឬទេ? ហើយតើលោកអាចជម្រាបយើងខ្ញុំដែរឬទេ លោកធ្លាប់ឃើញឯកសារនេះពីមុនដែរឬទេ? ឯកសារនេះ គឺនិយាយអំពីកំណត់ហេតុប្រជុំនៅថ្ងៃ-- កាលបរិច្ឆេទមួយដែលក្នុងនោះលើកឡើងអំពីស្ថិតិពាក់ព័ន្ធទៅនឹងសិទ្ធិមួយចំនួន ហើយក៏បានលើកឡើងអំពីកងពល និងបុគ្គលមួយចំនួនដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ ដែលក្នុងនោះ រួមទាំងមកពីស-២១ផងដែរ។ តើលោកធ្លាប់ឃើញប្រភេទឯកសារនេះ ពីមុនដែរឬទេ?

**ឆ៖** ឯកសារដែលលោកឲ្យ-- ផ្តល់មកឲ្យខ្ញុំឯកសារដដែល មិនមែនឯកសារថ្មីដែលបញ្ចាំងលើ

អក្រេកង់នេះទេ។

**ស៖** គឺខ្ញុំអាចឲ្យហុចឯកសារនេះវិញ បាទ សូមអញ្ជើញ!

[១៤:០១:៥៤]

**ឆ៖** ឯកសារនេះ បើតាមខ្ញុំចាំ បង្ហាញខ្ញុំនៅពេលសវនាការម្តងរួចទៅហើយ។ គឺកំណត់ហេតុស្តីពីការប្រជុំការងារបង្កបង្កើនផល យប់ថ្ងៃទី៩-- ៣០ ខែ៩ ឆ្នាំ១៩៧៦។ ហើយបើខ្ញុំចាំដែរ ប្រជុំខាងការងារបង្កបង្កើនផល ខ្ញុំក្លាប់មិនបានទេ។ មេច្រើនតែហៅមិត្តហ៊ុយ ឲ្យទៅចូលរួមប្រជុំ។ ប៉ុន្តែក្នុងឯកសារនេះ គ្មានកំណត់ថាឈ្មោះខ្ញុំ ឬ មិត្តហ៊ុយ ទេ។ ក៏ប៉ុន្តែការប្រជុំបង្កបង្កើនផលពិតជាមានពេលហៅ ស-២១ ទៅចូលរួមប្រជុំ។

**ស៖** តើលោកឯកភាពជាមួយខ្ញុំដែរឬទេថា កងពលមួយចំនួនដែលជាកងពលនៅក្នុងជួរបដិវត្តន៍-- ជួរកងទ័ពបដិវត្តន៍កម្ពុជានោះ ក៏បានចូលរួមក្នុងកិច្ចប្រជុំនោះដែរ តើមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[១៤:០៣:១១]

**ស៖** ហើយរបៀបវារៈពីរសំខាន់ៗ គឺនិយាយអំពីស្ថានភាពរបស់ខ្មាំង។ ហើយនិងរបៀបវារៈទីពីរ គឺស្ថិតិស្រូវស្រាល ហើយនិងបញ្ហាផ្សេងៗទៀត ទាក់ទងទៅនឹងការធ្វើស្រូវ។ ប្រសិនបើលោកមើល គឺនៅទំព័រទីមួយ ហើយវាជារបៀបវារៈនៃកិច្ចប្រជុំហ្នឹង តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ?

**ឆ៖** ខ្ញុំយល់ស្រប។

**ស៖** ស្ថានភាពខ្មាំងគឺរបៀបវារៈ ទីមួយ ហើយ បងទុំ ជាអ្នកស្នើ។ តើ បងទុំ ហ្នឹង គឺជាអ្នកណាដែរ?

**ឆ៖** បងទុំ នោះ គឺអនុលេខាសេនាធិការ អនុប្រធាន ឬអនុលេខា គេហៅបានដូចគ្នា។ ឈ្មោះដើម ស៊ាត ឆែ។

[១៤:០៥:០១]

**ស៖** តើអ្នកតំណាងស-២១ ចូលរួមនៅក្នុងកិច្ចប្រជុំហ្នឹង ញឹកញាប់បែបណា? បានន័យថាតើតំណាងស-២១ ចូលប្រជុំជាមួយអ្នកតំណាងដទៃៗទៀតនៅក្នុងកិច្ចប្រជុំហ្នឹងញឹកញាប់បែបណាដែរ?

**ឆ៖** តំណាងស-២១ ប្រជុំពីរឿងស្រូវ មិត្តហ៊ុយ ទៅ។ ដូច្នេះគ្រប់រដូវកាលស្រូវ នេះខែ៩ ថ្ងៃ ៣០ ខែ៩ ទៅប្រជុំ។ ដូច្នេះគ្រប់រដូវកាលស្រូវ។

**ស៖** សូមអរគុណ។ តើលោកដឹងទេថា ការប្រជុំរបៀបនេះ គឺគេធ្វើឡើងញឹកញាប់ប៉ុនណា ឬមួយក៏គេធ្វើតែម្តងទេ ឬមួយក៏គេធ្លាប់ញឹកញាប់ដែរ?

**ឆ៖** ខ្ញុំបានជម្រាបហើយ គ្រប់រដូវកាលស្រូវ ដូច្នេះមួយឆ្នាំម្តង។

**ស៖** ប្រសិនបើយើងមើលទៅលើឯកសារនេះ យើងចុះទៅក្រោមបន្តិចបន្ទាប់ពីរបៀបវារៈ គឺនិយាយអំពីការពិភាក្សាផ្សេងៗ។ ហើយចំណុចទីមួយ គឺនិយាយពីបញ្ហាកងទ័ព និងៗកងពលធំលេខ៥ ហើយនិងកងពលធំលេខ៣ ហើយនិយាយខ្លះៗទាក់ទងបញ្ហាហ្នឹង។ កងពល៥០២ និងកងពល៣១០ ហើយបាននិយាយថា នៅថ្ងៃ២៥ ខែ៩ មានស្ត្រីម្នាក់ឈ្មោះ ង៉ែត អូម មានកូនស្រីពីរនាក់ជាប្រជាជនថ្មីមកពីស្រុក៥៥ តំបន់៣៣ មានគោលបំណងរត់ទៅបាត់ដំបង ហើយត្រូវបានចាប់ខ្លួន។ ដែលបាត់ដំបងហ្នឹង គឺជាស្រុកកំណើតរបស់គាត់។ សំណួររបស់ខ្ញុំគឺថា តើលោកដឹងទេ? តើនេះជាគោលនយោបាយ ឬក៏មិនមែនទេក្នុងការចាប់ប្រជាជនដែលរត់គេច? បានន័យថា ប្រជាជនដែលរត់គេចពីតំបន់មួយទៅតំបន់មួយ។

[១៤:០៧:៣៣]

**ឆ៖** ត្រឹមត្រូវហើយ ជាគោលនយោបាយ។

**ស៖** ប្រសិនបើយើងមើលទៅទំព័របន្ទាប់ ហើយចុះទៅក្រោមបន្តិចក្រោយនោះ គឺវាបានរៀបរាប់ថា តំណាងមកពីកងពលធំ៣១០ បាននិយាយថាយើងចង់ទទួលបានយោបល់ យើងចង់ស្នើយោបល់ពីអង្គការ។ តើលោកអាចជម្រាបតុលាការបានដែរឬទេ ថាតើអង្គការនៅទីនេះសំដៅទៅលើអ្នកណា? បានន័យថាតើលោកអាចអាចជម្រាបបានទេថាតើអង្គការនេះសំដៅទៅលើអ្នកណាដែរ ប្រសិនបើលោកអាចដឹង?

**ឆ៖** អីណា? នៅកន្លែងណា? បន្ទាត់ទីប៉ុន្មាន? កងពលលេខ៣១០។

[១៤:០៨:៤៨]

**ស៖** ពិតហើយ គឺនិយាយទៅដល់កងពលធំ៣១០ គឺប្រហែលជាបីបួនជួរខាងលើ គឺនិយាយអំពីកងពលធំ៤០៨ ហើយបាននិយាយថាយើងចង់ទទួលបានយោបល់ពីអង្គការ។ តើលោកអាចជម្រាបយើងបានទេ ថាតើអង្គការហ្នឹងសំដៅលើអ្នកណាដែរ ប្រសិនបើលោកអាច?

**ឆ៖** ក្នុងពេលអប់រំក្នុងសាលាក៏ល្អួច ចេញពីសាលាភ្លាមក៏ល្អួចទៀត សមាសភាពនេះមានជាង៣០នាក់។ សូមស្នើមតិអង្គការ។ អង្គការនេះ គឺសំដៅខាងលើ គឺសំដៅ ប៉ុល ពត ហ្នឹងតែម្តង។ ក៏ប៉ុន្តែ

កងពល៧០៣ លេខាកងពល៧០៣ បងពីន មិនអាចជួបស្នើទេ គឺស្នើទៅតាមរយៈសេនាធិការ ដែលមានមុខដឹកនាំប្រជុំនៅពេលនុ៎ងអាចត្រឹមតែ ស៊ាត ឆែ ហៅ ទុំ គឺ បង៨១ ទេ។

**ស៖** ដូច្នេះ បង៨១ តើ បង៨១ ហ្នឹង គឺជាអ្នកណាដែរ?

**ឆ៖** ខ្ញុំជម្រាបអំមិញហើយ គេហៅបង៨១ នេះ គឺ ស៊ាត ឆែ ហៅ ទុំ អនុប្រធានសេនាធិការ។

**ស៖** នៅពេលដែលយើងពិនិត្យឯកសារនេះ តើវាច្បាស់ដែរឬទេ ដែលថាប្រធានកងពលធំហ្នឹងចង់ៗស្នើសុំមតិអង្គការ ស្នើសុំមតិឬក៏ស្នើនូវយោបល់ពីថ្នាក់លើ? តើយើងអាចនិយាយបែបនេះបានទេ?

**ឆ៖** សរសេរនៅក្នុងនេះ ជាខ្មែរ គឺសូមស្នើមតិអង្គការ។ មានន័យថា សូមអង្គការសម្រេច។

[១៤:១១:២៥]

**ស៖** ប្រសិនបើលោកអាច សូមលោកជួយពន្យល់ដោយត្រួសៗទៅលើគោលដៅ គោលបំណងនៃការប្រជុំនេះ ថាតើការប្រជុំហ្នឹងដើម្បីស្នើមតិ ឬក៏ដើម្បីផ្តល់ព័ត៌មានផ្តល់យោបល់ទៅដល់អង្គភាពទៅដល់កងពល ឬក៏ទៅដល់អង្គភាពផ្សេងៗ?

**ឆ៖** ប្រជុំនេះវាមានទិសដៅសំខាន់គឺ និយាយអំពីស្រូវ។ ទីមួយ និយាយអំពីសភាពការណ៍ខ្មាំងនេះហើយដែលយើងកំពុងតែនិយាយគ្នានេះ ក៏ប៉ុន្តែតទៅទៀត សុទ្ធតែពីរឿងស្រូវទាំងអស់ ហើយនិងបញ្ហាផ្សេងៗបន្តិច។ ដូច្នេះសភាពការណ៍ខ្មាំងនេះ គេលើកយកមករាយការណ៍នៅពេលនេះ ដើម្បីសុំអង្គការសម្រេចសភាពការណ៍ខ្មាំងនៅក្នុងអង្គភាពគេ គេមានចោទអ៊ីចឹងតើអង្គការសម្រេចយ៉ាងម៉េច? នេះហើយដែលហៅថារាយការណ៍ពីក្រោមឡើងលើ តាមរយៈការប្រជុំ។

[១៤:១២:៥០]

**ស៖** ហើយនៅចុងបញ្ចប់នៃរបាយការណ៍ គឺចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ៧៦ តើមន្ទីរ៦២ ហ្នឹងជាអ្វីដែរ? លោកអាចជម្រាបយើងបានទេ ថាតើមន្ទីរ៦២ ហ្នឹងជាអ្វី?

**ឆ៖** មន្ទីរ៦២នេះ បើតាមខ្ញុំចាំគឺមន្ទីរភ័ស្តុភាររបស់មិត្ត ទាញ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំបញ្ចប់ឯកសារមួយនេះ ហើយខ្ញុំសូមឲ្យលោកពិនិត្យទៅលើសេចក្តីសម្រេចរបស់គណៈមជ្ឈិមក្នុងការកម្ទេចទាំងក្នុងជួរបក្ស និងក្រៅបក្ស។ ខ្ញុំគិតថាប្រហែលជាលោកមានឯកសារនៅចំពោះមុខហើយ គឺឯកសារលេខ IS63។ យើងបានពិភាក្សាអំពីភាពខុសគ្នា។ បានន័យថា អំពីគណៈកម្មាធិការខុសៗគ្នា ព្រមទាំងសេនាធិការដែលមានសិទ្ធិក្នុងការសម្រេច។ ដូច្នេះដើម្បីឲ្យច្បាស់លាស់នៅពេលដែលយើងពិនិត្យទៅលើមាត្រា១ គឺសិទ្ធិក្នុងសម្រេចកម្ទេចក្នុងជួរ និងក្រៅ

ប្រទេស ថាតើៗមានក្របខ័ណ្ឌប៉ុន្មានដែរនៅក្នុង-- ថាតើមានក្រុមប៉ុន្មានដែរដែលមានសិទ្ធិក្នុងការសម្រេច?

[១៤:១៤:៤៩]

**ឆ៖** សិទ្ធិដែលសម្រេចកម្មេចនេះ គឺសម្រេចកម្មេចក្នុងជួរ និងក្រៅជួរ។ ក្រៅជួរសំដៅប្រជាជនសុទ្ធសាធ។ អ្នកដែលមានសិទ្ធិសម្រេចកម្មេចនេះ ចែកទៅតាមអង្គភាព។ នៅមូលដ្ឋាន មួយប៉ែកទៅគឺសំដៅឱ្យលេខាភាគមានសិទ្ធិសម្រេចកម្មេច។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតទៅទៀត។

សូមអញ្ជើញលោកមេធាវី!

**លោក អាកឡូវ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានការជំទាស់ ពីព្រោះថាខ្ញុំមិនឃើញថាមានប្រយោជន៍អីទេ ដែលសហព្រះរាជអាជ្ញាចោទសំណួរនេះ ឱ្យៗសាក្សីនេះអានឯកសារមួយនេះ ហើយសូមឱ្យគាត់ផ្តល់សក្ខីកម្មនេះ។ បើសិនជាដើម្បីតែអានតែឯកសារនេះទេ គឺថាយើងអាចអានខ្លួនឯងក៏បានដែរ យើងមិនបាច់ត្រូវការសាក្សីអីនោះទេ។ អ៊ីចឹង ខ្ញុំគិតថានេះមិន-- គឺថាវាមិនពាក់ព័ន្ធនឹងព័ត៌មានដែលថាគាត់អាចផ្តល់ជូនតាមរយៈការដឹងឮរបស់គាត់នោះទេ។ ខ្ញុំគិតថាដូចជាមិនមានប្រយោជន៍អីទេ ក្នុងការអានឯកសារនេះ។ ហើយខ្ញុំមិនយល់ថា ហេតុអីបានជាសហព្រះរាជអាជ្ញាធ្វើយ៉ាងដូច្នេះនោះទេ?

[១៤:១៦:២៩]

**លោក វីណ្សៀម ស្មីត៖**

សូមអរគុណ។ ខ្ញុំគ្រាន់តែចង់ឱ្យសាក្សីគាត់ធ្វើការសង្ខេប ប៉ុន្តែប្រសិនបើនជាមិននេះទេ ឥឡូវយើងបន្តទៅមុខទៀត។

**សួរដោយលោក វីណ្សៀម ស្មីត៖**

**ស៖** សិទ្ធិក្នុងការសម្រេច គឺនិយាយអំពីមន្ទីរមជ្ឈិម គណៈអចិន្ត្រៃយ៍ ព្រមទាំងសេនាធិការ តើលោកយល់ស្របដែរឬទេ?

**លោក ម៉ែខល ផេសមិន៖**

សូមទោស ខ្ញុំសូមជំទាស់។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញា គាត់កំពុងតែឱ្យសាក្សីហ្នឹងធ្វើការបកស្រាយទៅលើឯកសារទាំងអស់នេះ ហើយខ្ញុំគិតថាសំណួរគួរតែសួរថា ថាតើគាត់ចងចាំដែរឬទេ

នៅពេលនោះ? បានន័យថានៅពេលដែលមានឯកសារ-- នៅពេលដែលមានការបញ្ហានោះ? ដូច្នេះវាគ្មានចំណុចនោះ-- គ្មានប្រយោជន៍នោះទេក្នុងការដែលស្នើឱ្យសាក្សីធ្វើការបកប្រែ ឬក៏បកស្រាយទៅលើឯកសារដែលគាត់មិនដែលបានឃើញនោះ ។ សូមអរគុណ។

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រម ប្រសិនៗបើខ្ញុំចង់ឆ្លើយ គឺថាមិនមែនខ្ញុំស្នើឱ្យសាក្សីធ្វើការបកស្រាយទេ។ ប៉ុន្តែ គ្រាន់តែចង់ឱ្យសាក្សីគាត់និយាយបន្ថែមទៅលើព័ត៌មានដែលគាត់បានដឹង គាត់បានយល់ទាក់ទងទៅនឹងចំណុចមួយនេះ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** សាក្សី គណៈអចិន្ត្រៃយ៍មជ្ឈិម ថាតើលោកអាចជម្រាបបានដែរឬទេ ថាតើគណៈអចិន្ត្រៃយ៍មជ្ឈិមហ្នឹងគឺជាអ្វី? គឺ-- ថាតើគណៈមន្ទីរមជ្ឈិមហ្នឹងគឺជាអ្វី?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** គណៈមន្ទីរមជ្ឈិមហ្នឹងគឺសំដៅយកតែម្នាក់ទេ គឺប្រធានគណៈកម្មាធិការមន្ទីរមជ្ឈិមបក្ស។

[១៤:១៨:៤៥]

**ស៖** ថាតើអ្នកណាជាប្រធានគណៈមន្ទីរមជ្ឈិមនោះ?

**ឆ៖** ខ្ញុំបានសរុបជូនការិយាល័យចៅក្រមស៊ើបអង្កេតហើយ ប្រធានគណៈកម្មាធិការមន្ទីរមជ្ឈិមគឺ ខៀវ សំផន។

**ស៖** នៅមុននេះលោកបាននិយាយអំពីបុគ្គលម្នាក់ដែលឈ្មោះ ប៉ង់។ ថាតើ ប៉ង់ មានទំនាក់ទំនង ឬក៏មានសាច់ញាតិអ្វីដែរជាមួយ ខៀវ សំផន ប្រសិនបើលោកដឹង?

**ឆ៖** ខ្ញុំមិនដឹង មិនដែលឮព័ត៌មានណាដែលនិយាយអំពីរឿង ប៉ង់ ហើយនិង ខៀវ សំផន ទាក់ទងគ្នាជាសាច់ញាតិទេ។

**ស៖** ការពិតខ្ញុំចង់-- ខ្ញុំមិនមែនចង់និយាយពីសាច់ញាតិទេ ប៉ុន្តែចង់និយាយពីទំនាក់ទំនងការងារ។ ថាតើលោកដឹងទេថានៅពេលនោះថា តើ ប៉ង់ ហើយនិង ខៀវ សំផន មានទំនាក់ទំនងការងារអ្វីដែរ? ប្រសិនបើលោកដឹង សូមលោកជម្រាបប្រាប់ផង។

**ឆ៖** អរគុណ។ ប៉ង់ ដែលចុះទៅណែនាំខ្ញុំមិនដែលនាំពាក្យ ខៀវ សំផន ទៅឱ្យខ្ញុំទេ គឺនាំពាក្យ ប៉ុល ពត ទៅ។ មិនមែន នួន ជា ទៅទៀត គឺ ប៉ុល ពត។

**ស៖** ថាតើលោកអាចរៀបរាប់បានទេ អំពីមុខងារ ឬក៏តួនាទីរបស់គណៈមន្ទីរមជ្ឈិម? បានន័យថាមន្ទីរដែល ខៀវ សំផន គឺជាប្រធានថា តើមន្ទីរនោះគឺមានតួនាទីអ្វីដែរ? ហើយបំពេញការងារអ្វីដែរ?

[១៤:២១:០៩]

**ឆ៖** ខ្ញុំដឹងៗបានត្រឹមតែការងារដែលខ្ញុំសរុបជូនការិយាល័យសហាចៅក្រមស៊ើបអង្កេតនុ៎ង។ ខ្ញុំឆ្ងាយណាស់ រវាងខ្ញុំហើយនិង ខៀវ សំផន ឆ្ងាយពីគ្នាណាស់។

**ស៖** *(ព្រះរាជអាជ្ញាមិនបើកក្បាលមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញារអត់បើកក្បាលមីក្រូ។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ដូច្នេះជារួម ជាទូទៅ ថាតើលោកអាចផ្តល់ព័ត៌មានអំពីតួនាទី ឬក៏ភារកិច្ចរបស់គណៈមជ្ឈិមនោះទេ? បានន័យថា ជាៗលក្ខណៈទូទៅ មិនមែនជាលក្ខណៈជាក់លាក់ពិសេសអីមួយនោះទេ។ តើលោកអាចផ្តល់បានដែរឬទេ?

[១៤:២២:៣៧]

**លោក កាំង ហ្កេកអ៊ាវ៖**

**ឆ៖** ខ្ញុំដឹងថា--

**លោក អាកឡូវ វែកគែន៖**

លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយនឹងសំណួរ។ សូមអញ្ជើញ លោកមេធាវី!

**លោក អាកឡូវ វែកគែន៖**

បាទ សូមអរគុណ លោកប្រធាន។ បាទ ខ្ញុំជំទាស់ ពីព្រោះថា សហព្រះរាជអាជ្ញានៅតែចោទសំណួរលក្ខណៈបង្វែរ ដែលថាសំណួរនុ៎ង គឺថាជនជាប់ចោទទើបនឹងឆ្លើយរួចហើយ។ អ៊ីចឹងខ្ញុំពុំឃើញមានភាពខុសគ្នារវាងសំណួរទីមួយ ដែលថាតើតួនាទីរបស់ៗ ខៀវ សំផន នោះទេ ហើយៗដែលថា

សាក្សីអត់ដឹងដែរ ឥឡូវសហព្រះរាជអាជ្ញាបកមកចោទសួរសំណួរហ្នឹងដដែលទៀត ដើម្បីឲ្យៗគាត់ឆ្លើយឲ្យខុសពីមុននោះទៀត។ សួរទៅជាថា ឥឡូវតួនាទីទូទៅហ្នឹងយ៉ាងម៉េច? អ៊ីចឹងខ្ញុំគិតថា នេះគឺគាត់កំពុងតែ ន៎ រុកកួនសាក្សីហើយ។ អ៊ីចឹងខ្ញុំគិតថា សូមកុំឲ្យសាក្សីឆ្លើយ។

[១៤:២៣:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្ដីលោក អៀង សារី!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំចង់ឲ្យមានការបកស្រាយបន្ថិចទៅលើចម្លើយពីការមុនហ្នឹង ព្រោះថាលោកសាក្សីបាននិយាយថា គាត់ផ្អែកទៅលើអ្វីដែលគាត់បានប្រាប់ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ទៅតាមអ្វីដែលគាត់ធ្វើបាន ហើយក្នុងការឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា។ ដូច្នេះហើយគួរតែមានសំណួរបន្ត ហេតុអ្វីបានជាមានដូច្នេះ។ ប៉ុន្តែសាក្សីបានបញ្ជាក់ថា គាត់បានផ្តល់ព័ត៌មានទៅសហចៅក្រមស៊ើបអង្កេត ទៅលើឯកសារដែលបានផ្តល់មកចំពោះគាត់ ហើយគាត់បានធ្វើការវិភាគ សិក្សា ហើយគាត់បានផ្តល់នូវចម្លើយ។

[១៤:២៤:៤៦]

ដូច្នេះហើយ អានេះគឺជាអ្វីដែលគាត់បានវិភាគ បានបកស្រាយទៅលើឯកសារ មិនមែនជាអ្វីដែលគាត់ដឹងនោះទេ។ ការពិតទៅ គឺសហចៅក្រមស៊ើបអង្កេតបានផ្តល់នូវឯកសារជាច្រើន ហើយឲ្យទុកពេលឲ្យគាត់រាប់ពេល រាប់ខែ ដើម្បីពិភាក្សា ដើម្បីសិក្សា ហើយដើម្បីទទួលបាននូវចម្លើយនោះ។ ដូច្នេះហើយ ថាតើអានេះគឺជាអ្វីដែលគាត់បានជួប ឬមួយក៏យ៉ាងម៉េច?

ប្រសិនបើជាការពិតមែន ខ្ញុំគិតថាការចោទសួរទាំងអស់ហ្នឹង គឺគួរតែជំទាស់បាន ព្រោះថាគាត់កំពុងតែផ្តល់នូវការវិភាគទៅលើឯកសារ មិនមែនជាការដែលគាត់ទទួលបានដឹងនៅពេលសម័យកាលនោះទេ។ ដូច្នេះក្នុងករណីនេះ គឺអង្គជំនុំជម្រះមានសិទ្ធិក្នុងការសម្រេចទៅលើបញ្ហាទាំងនេះ។ សូមអរគុណ។

[១៤:២៥:៣៦]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ តើលោកចង់តតបទៅនឹងការជំទាស់របស់មេធាវី ឬយ៉ាង

ម៉េច? លោកអាចតបបាន។ តបរួច អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហានេះជាមុន មុននឹងផ្តល់វេទិកាឲ្យលោកបន្តការតាំងសំណួរទៅមុខទៀត។

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ ខ្ញុំគិតថាចម្លើយតប គឺគួរតែមានការសួរសំណួរបន្តទៅបន្តទៀតទៅលើសាក្សីដូចដែលមេធាវីការពារលោក អៀង សារី បានលើកឡើង។ ទោះបីថាព័ត៌មានដែលគាត់បានទទួលដែលផ្តល់សក្ខីកម្មទៅពេលនេះ គឺជាអ្វីដែលគាត់បានទទួលពីឯកសារនៅក្នុងសំណុំរឿង ក៏អត់នោះក៏ដោយ ទោះបីថាគាត់បានទទួលដោយសារព័ត៌មាន ទទួលព័ត៌មានដោយដឹងខ្លួនឯងក៏ដោយ ក៏តម្រូវឲ្យមានការចោទសួរជាបន្តបន្ទាប់។ ដូច្នេះ ខ្ញុំគិតថាគួរតែមានការដេញ សួរដេញដោលបន្តទៅទៀត។

ចំពោះការដែលគាត់ និយាយថាគាត់មិនបានដឹងច្បាស់លាស់អំពីតួនាទីនេះ សំណួរបន្ទាប់របស់ខ្ញុំគឺថាជាទូទៅ ថាតើការិយាល័យហ្នឹង ថាតើគណៈមន្ទីរហ្នឹងមានតួនាទីអ្វីដែរជាទូទៅ?

ការសួរបែបនេះ គឺមិនមែនដើម្បីទាមទារឲ្យគាត់ឆ្លើយនូវអ្វីដែលគាត់ដឹងជាលម្អិតនោះទេ គ្រាន់តែចង់សួរអំពីអ្វីដែលគាត់គិត ដែលគាត់ដឹង ហើយបន្ទាប់មកយើងនឹងអាចសួរឲ្យគាត់ឆ្លើយអំពីកម្រិតណាដែលគាត់អាចដឹង អាចយល់បាន។

[១៤:២៧:២០]

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំសូមបន្ថែមបន្តិចទៀត។ ខ្ញុំគិតថាគួរជាការល្អ ដែលថាយើងគួរតែឲ្យសាក្សីធ្វើការបែងចែកនូវអ្វីដែលគាត់បានដឹងកាលពីសម័យនោះ ហើយនិងអ្វីដែលគាត់បានសិក្សារៀនសូត្រពេលក្រោយមកទៀតតាមរយៈការរៀន សិក្សាឯកសារសម្រាប់សំណុំរឿង០០១របស់គាត់នេះ។ អ៊ីចឹងខ្ញុំថាសុំឲ្យគាត់ធ្វើការបែងចែកចំណុចនេះឲ្យច្បាស់លាស់។

**ប្រធានអង្គជំនុំ៖**

បាទ ការជំទាស់របស់ក្រុមមេធាវីការពារក្តី គ្មានប្រសិទ្ធភាព។ តំណាងសហព្រះរាជអាជ្ញាអាចបន្តសួរទៀតបាន។ ប៉ុន្តែសូមរំឭកតំណាងសហព្រះរាជអាជ្ញាថា គប្បីសួរនូវសំណួរដែលមានលក្ខណៈទូទៅ ហើយចៀសវាងនូវការតាំងសំណួរច្រំដែល សំណួរដឹកមុខ។ សាក្សីដូចគ្នា សូមពិចារណាឡើងវិញ ហើយរៀបចំនូវការបែបផែនក្នុងការឆ្លើយតបសំណួរទៅនឹងសំណួរ វាជាជាងក្នុងការឆ្លើយតបនឹង

សំណួរ ហើយចង្អុលបង្ហាញទៅនឹងកំណត់ហេតុដែលឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ពីព្រោះភាគី ទាំងភាគី ទាំងអង្គជំនុំជម្រះ ប្រសិនបើសាក្សីឆ្លើយដូច្នេះ អង្គជំនុំជម្រះមិនដឹងថាខ្លឹមសារដែលលោកឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះ វាយ៉ាងម៉េចទេ?

[១៤:២៨:៤៨]

ការដេញដោល គឺជាការវិភាគ គឺជាការបកស្រាយ គឺជាការឆ្លើយផ្តល់ព័ត៌មានជាផ្លូវការ ជាសាធារណៈចំពោះមុខអង្គជំនុំជម្រះ និងសាធារណជនអំពីលទ្ធផលនៃដំណើរការសវនាការអសាធារណៈ អ៎! កិច្ចការស៊ើបអង្កេតកន្លងមកនៅដំណាក់កាលពីដើមខ្សែ តាំងពីនគរបាលយុត្តិធម៌ ទាំងពីរសហព្រះរាជអាជ្ញា រហូតដល់សហចៅក្រមស៊ើបអង្កេត។ នោះជាការស៊ើបអង្កេតដោយអសាធារណៈ ដោយសម្ងាត់ ឥឡូវនេះយើងយកមកលាងត្រដាងជាសាធារណៈ ដើម្បីឱ្យភស្តុតាងដែលដេញដោលហ្នឹង គឺយើងយកជាមូលដ្ឋាននៅក្នុងការពិចារណាសម្រេចនៅលើរឿងក្តីហ្នឹង ទីចុងបញ្ចប់ដើម្បីវិភាគពិចារណាថាការស្វែងរកការពិតនោះទៅថ្ងៃមុខនៅក្នុងរឿងក្តីនេះ តើវាទៅយ៉ាងណា? នេះ គឺកំណត់បានថាភាពពិរុទ្ធ មានពិរុទ្ធ ឬក៏គ្មានពិរុទ្ធភាពចំពោះជនជាប់ចោទដែលត្រូវប្រឈមចំពោះមុខអង្គជំនុំជម្រះនៅក្នុងដំណើរការសវនាការនេះ។

សូមរំឭក! សូមបញ្ជាក់បញ្ហានេះ ចៀសវាងយើងឆ្លើយទៅ ហាក់ដូចជាឆ្លើយសំដៅទៅលើកំណត់ហេតុដែលបានឆ្លើយរួចហើយ នៅដំណាក់កាលចៅក្រមស៊ើបអង្កេតនោះ ហាក់ដូចជាបិទនូវព័ត៌មានហ្នឹង មិនដឹងថាខ្លឹមសារនោះយ៉ាងដូចម្តេចទេ។ វាលុះត្រាតែយើងចាំនូវខ្លឹមសារនោះ យើងអាចដកស្រង់នូវខ្លឹមសារយកមកលាតត្រដាងចំពោះមុខអង្គជំនុំជម្រះ និងសាធារណជនបានដឹង។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:៣០:២៦]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** សាក្សីតាមការដឹងរបស់លោកនៅពេលនោះ បានន័យថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថាតើលោកដឹងដែរឬទេ អំពីតួនាទី និងភារកិច្ចនៃគណៈមន្ទីរមជ្ឈិម បានន័យថាមិនមែនអ្វីដែលលោកបានរៀននៅពេលក្រោយនោះទេ?

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** អរគុណ។ ខ្ញុំសូមភ្ជាប់ចម្លើយរបស់ខ្ញុំទៅនឹងសហព្រះរាជអាជ្ញា ទៅនឹងសេចក្ដីណែនាំរបស់លោកប្រធាននៃអង្គជំនុំជម្រះ ហើយសូមឆ្លើយដូចតទៅ៖

អំពីកាលដែលខ្ញុំបានពន្យល់ជូនសហចៅក្រមស៊ើបអង្កេត។ ខ្ញុំអត់និយាយអំពីរឿងតួនាទីរបស់មន្ទីរមជ្ឈិមទេ។ ខ្ញុំនិយាយអំពីតួនាទីរបស់ ខៀវ សំផន នោះតែម្ដង។ នៅពេលដែលសម្រេចចាប់ ជូ ជេត ហៅ ស៊ី ខ្ញុំគិតថាតើ វន វ៉េត មានមតិម៉េចការពារ ជូ ជេត ហៅ ស៊ី ទេ។ ពីព្រោះខ្ញុំដឹងថា ជូ ជេត ហៅ ស៊ី នោះ ទំនាស់គ្នាជាមួយ អ៊ុង ជឿន ហៅ ម៉ុក។ ហើយខ្ញុំឃើញ វន វ៉េត នេះ ជាមនុស្សកណ្ដាល។ ដល់ខ្ញុំចោទសួរ ប៉ង់ អ៊ីចឹងទៅ ប៉ង់ថា អ្ហ៎! ស-២១ មនុស្សបង វន នេះ មនុស្សពិបាកធ្វើការជាមួយណាស់ ជួនអីទៅអង្គុយកំពែកំពៅនៅក្នុងប្រជុំ។

[១៤:៣២:១២]

ហើយថ្ងៃប្រជុំដើម្បីសម្រេចចាប់ ជូ ជេត ហៅ ស៊ី ឬមិនចាប់នេះ វន វ៉េត នៅនុំង បងវន គាត់នៅនុំង ក៏ប៉ុន្តែ បងប៉ុល មិនឲ្យខ្ញុំទៅអញ្ជើញ បងវន ចូលរួមទេ បែរជាឲ្យទៅអញ្ជើញ បងហែម ចូលរួមវិញ។ នេះជាព្រឹត្តិការណ៍មួយដែលខ្ញុំឮច្បាស់នៅពេលនោះ។ ទាក់ទងនឹងការសម្រេចប្រជុំគ្នាសម្រេច ជូ ជេត ហៅ ស៊ី។

ក្រោយមកទៀត និយាយអំពីថាតើ ខៀវ សំផន មានអង្គភាពកាន់កាប់ទេ? ខ្ញុំលើកយកចម្លើយរបស់មនុស្សម្នាក់ឈ្មោះ យក់ ជួង ហៅ ជន ប្រធានរោងចក្រអគ្គិសនីចាក់អង្រែ ឆ្លើយថា លោក ខៀវ សំផន នេះណែនាំឲ្យក្បត់។ ធ្វើឲ្យល្អក៏មាន ធ្វើតាមផ្លូវក្បត់ក៏មានដែរ។ ដូច្នេះ យើងត្រូវធ្វើឲ្យល្អ ដើម្បីកុំឲ្យអង្គការគេសង្ស័យ ហើយត្រូវធ្វើតាមផ្លូវក្បត់។ នៅពេលហ្នឹងហើយ ដែលខ្ញុំទៅរាយការណ៍សុំយោបល់សម្រេចពីបងនួន។ បងនួន សម្ដុតខ្ញុំ ថាម៉ាស្រុកខ្មែរអស់រលីងណ៎ា នៅសល់តែខ្ញុំ និងបង ប៉ុលទេ។ ឥឡូវមិត្តហែម ទៅទៀត មិត្តចង់ម៉េច? ទៅធ្វើទូតអ្ហែះ! នេះជាព្រឹត្តិការណ៍ពិតដែលខ្ញុំដឹង។ ហើយរឿងនេះ វាៗចេញមកអ៊ីចឹង ហើយខ្ញុំបានជម្រាបសហព្រះរាជអាជ្ញាទៀតថា បងហែម នេះមិនមែនដណ្ដើមនាទីរបស់ សឿ វ៉ាស៊ី ហៅ ឌឿន ដូច ដេវីដ ឆេនដ័ល័រ សរសេរទេ គឺគេមានកិត្តិយសរបស់គេ គេមិនដណ្ដើមទេ។ ហែម ហ្នឹងធំជាង សឿ វ៉ាស៊ី ហៅ ឌឿន ហ្នឹងទៀត។ នេះ ខ្ញុំបំភ្លឺសហព្រះរាជអាជ្ញាអ៊ីចឹង-- អ្ហ៎! សហចៅក្រមស៊ើបអង្កេតអ៊ីចឹង។ ហើយខ្ញុំថា ដោយសារប្រតិកម្មមិត្តជន, យក់ ជួង ហៅ ជន នេះអ៊ីចឹង បានខ្ញុំថា បងហែម នេះ មានអង្គភាពកាន់កាប់ មានអង្គភាពដឹកនាំ។

[១៤:៣៤:១៦]

អង្គភាពច្បាស់លាស់ជាងគេ គឺអគ្គីសនីផ្សារតូច។ ដល់ក្រោយមកទៀត សហចៅក្រមស៊ើបអង្កេតយកឯកសារដែលខាងពាណិជ្ជកម្ម គេន៎សុំយោបល់ បងហែម ពីរឿងទិញអីវ៉ាន់ មកបង្ហាញខ្ញុំ។ ខ្ញុំយល់ថា រឿងនេះអាចជារឿងពិត ពីព្រោះម្ហូងហ្នឹង គេមាននិយាយអំពីក្រុមហ៊ុនប្រេគ្គនហ្មុងអីៗហ្នឹង។ ខ្ញុំថា អូ្ហ! ឯកសារហ្នឹងពិតហើយ។ ខ្ញុំជម្រាបហ្នឹងទៅ ខ្ញុំថាបងវិត នេះ សុំយោបល់បងហែម។ ដូចបងវិត-- អ៎! បងហែម នេះ មិនមែនមានត្រឹមតែអគ្គីសនីចាក់អង្រែទេ គាត់ត្រួតទាំង ន៎នេះទៅទៀតពាណិជ្ជកម្មទៀត។ ឯចំណែករឿងមួយទៀត ដែលខ្ញុំធ្វើជាភស្តុតាងសម្រាប់បញ្ជាក់ថា បងហែម នេះកាន់កិច្ច-- មានអង្គភាពកាន់កាប់ សំបុត្រដើរផ្លូវរបស់ខ្ញុំមុនដំបូងស៊ីញេ ខៀវ ស៊ីញេ យឹម។ យឹម នេះជាឈ្មោះរបស់ ខៀវ សំផន អ៊ំ សុន សេន ស៊ីញេសំបុត្រដើរផ្លូវ ហើយដល់បង ហែម គាត់សរសេរគាត់ដាក់ “ខាង”។ រួចការិយាល័យសហចៅក្រមស៊ើបអង្កេតដេញដោលសួរថា “ខាង” នេះយ៉ាងម៉េច? ស្អីយ៉ាងម៉េច? មិត្តដែលឃើញអក្សរខាង ហ្នឹងដែរទេ? ខ្ញុំសួរ ប៉ង់ ថា “ខាង” ហ្នឹងអ្នកណា? ប៉ង់ ថា “ខាង” ហ្នឹងគឺបង ហែម។ ហើយបានខ្ញុំប្រាប់ឥឡូវសំបុត្រដើរផ្លូវហ្នឹង អាចនៅស-២១ ទេ ការិយាល័យសហព្រះរាជអាជ្ញាទៅរកមើលទៅ។

ដូច្នេះរឿងរ៉ាវដែលខ្ញុំដឹង ហើយដែលខ្ញុំរាយការណ៍ជូននេះ ប៉ុណ្ណឹង។ ថា បងហែម នេះជាប្រធានមន្ទីរ៧មជ្ឈិម ហើយមានចេញសំបុត្រដើរផ្លូវដោយមានចុះហត្ថលេខា “ខាង” ហើយបានចូលរួមប្រជុំជាមួយអចិន្ត្រៃយ៍មជ្ឈិម តាមសម្តី ប៉ង់។ ខ្ញុំមិនជឿថាសម្តី ប៉ង់ ហ្នឹងភរទេ។ នេះខ្ញុំលើកបញ្ហានេះប៉ុណ្ណឹង។ ឯចំណែកភារកិច្ចរបស់មន្ទីរមជ្ឈិមស្អីខ្លះ? ខ្ញុំមិនច្បាស់ទេ ដឹងតែអង្គភាពពីរ អង្គភាពទីមួយគឺពាណិជ្ជកម្ម អង្គភាពទីពីរគឺរោងចក្រចាក់អង្រែ។ នេះការដែលខ្ញុំដឹងច្បាស់។ នេះខ្ញុំសូមសរុបប៉ុណ្ណេះ។

[១៤:៣៦:៣៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំមានសំណួរមួយចង់ឲ្យបញ្ជាក់បំភ្លឺ ដោយសារតែចម្លើយវែង តើចម្លើយរបស់គាត់នោះផ្អែកទៅលើចម្លើយសារភាពដែលគាត់មើល ឬក៏ផ្អែកទៅតាមអ្វីដែលលោក ដេវីដ ឆេនដ័ល័រ បានលើកឡើង? ខ្ញុំហាក់ដូចជាវិលវល់អស់ហើយ។

**លោក វីល្លៀម ស្មីត៖**

នេះគឺជារបៀបដែលយើងតាំងសំណួរ ហើយខ្ញុំនឹងសួរបញ្ជាក់បំភ្លឺផងដែរនាពេលក្រោយមក។ យើងខ្ញុំសូមជម្រាបថា នៅពេលនេះគឺខ្វះម្ភៃទៀតម៉ោងបី ហើយខ្ញុំនៅមានសំណួរមួយចំនួនដែលខ្ញុំចង់សុំសួរបន្ត។ ដូច្នេះហើយ តើចង់ឲ្យខ្ញុំចាប់ផ្ដើមនៅពេលនេះ ឬក៏យើងឈប់សម្រាក ឲ្យខ្ញុំចាប់ផ្ដើមក្រោយពេលសម្រាក?

[១៤:៣៧:៣៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងអញ្ជើញសាក្សីទៅកាន់បន្ទប់រង់ចាំសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់បន្ទប់សវនាការវិញ កន្លែងផ្ដល់សក្ខីកម្មនេះបានមុនអង្គជំនុំជម្រះចូលកាន់អាសនៈ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៨នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលសំណួរចំពោះសាក្សីរូបនេះ។

បាទ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណ លោកប្រធាន។ សួស្ដី អស់លោក លោកស្រីចៅក្រមទាំងអស់។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សីមុនពេលដែលយើងសម្រាក លោកបានផ្តល់នូវព័ត៌មានមួយចំនួនទាក់ទងទៅនឹងអ្វីដែលលោកជឿជាក់ថា ជាតួនាទីរបស់ ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំចង់សួរបន្តទៅទៀត ដើម្បីបញ្ជាក់លម្អិតទៅលើករណីមួយចំនួនដែលលោកបាននិយាយយោងនៅក្នុងចម្លើយខាងមុន។ ហើយជាពិសេស ខ្ញុំចង់បញ្ជាក់ទៅលើអ្វីដែលលោកបាននិយាយពាក់ព័ន្ធទៅនឹងបុគ្គលដែលចុះហត្ថលេខានៅទៅលើលិខិតធ្វើដំណើររបស់លោកនៅពេលដែលលោកនៅធ្វើការនៅមន្ទីរស-២១?

ជាដំបូងមុននឹងខ្ញុំសួរសំណួរមួយនេះថា តើលោកអាចជម្រាបមកតុលាការបានដែរឬទេ? ហេតុអ្វីបានជាលោកត្រូវការលិខិតធ្វើដំណើរនៅពេលដែលលោកធ្វើការនៅមន្ទីរស-២១?

[១៥:០១:៥៤]

**លោក កាំង ហ្គេកអ៊ាវ៖**

**ឆ៖** ខ្ញុំសូមឆ្លើយមួយម៉ាត់។ គ្រប់យុទ្ធជន កម្មាភិបាលទាំងអស់ ដែលធ្វើដំណើរនៅក្រុងភ្នំពេញត្រូវតែមានលិខិតដើរផ្លូវ ទោះបីនៅក្រុងភ្នំពេញក៏ដោយ ត្រូវតែមានលិខិតដើរផ្លូវជាចាំបាច់។

**ស៖** ថាតើលិខិតដើរផ្លូវហ្នឹង ថាតើវាមានសុពលភាពសម្រាប់តែការធ្វើដំណើរម្តង ឬមួយមានសុពលភាពរយៈពេលកំណត់ជាក់លាក់ណាមួយ?

**ឆ៖** សុពលភាពនៃលិខិតដើរផ្លូវ បើតាមខ្ញុំចាំគឺប្រាំមួយខែ។

**ស៖** នៅពេលដែលលោកនៅមន្ទីរស-២១ ថាតើលោកធ្វើការផ្លាស់ប្តូរលិខិតដើរផ្លូវហ្នឹងថ្មីប្រហែលជាប៉ុន្មានដងដែរ បានន័យថា តើលោកត្រូវផ្លាស់ប្តូរលិខិតដើរផ្លូវថ្មីហ្នឹងប៉ុន្មានដងដែរ?

[១៥:០៣:២៣]

**ឆ៖** ខ្ញុំមិនចាំទេ ក៏ប៉ុន្តែដល់ពេលផ្លាស់ខាងសេនាធិការគេផ្លាស់ ដំបូងខ្ញុំកាន់លិខិតដើរផ្លូវរបស់សេនាធិការ ដែលមេខ្ញុំ សុន សេន គាត់ស៊ីញ៉េ។ គាត់នេះមានឈ្មោះមួយទៀតនៅពេលស៊ីញ៉េលិខិតដើរផ្លូវ ឈ្មោះ ឃឹម មិនមែនឈ្មោះ ខៀវ ទេ ឈ្មោះ ឃឹម។

**ស៖** ដូច្នេះនៅពេលនោះគឺ សុន សេន តើមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ថាតើលោកអាចពន្យល់តុលាការបានដែរឬទេថា តើនៅពេលនោះ ហេតុអ្វីក៏បុគ្គលខ្លះគាត់មានឈ្មោះហៅក្រៅពីរបី មិនមែនមានតែមួយ។ តើលោកអាចជម្រាបបានឬទេថា ហេតុអ្វី?

**ឆ៖** ដោយឡែកមេខ្ញុំឈ្មោះមិនដឹងប៉ុន្មានទេ កងទ័ពគេហៅ បង៨៩ ហ្នឹងក្នុងកងទ័ព។ ដោយឡែកមន្ទីរស-១២ សរសេរសំបុត្រទៅគាត់ សរសេរថា “គោរពជូន បង៦២” ឈ្មោះជាទូទៅរបស់គាត់ដែលគេហៅក្រៅ “ខៀវ”។ ហើយឈ្មោះដែលគាត់សរសេរក្នុងលិខិតដើរផ្លូវហ្នឹង ឃឹម។

**ស៖** លោកនិយាយថា លោកផ្តល់សក្ខីកម្មនៅក្រោយថា លិខិតដើរផ្លូវរបស់លោកចុះហត្ថលេខាដោយ ខៀវ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជាហូរហែតាំងពី៧៥ លិខិតដើរផ្លូវរបស់ខ្ញុំចុះហត្ថលេខាដោយ ឃឹម គឺ សុន សេន។

**ស៖** ដូច្នេះខ្ញុំយល់ច្បាស់ ថានៅពេលក្រោយមកទៀត ថាតើលិខិតហ្នឹងត្រូវចុះហត្ថលេខាដោយឈ្មោះផ្សេង តើមែនឬទេ?

[១៥:០៦:០៩]

**ឆ៖** មុននឹងៗបានលិខិតដើរផ្លូវថ្មីនេះមក ប៉ង់ ប្រមូល។ ថាឥឡូវសុំឈ្មោះមក កម្មាភិបាលណាខ្លះដែលត្រូវចេញដំណើរក្រៅស-២១ ដើម្បីធ្វើលិខិតដើរផ្លូវឲ្យ ព្រោះលិខិតដើរផ្លូវចាស់អស់សុពលភាពហើយ។ ខ្ញុំក៏ឲ្យទៅ ដល់ខ្ញុំឲ្យឈ្មោះទៅ មួយសន្ទុះឃើញ ប៉ង់ យកលិខិតដើរផ្លូវមកឲ្យខ្ញុំវិញ។ ខ្ញុំសួរថាអ្នកណា ខាង? ប៉ង់ គាត់ឆ្លើយថា ខាង ហ្នឹង បងហែម។ ដល់ឮគេប្រាប់ថា បងហែម អ៊ីចឹង ខ្ញុំមើលទៅអក្សរនៅក្នុងលិខិតដើរផ្លូវនោះ ហើយនិងអក្សរដែលគាត់ដាក់ឈ្មោះ ខាង នុ៎ង ខ្ញុំនឹកឃើញថាប្រហែលជាពិត។ អ្ហ៎ ប្រហែលជាពិតអី គឺពិត ព្រោះខ្ញុំធ្លាប់ឃើញអក្សរ បងហែម ម្តង សរសេរទៅមិត្តភក្តិគាត់ដែលជាប្រធានមន្ទីរ៣០៥ ភូមិភាគពិសេស។

**ស៖** បងហែម ថាតើអ្នកណាជា បងហែម?

**ឆ៖** ជារបស់ ខៀវ សំផន។ បងហែម ឈ្មោះរបស់ ខៀវ សំផន។

[១៥:០៧:៤២]

**ស៖** ថាតើ ប៉ង់ មានប្រាប់លោកដែរឬទេ ថាហេតុអ្វីបានជា ខៀវ សំផន គឺជាអ្នកចុះហត្ថលេខាទៅលើលិខិតដើរផ្លូវរបស់លោក?

**ឆ៖** ខ្ញុំមិនដឹងទេ អត់ប្រាប់ទេ អត់សួរផង ខ្ញុំមិនសួរ។

**ស៖** ថាតើលោកចាំបានដែរឬទេ ថាតើនៅពេលណាដែលលិខិតដើរផ្លូវរបស់លោកត្រូវចុះហត្ថលេខាដោយ បងហែម?

**ឆ៖** ខ្ញុំមិនចាំខែទេ ក៏ប៉ុន្តែខ្ញុំចាំច្បាស់ថា លិខិតដើរផ្លូវនេះជាលិខិតផ្លូវតែមួយគត់ដែលខ្ញុំប្រើ។

ហើយខ្ញុំទុកលិខិតដើរផ្លូវនេះមិនមែននៅផ្ទះខ្ញុំទេ នៅការិយាល័យរបស់ មិត្តធី, សួស ធី។ អ៊ីចឹងហើយបាន១ ខ្ញុំថាលិខិតដើរផ្លូវរបស់ខ្ញុំពិតជានៅសល់ គេប្រមូលយកបាន សម្រាប់ជាភស្តុតាង។

[១៥:០៨:៥២]

**ស៖** ប្រសិនបើយើងអាចនិយាយអំពី ប៉ង់ គឺលោកនិយាយថា គាត់គឺជាប្រធានស-៧១។ ថាតើមានសម្ពតិកម្ម ឬក៏មានការសន្មតអ្វីដែរនៅ-- ថាតើវាជាតួនាទីមួយ ឬតួនាទីខ្ពស់ ឬតួនាទីទាបនៅរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** យើងមើលតួនាទីរបស់ ប៉ង់ ទើបដឹងថាតើស-៧១ វាសំខាន់ប៉ុនណា? ប៉ង់ ជាជំនួយការមជ្ឈិម បុគ្គលទីមួយ។ ដូច្នេះ បងអន-- ចេង អន ដែលអាយុច្រើនជាង ប៉ង់ ក៏ហៅ ប៉ង់ បងដែរ។ ហើយ ចេង អន ក៏នៅក្នុងជំនួយការជម្មិមដូចគ្នាដែរ។

**ស៖** ហើយ ប៉ង់ គឺថាតើអ្នកណាគឺជាមេកោយផ្ទាល់របស់ ប៉ង់?

**ឆ៖** មេកោយផ្ទាល់របស់ ប៉ង់ ដូចខ្ញុំបានបញ្ជាក់រួចពីមុននេះមកហើយ។ ប៉ង់ ទៅជួបខ្ញុំ មិនដែលនាំពាក្យ ខៀវ សំផន ទៅរកខ្ញុំទេ គឺនាំពាក្យ ប៉ុល ពត ទៅរកខ្ញុំ។

**ស៖** ថាតើលោកធ្លាប់ជួប ប៉ង់ នៅកន្លែងផ្សេងដែរឬទេ? បានន័យថានៅក្រៅមន្ទីរស-២១ដែរឬទេ?

**ឆ៖** ប៉ង់ ធ្លាប់ឲ្យខ្ញុំជូនដើរ ឲ្យខ្ញុំជូនដើរទៅជួប ចេង អន ប្រធានឧស្សាហ៍កម្មម្តង ហើយនិងឲ្យខ្ញុំជូនដើរទៅជួប បងរិត ប្រធានពាណិជ្ជកម្មម្តង។

[១៥:១១:២៤]

**ស៖** នៅក្នុងពេលនោះ ថាតើធ្លាប់ទៅការិយាល័យនីរសារដែរឬទេ? បានន័យថាការិយាល័យនីរសារដែលលោកបាននិយាយពីមុនមក?

**ឆ៖** ខ្ញុំធ្លាប់ទៅការិយាល័យនីរសារ ក-៧ នៅមាត់ទន្លេ ខ្ញុំទៅ ដូចជាអាចបីដង។

**ស៖** ថាតើ ក-៧ ពេលនោះគឺជាអ្វី? តើលោកដឹងនៅពេលដែលលោកនៅមន្ទីរស-២១ ឬក៏លោកដឹងអំពី ក-៧ ហ្នឹងនៅពេលក្រោយ?

**ឆ៖** មិនពេលក្រោយទេ គឺនៅក្នុងពេល ស-២១។ ដំបូងមេឲ្យគេមកហៅខ្ញុំទៅជួប គាត់នៅកន្លែងនុំង ដើម្បីឲ្យខ្ញុំទៅរង់ចាំទទួល សួស នៅ ហៅ ឈូក នៅកន្លែងនុំង។

**ស៖** នៅពេលដែលលោកទៅទីនោះ ដើម្បីជួបគាត់ ថាតើមានអ្វីកើតឡើង?

**ឆ៖** នៅពេលដែលគាត់ហៅខ្ញុំទៅជួបគាត់នុំង គឺឲ្យខ្ញុំស្គាល់កន្លែង នេះវត្ថុទីមួយ។ វត្ថុបំណងទីពីរ គឺឲ្យ មិត្តគី ប្រធាន ក-៧ នេះស្គាល់ខ្ញុំ ខ្ញុំស្គាល់ មិត្តគី សម្រាប់ទាក់ទងការងារនៅពេលទទួល ស្ងួស នៅ ហៅ ឈូក។

**ស៖** ថាតើលោកបានទទួល ឈូក ហ្នឹងពីការិយាល័យហ្នឹង ឬមួយក៏លោកទៅទទួល ឈូក ហ្នឹងនៅកន្លែងផ្សេង?

**ឆ៖** សំណួរនេះ ខ្ញុំសូមបញ្ជាក់ថា មេហៅខ្ញុំឲ្យទៅ ក-៧ ដើម្បីរង់ចាំទទួលឈូកនៅ ក-៧ ខ្ញុំអត់ទៅទទួលកន្លែងផ្សេងឯណាទៀតទេ គឺខ្ញុំរង់ចាំតែថ្ងៃគេមកដល់ មេប្រាប់ ន្ទាលនឹងទៅទទួលនៅ ក-៧ហ្នឹង។ ដូច្នេះ ក-៧ ជាកន្លែងដែលមេឲ្យខ្ញុំទៅស្គាល់ ដើម្បីទៅរង់ចាំ ឈូក នៅនុំង។

[១៥:១៤:១៧]

**ស៖** លោកបាននិយាយថា មេរបស់លោកបានបង្គាប់ឲ្យលោកទៅទីនោះ ថាតើលោកមេរបស់លោកហ្នឹងជាអ្នកណា?

**ឆ៖** សុន សេន។

**ស៖** ខ្ញុំមានសំណួរពីរបីបន្តទៅទៀត។ នៅពេលដែលលោកទៅមន្ទីរ ក-៧ ហ្នឹងថាតើលោកៗពិតជាទទួល ស្ងួស នៅ នៅចំណុចនោះ តើមែនឬទេ?

**ឆ៖** ត្រឹមត្រូវ។ ថ្ងៃដែល ស្ងួស នៅ ហៅ ឈូក មកដល់ ខ្ញុំទៅទទួលចំពេលដែល ស្ងួស នៅ ហៅ ឈូក មកដល់។

[១៥:១៥:០៧]

**ស៖** ថាតើមានអ្នកណាផ្សេងទៀតទេ នៅមន្ទីរហ្នឹង នៅពេលដែលលោកនៅដល់មន្ទីរនោះ?

**ឆ៖** ខ្ញុំយកឡានមួយទៅ កូនឡានតូចដែលដឹកបានទម្ងន់៥០០គីឡូទៅ។ ដូច្នេះខ្ញុំមានកងពិសេសរបស់ខ្ញុំទៅ។ ខ្ញុំជិះម៉ូតូ។ នៅពេលដែល ស្ងួស នៅ ហៅ ឈូក មកដល់ អង្គភាពខ្ញុំក៏ទៅទទួល។ ស្ងួស នៅ ហៅ ឈូក ដាក់ឡាន ហើយខ្ញុំក៏ជិះម៉ូតូមកតាមមក។ មកដល់កន្លែង ទើបបានកងពិសេសរបស់ខ្ញុំម្នាក់ឈ្មោះមិត្ត ស្រ៊ី ប្រាប់ថាបងទីពីរ គឺបង នួន ឬ នួន ជា នេះ ទៅលបមើល។ គាត់ឈរលបមើល គាត់មិនឲ្យខ្ញុំនេះទេ ខ្ញុំអត់បានឃើញគាត់ទេ។ តែខ្ញុំជឿបញ្ហានេះ។

**ស៖** សូម-- ខ្ញុំសូមបញ្ជាក់គឺថាលោកនិយាយថា នៅពេលនោះ បង នួន គាត់ទៅលួចមើលសកម្មភាពរបស់លោក ថាតើលោកបានឃើញបង នួន នៅទីនោះ ឬក៏អត់ទេ?

**ឆ៖** ខ្ញុំបានជម្រាបរួចហើយ ថាខ្ញុំអត់មានឃើញទេ មិត្តស្រី គេឃើញ ហើយគេមកប្រាប់ខ្ញុំ។ មិនដឹងជាឃើញប៉ុន្មាននាក់ទេ ប៉ុន្តែ មិត្តស្រី គាត់ថាគាត់ឃើញ ហើយគាត់មកប្រាប់ខ្ញុំ។

**ស៖** ថាតើអ្នកណាជាសមមិត្ត ស្រី នោះ?

**ឆ៖** មិត្តស្រី ជាសមាជិកគណៈកម្មាធិការកងពិសេសរបស់ខ្ញុំ របស់ ស-២១។

[១៥:១៧:៣៨]

**ស៖** ថាតើមន្ទីរក-៧ ហ្នឹង មានមុខងារអ្វីដែរ? តើមានសកម្មភាពអ្វីកើតឡើងខ្លះ នៅមន្ទីរក-៧ នោះ?

**ឆ៖** នៅមន្ទីរក-៧ នេះ ខ្ញុំទៅម្តងទៀត យប់ ចាំទទួលអ្នកទោសមកពីខាងឧត្តរ។ អាហ្នឹងជារឿងមួយទៀតដាច់ដោយឡែកទេ។

**ស៖** ថាតើមន្ទីរក-៧ មានគោលដៅដែរឬទេ? មានគោលដៅអ្វីដែរ? ហើយថាតើមានតួនាទីអ្វីដែរនៅមន្ទីរក-៧ហ្នឹង? តើលោកអាចជម្រាបបានទេ?

**ឆ៖** នៅមន្ទីរក-៧ នេះ ខ្ញុំឃើញសង់ត្រាល់ទូរស័ព្ទគេនៅនុំងមួយ ពីព្រោះខ្ញុំពេលដែលទទួលមនុស្សមកពីឧត្តរនេះ ខ្ញុំត្រូវការទូរស័ព្ទទៅមេ។ ដូច្នេះ គេនាំខ្ញុំចូលទៅ ឃើញសង់ត្រាល់ទូរស័ព្ទគេនៅនុំងមួយ។ នេះដែលខ្ញុំឃើញ។ តែឯកសារទាំងអស់ ដែលផ្ញើមកពីលេខាភូមិភាគមកមជ្ឈិម គឺត្រូវផ្ញើមក ក-៧។ ក-៧ អ្នកបានទទួលឯកសារភ្លាម រត់ទៅយកទៅក្នុងមន្ទីរមជ្ឈិម។ នេះជាកិច្ចដំណើរការរបស់នីរសារនៅខាងក្រៅ។

[១៥:១៩:២៧]

**ស៖** ថាតើនៅពេលនោះ លោកដឹងទេ ថាតើអ្នកណាជាអ្នកបែងចែកឯកសារ ឬក៏សំបុត្រនានាពី ក-៧ ទៅមន្ទីរនានា ថាតើលោកដឹងដែរឬទេ អ្នកណាជាអ្នកបែងចែកឯកសារទាំងអស់នោះ?

**ឆ៖** ក-៧ ទទួលសំបុត្រពីភូមិភាគយកទៅជូនខាងលើ ទៅជូនបង ប៉ុល។ អត់បែងចែកទៅណាទេ ហើយចាំទទួលភ្ញៀវ។

**ស៖** ថាតើមានបុគ្គលិកអចិន្ត្រៃយ៍នៅទីនោះដែរឬទេ? ថាតើមានបុគ្គលិកត្រឹមតែម្នាក់ពីរនាក់ ឬមួយក៏មានបុគ្គលិកច្រើននៅទីនោះ?

**ឆ៖** ខ្ញុំក្តាប់មិនបានតែ ប៉ុន្តែខ្ញុំស្គាល់ច្បាស់ មិត្តគី ប្រធានមន្ទីរក-៧ ដែល សុន សេន ហៅខ្ញុំទៅបង្ហាញឧទ្ទេសនាមឲ្យស្គាល់គ្នា។

**ស៖** ថាតើតួនាទីសំខាន់របស់ គី ហ្នឹង គឺអ្វី?

**ឆ៖** គាត់ជាប្រធានមន្ទីរនីរសារ។

**ស៖** ថាតើលោកដឹងដែរឬទេ ថាតើមានបុគ្គលិកនីរសារប៉ុន្មានរូបនៅមន្ទីរនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ ខ្ញុំជម្រាបហើយតើ ខ្ញុំអត់ដឹងទេ។

**ស៖** លោកបានផ្តល់សក្ខីកម្ម ថាតើមន្ទីរក-៧ នៅពេលដែលលោកធ្វើការនៅមន្ទីរស-២១ ថាតើលោកដឹងដែរឬទេ ថាតើមានមន្ទីរ "ក" ដទៃទៀតណាដែរឬទេ នៅពេលដែលលោកធ្វើការនៅមន្ទីរស-២១នោះ ឬមួយក៏លោកអត់ដឹងទេ?

**ឆ៖** ខ្ញុំស្គាល់តែមួយហ្នឹងឯង ក-៧ បានទៅដល់ បានធ្វើការងារនៅទីនោះ។ ផ្សេងទៀត ខ្ញុំមិនដឹង។

[១៥:២២:៣៤]

**ស៖** សូមអរគុណ។ ឥឡូវនេះ យើងសូមនិយាយអំពី ប៉ង់ វិញម្តង តើលោកជួប ប៉ង់ ញឹកញាប់បែបណាដែរ?

**ឆ៖** ប៉ង់ ខ្ញុំជួបញឹក។ តាំងពីខ្ញុំបែកពី សុន សេន ទៅ ម៉ុាង បងនួន គាត់ ហៅទៅធ្វើការបីបួនថ្ងៃម្តង ម៉ុាង ប៉ង់ មក។ ប៉ង មកអាចណែនាំបញ្ហាអីក៏បានដែរ អាចស្តាប់ចម្លើយរបស់អ្នកសារភាពក៏បានដែរ។ នេះតួនាទីរបស់គេ។

**ស៖** តើលោកដឹងដែរ-- នៅពេលមុននេះលោកបាននិយាយថា ប៉ង់ ត្រូវបានគេចាប់យកទៅដាក់មន្ទីរស-២១ ថាតើលោកដឹងដែរឬទេ មានអ្វីកើតឡើងចំពោះ ប៉ង់ នៅពេលដែលគេចាប់គាត់?

**ឆ៖** ឥឡូវលោកចង់សួរថាម៉េច? ចង់សួរថាទារុណកម្ម ឬអត់ ឬយ៉ាងម៉េច?

**ស៖** ខ្ញុំជឿថា លោកបានផ្តល់សក្ខីកម្មថា ប៉ង់ ត្រូវបានគេចាប់ ហើយយកទៅមន្ទីរស-២១ ថាតើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

[១៥:២៤:១៨]

**ស៖** ថាតើគេមានធ្វើទារុណកម្មគាត់ដែរឬទេ នៅមន្ទីរស-២១?

**ឆ៖** ប៉ង់ ធ្វើ។ ខ្ញុំជម្រាបសហព្រះរាជអាជ្ញា ឲ្យអស់ម្តងទៀត។ អ្នកដែលអត់ធ្វើទារុណកម្មមានតែម្នាក់គត់គឺ កុយ ធួន ក្រៅពីនោះធ្វើទាំងអស់។ យឹម សម្បត្តិ តែម្តងគត់នៅពេលដែលឲ្យគាត់

សារភាពថា គាត់ជាអ្នកបោកគ្រាប់បែក ផុតពីនោះមកមានធ្វើទារុណកម្មទៀត។ ដូច្នេះតែម្នាក់គត់គឺ កុយ ធួន ដែលអត់ធ្វើទារុណកម្ម។

**សៈ** លោកបានផ្តល់សក្ខីកម្មថា ប៉ង់ បាននិយាយជាមួយលោកអំពីសេចក្តីសម្រេចក្នុងការចាប់ ជូ ជាតិ (ស៊ីក) សំណួររបស់ខ្ញុំគឺថានៅពេលដែល ប៉ង់ ជម្រាបលោកបែបនេះ ថានៅពេលដែលគាត់ត្រូវបានគេចាប់ទៅមន្ទីរស-២១ ឬក៏នៅពេលដែលគាត់មិនទាន់ គឺនៅពេលដែលគាត់មិនទាន់គេចាប់នៅឡើយ។ បានន័យថាគឺគាត់ជម្រាបពីការចាប់ ជូ ជាតិ (ស៊ីក) ។

**ឆៈ** ខ្ញុំសួរ ប៉ង់ នៅពេលដែល ប៉ង់ ចុះមកណែនាំខ្ញុំ ដឹកនាំខ្ញុំ។ ខ្ញុំសួរ ប៉ង់ នៅពេលដែល ប៉ង់ ចុះមកដឹកនាំខ្ញុំ ក្នុងឋានៈជាមេខ្ញុំ។

**សៈ** ថាតើលោកអាចពន្យល់ឲ្យបានច្បាស់លាស់ដែរឬទេថា តើនៅពេលនោះ ប៉ង់ និយាយប្រាប់លោកថាម៉េចខ្លះ អំពីសេចក្តីសម្រេចក្នុងការ ចាប់ ជូ ជេត។ ថាតើនៅពេលនោះ មានអ្នកណាដែលមានវត្តមាននៅទីនោះដែរ?

[១៥:២៦:២៤]

**ឆៈ** ខ្ញុំសូមបញ្ជាក់ថា ថ្នាក់លើពីរនាក់ជជែកគ្នា ថ្នាក់ក្រោមគ្នាសិទ្ធិនៅជិតទេ។ សូម្បីតែ មិត្ត ហ៊ី ក៏មិនមែនទៅប៉ាននទៅជិតខ្ញុំ នេះមួយ។ ហើយម៉េចបានៗជាធ្លាក់ដល់រឿង ជូ ជេត? នៅពេលដែលគេសម្រេចចាប់ ជូ ជេត ខ្ញុំគិតថា ជូ ជេត ហើយនិង តាម៉ុក អ៊ុង ជឿន ហៅ ម៉ុក នេះទំនាស់គ្នាខ្លាំងណាស់។ ខ្ញុំឃើញថា វន វេត ជាមនុស្សប្រកាន់អាកប្បកិរិយាកណ្តាល។ តើ វន វេន មានទប់ទេនៅក្នុងអង្គប្រជុំអចិន្ត្រៃយ៍? ដើម្បីសម្រេចចាប់ ជូ ជេត។ ព្រោះព្រះរាជអាជ្ញាឃើញហើយសេចក្តីរាយការណ៍ខ្ញុំលើកមុន ដើម្បីសម្រេចចាប់ សួស នៅ ហៅ ឈូក, បង ខៀវ ប្រាប់ខ្ញុំឲ្យរៀបចំឯកសារប្រាំពីរដុំ។ ខ្ញុំរៀបចំប្រាំពីរដុំជូនគាត់។ មិនមែនគាត់បញ្ជាមកប្រាំពីរដុំទេ គឺខ្ញុំរៀបចំប្រាំពីរដុំជូនគាត់។ ដូច្នេះ ខ្ញុំជឿថានៅពេលសម្រេចចាប់ ជូ ជេត ដែលជាសមាជិកមជ្ឈិមពេញសិទ្ធិ ក៏ត្រូវគេមានប្រជុំអចិន្ត្រៃយ៍មជ្ឈិម។ បានខ្ញុំសួរ ប៉ង់ ខ្ញុំថា ពេលប្រជុំអចិន្ត្រៃយ៍មជ្ឈិម ដើម្បីសម្រេចចាប់ បងស៊ី តើ បងវន មានជួយមតិទប់ទល់ទេបញ្ហានេះ? បាន ប៉ង់ ឆ្លើយថា អត់ទេ។ បងវន នេះលំបាកណាស់ ពេលប្រជុំម្តងៗជូនអង្គុយជូនពេលខ្លះអង្គុយធ្វើមុខក្រម៉ូវៗ និយាយអីក៏មិននិយាយ។ ដូច្នេះដោយឡែក ចំពោះថ្ងៃប្រជុំដើម្បីវិភាគថាតើចាប់ ជូ ជេត ឬមិនចាប់ បងវន គាត់នៅនុំង។ ក៏ប៉ុន្ត បងប៉ុល គឺ ប៉ុល ពត នេះបញ្ជាឲ្យ ប៉ង់ ទៅអញ្ជើញ បងហែម ចូលរួមវិញ គឺ ខៀវ សំផន នេះចូលរួមវិញ។ ហើយសូមបញ្ជាក់ថា ខ្ញុំដឹង ថា ខៀវ

សំផន នេះមិនមែនជាសមាជិកអចិន្ត្រៃយ៍មជ្ឈិមទៅទៀត។ ក៏ម៉េចក៏បញ្ចូលទៅ? តែខ្ញុំមិនទាន់សួរ ប៉ង់ទេ ថាម៉េចក៏បានអញ្ជើញ បងហែម? មិនអញ្ជើញនៃ បងវន? ខ្ញុំអត់ហ៊ានសួរ។ ដូច្នេះ ចម្លើយ ប៉ង់ គឺអីចឹង។ រឿងពិតយ៉ាងម៉េច កំណត់ហេតុប្រជុំអចិន្ត្រៃយ៍មជ្ឈិមវាបញ្ជាក់។

[១៥:២៩:០៥]

**ស៖** ដូច្នេះក្រៅពី ប៉ុល ពត និង បងហែម ដែលជា ខៀវ សំផន នោះ តើមានអ្នកណាផ្សេងទៀតដែរឬទេ? ដែលចូលរួមក្នុងកិច្ចប្រជុំដើម្បីសម្រេចក្នុងការសម្រេចចាប់ ជូ ជេត នោះ?

**ឆ៖** ខ្ញុំមិនបានដេញដោលសួរទេ។ ខ្ញុំមិនបានដេញដោលសួរឫគល់ទេ។ ខ្ញុំគ្រាន់តែដឹងប៉ុណ្ណឹង ខ្ញុំឈប់ទៅ។ គ្រាន់ដឹងថា បងវន គេអត់អញ្ជើញគាត់ទេ គេឲ្យអញ្ជើញ បងហែម ចូលវិញ។

**ស៖** សូមអរគុណ។ នៅ-- ដូច្នេះចុងក្រោយនេះគឺថា ពាក់ព័ន្ធទៅនឹងអ្វីដែលលោកបាននិយាយគឺ យក់ ឈន។ ថាតើៗ ប៉ង់ មានប្រាប់លោកដែរឬទេ អំពីសេចក្ដីសម្រេចក្នុងការចាប់ យក់ ឈង។ ហើយថាតើលោកដឹងព័ត៌មានមកពីណាអំពីសេចក្ដីសម្រេចចាប់ យក់ ឈង?

**ឆ៖** អូ១! យក់ ជួង ប្រធានរោងចក្រអគ្គិសនីចាក់អង្រែ។ យក់ ជង នេះ យក់ ជួង នេះហើយនិងខ្ញុំធ្លាប់ជាប់គុកជាមួយគ្នា ស្គាល់គ្នា។ នៅពេលដែលគេចាប់ យក់ ជង-- យក់ ជួន-- យក់ ជនអ៊្នែមើល៉ ទៅស-២១ គាត់ឆ្លើយដាក់ បងហែម ថាមេក្បត់របស់គាត់គឺ បងហែម។ ខ្ញុំមិនចង់និយាយអំពីសកម្មភាពដែល យក់ ជង-- យក់ ជួង គាត់ឆ្លើយនោះទេ។ ខ្ញុំចង់និយាយថា បងហែម មានអង្គភាពគ្រប់គ្រងហ្នឹងគេ យ៉ាងហោចណាស់ក៏មានអគ្គិសនីចាក់អង្រែមួយដែរ។ នេះជាអង្គភាពមួយដែលខ្ញុំរាយការណ៍ជូនតុលាការថា បងហែម គាត់គ្រប់គ្រងអង្គភាពនេះ បានជាមិត្ត ជន គាត់ឆ្លើយដាក់។

ទន្ទឹមនេះ ខ្ញុំក៏នៅចាំបានថា ថ្ងៃ៦ មករា មិត្តលីន មកហៅខ្ញុំឲ្យទៅធ្វើការ បងឲ្យហៅទៅធ្វើការ។ ដល់ចូលទៅ ឃើញមនុស្សនៅជុំវិញ បងហែម។ ខ្ញុំធ្លាប់ធ្វើការជាមួយ បងនួន ហើយទៅដល់ឃើញបងហែម ខ្ញុំវាមិនទៅ មិត្តលីន រុញស្មាថា មិត្តចូលទៅ។ ខ្ញុំក៏ចូលទៅ ព្រោះខ្ញុំគិតថា មិត្តលីន មិនហ៊ានធ្វើអីផ្ដេសផ្ដាស ដោយគ្មានបញ្ជាពីលើទេ។ ខ្ញុំក៏ចូលទៅ មិត្តរឿង ខាងឃ្លាំងរដ្ឋរុញកៅអីមកឲ្យខ្ញុំអង្គុយ។ បងហែម អត់សួរខ្ញុំមួយម៉ាត់ទេ។ រុញកៅអីមកឲ្យខ្ញុំអង្គុយ ដល់ខ្ញុំអង្គុយហើយបានដល់ បងហែម និយាយតទៅទៀត។ ពេលនេះសភាពការណ៍យួនមិនអីទេ កុំភ័យ កុំភ្ញាក់ផ្អើល នាំគ្នាធ្វើការងារដោយស្ងាត់ស្ងៀមតទៅទៀត។ នេះប្រហែលជាម៉ោងប្រាំបួនព្រឹក ឬក៏ម៉ោងដប់ព្រឹកនៅថ្ងៃ៦ មករា ឆ្នាំ១៩៧៩ នៅពុទ្ធិកវិទ្យាល័យសុរាម្រិត។ ដោយសារឃើញអង្គប្រជុំហ្នឹង វាមានឃ្លាំងរដ្ឋ បានខ្ញុំគិតថាបង

ហែម គ្រប់គ្រងឃ្លាំងរដ្ឋមុំទៀត។

នេះគឺដើម្បីបញ្ជាក់ថា បងហែម មានអង្គភាពគ្រប់គ្រង។ មិនមែនជាមន្ទីរដែលធ្វើការតែនឹងក្រដាសទេ។ ដល់ក្រោយមកទៀត នៅពេលរត់ឃ្លួន ខ្ញុំសួរគេថា អង្គភាពណាហ្នឹង? ពួកណាហ្នឹង?គេថាពួក តាខាង។ ខ្ញុំប្រាប់គេថា ខាងណេះក៏ តាខាង ដែរ។ ដូច្នេះមិនដឹងពួកហ្នឹងពួកណាទេ។

សរុបមក រឿងទាំងអស់នេះជារឿងដែលខ្ញុំដឹង ហើយបានជួប ដែលបានឮ នេះប៉ុណ្ណោះ។

[១៥:៣៣:៥៧]

**ស៖** យើងនឹងចូលទៅដល់ប្រធានបទមួយទៀត។ ខ្ញុំចង់សុំសួរមួយ ឬពីរសំណួរពីរ ឬក៏បីសំណួរអំពីការប្រជុំ។ នៅថ្ងៃទី៦ ខែមករា ឆ្នាំ៧៤ តើពិតជាថ្ងៃ៦ ខែមករា ឆ្នាំ៧៤ ឬក៏នៅក្នុងឆ្នាំផ្សេងទេ មិនមែនក្នុងឆ្នាំនុ៎ងទេ?

**ឆ៖** មិនមែន៧៤ ទេ ៦ មករា ១៩៧៩។ ៦ មករា ១៩៧៩ ប្រហែលជាម៉ោងប្រាំបួន ឬដប់ព្រឹក ទីកន្លែងប្រជុំ គឺនៅពុទ្ធិកវិទ្យាល័យសុរាម្រិត។

**ស៖** តើមាននរណាធ្វើជាប្រធាននៅពេលនោះដែរឬទេ? ហើយមាននរណាជាអ្នកធ្វើអធិបតីពេលប្រជុំដែរឬទេ?

**ឆ៖** មនុស្សដែលនៅក្នុងនុ៎ង សុទ្ធជាមនុស្សថ្មី ខ្ញុំអត់ស្គាល់។ ខ្ញុំស្គាល់តែ បងហែម មួយដែលជាអ្នកឧទ្ទេសនាមសភាពការណ៍។ ហើយក្រៅពីនោះខ្ញុំស្គាល់ មិត្តរឿង ឃ្លាំងរដ្ឋ ដែលរុញកៅអីឲ្យខ្ញុំអង្គុយ ព្រោះខ្ញុំនិងមិត្តរឿង ស្គាល់គ្នាយូរហើយ។ ដូច្នេះប្រធានអ្នកឧទ្ទេសនាមសភាពការណ៍ គឺ បងហែម នេះឯង។

**ស៖** តើហេតុអ្វី--តើលោកដឹងថាឃ្លាំងរដ្ឋនោះ ហើយមានទំនាក់ទំនងយ៉ាងម៉េចទៅនឹង ហែម? លោកដឹងតាមរបៀបណាដែរ?

[១៥:៣៥:៥៣]

**ឆ៖** ឃ្លាំងរដ្ឋនិងខ្ញុំស្គាល់គ្នា។ ក៏ប៉ុន្តែអ្នកណាគ្រប់គ្រងឃ្លាំងរដ្ឋ ខ្ញុំមិនដឹងទេ។ ដោយឃើញព្រឹត្តិការណ៍ថ្ងៃដែលប្រជុំ ថ្ងៃ០៦ នោះ ឃើញឃ្លាំងរដ្ឋនៅក្រោមការប្រជុំ ក្រោមបទឧទ្ទេសនាមរបស់បងហែម ខ្ញុំគ្រាន់តែថាអាច១ បងហែម គ្រប់គ្រងឃ្លាំងរដ្ឋមួយទៀតផងដែរ។

**ស៖** តើលោកអាចបញ្ជាក់ខ្លី១បានដែរឬទេ? តើ បងហែម មានចូលរួមប្រជុំនៅពេលនោះដែរឬទេ ហើយគាត់បានលើកឡើងអំពីអ្វីជាក់លាក់?

**ឆ៖** បងហែម ជាអ្នកឧទ្ទេសនាមសភាពការណ៍ ថាយួនវាចូលមកមែន តែ មិត្តរឿង និង មិត្តសាន រ៉ែទប់ហើយ។ ដូច្នេះយើងទប់ជាប់ នាំគ្នាខំធ្វើការទៅ មិនអីទេ កុំភ្ញាក់ផ្អើល។ នេះឧទ្ទេសនាម ប៉ុណ្ណឹង ខ្លី។

**ស៖** ប្រហែលយើងអាចត្រឡប់ទៅលើបញ្ហាមួយផ្សេងវិញអំពី បងហែម ដែលជាប្រធានគណៈមន្ទីរមជ្ឈិម។ តើគាត់ធ្វើជាប្រធានគណៈមន្ទីរមជ្ឈិមក្នុងពេញមួយអំឡុងពេលនោះតែម្តង ឬក៏តែមួយរយៈកាលតែប៉ុណ្ណោះក្នុងរបបនោះ?

[១៥:៣៧:៥៧]

**ឆ៖** ខ្ញុំឃើញថា ការងារនេះគាត់ទទួលតាំងពីពេលនោះមក តាំងពីដំបូងដែមក។ ហើយខ្ញុំនៅតែជឿថា វាជាតំណតាំងពី៧០។

**ស៖** តើលោកធ្លាប់ឮឈ្មោះបុគ្គល ស៊ូ-- សឿ វ៉ាស៊ី ហៅ ឌឿន ដែរឬទេ?

**ឆ៖** សឿ វ៉ាស៊ី ហៅ ឌឿន នេះ ខ្ញុំធ្លាប់ជួបតាំងពី៦៧ ម្ល៉េះ។ ដល់ក្រោយមកបែកគ្នា ខ្ញុំមកជាប់បាត់មក។ ហើយគាត់ចូលទៅនៅនុំង គេហៅ-- គេថា សឿ វ៉ាស៊ី ហៅ ឌឿន ឡើងទៅជាប្រធានមន្ទីរមជ្ឈិមដែរ។ ហ្នឹងហើយនៅពេលដែលចាប់ សឿ វ៉ាស៊ី ហៅ ឌឿន ឬក៏បញ្ចេញ សឿ វ៉ាស៊ី ហៅ ឌឿន ទៅពាណិជ្ជកម្ម ដែល ដេវីដ ឆេនដ៍ល័រ ថាជាឧបាយកលរបស់ ខៀវ សំផន ដើម្បីខ្លួនឯងបានឡើងទៅជាប្រធានមន្ទីរមជ្ឈិម។

[១៥:៣៨:៤៤]

**ស៖** យើងមិនចាប់អារម្មណ៍ថា ដេវីដ ឆេនដ៍ល័រ គាត់និយាយអ្វីនោះទេ។ យើងខ្ញុំគ្រាន់តែចង់ដឹងអំពីការសង្កេតរបស់លោកនៅក្នុងអំឡុងពេលនោះ តើលោកបានឃើញអ្វីខ្លះ? តាមការសង្កេតផ្ទាល់ខ្លួនរបស់លោក ឌឿន គឺជាប្រធានមន្ទីរមជ្ឈិមក្នុងមួយរយៈកាលនៅក្នុងរបបនោះ តើមែនដែរឬទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែមថា សឿ វ៉ាស៊ី ហៅ ឌឿន នេះចូលទៅធ្វើជាប្រធានមន្ទីរមជ្ឈិមនៅតែកាន់កាប់ខាងក្រដាសទេ។ ថ្ងៃណាខាងលើប្រជុំនិយាយពីរឿងអី ជួយដឹង ជួយចាំ។ នេះជាបញ្ហាមួយ។ បញ្ហាមួយទៀត ដែលខ្ញុំចេះតែនិយាយពីរឿង ដេវីដ ឆេនដ៍ល័រ ព្រោះ ដេវីដ ឆេនដ៍ល័រ គាត់ថា ខៀវ សំផន ចោកទាប។ ខ្ញុំថាអត់ទេ ខៀវ សំផន គេថ្លៃថ្នូរ សឿ វ៉ាស៊ី ហៅ ឌឿន ទេដែលចោកទាប។ នេះដែលខ្ញុំរំឭកយកឈ្មោះ ដេវីដ ឆេនដ៍ល័រ មកនិយាយ។ ដូច្នេះ សឿ វ៉ាស៊ី ហៅ ឌឿន នេះចូលទៅក្នុងមន្ទីរមជ្ឈិមកាន់កាប់ក្រដាសទេ អត់មានអង្គភាពកាន់កាប់ទេ។

[១៥:៤១:១៥]

**ស៖** ជាថ្មីម្តងទៀត ខ្ញុំគ្រាន់តែចង់ឲ្យលោកឆ្លើយ តើលោកសង្កេតឃើញយ៉ាងម៉េចក្នុងស្ថានការណ៍នុំង? ខ្ញុំមិនចង់សួរមតិយោបល់របស់បុគ្គលផ្សេងនោះទេ គ្រាន់តែចង់ដឹងថាអ្វីដែលលោកបានដឹង។ តាមអ្វីដែលលោកលើកឡើង លោកបញ្ជាក់ថា ខៀវ សំផន គឺជាប្រធានគណៈមន្ទីរមជ្ឈិម។ ហើយលោកក៏បាននិយាយផងដែរថា ខឿន ក៏ជាប្រធានគណៈមន្ទីរមជ្ឈិមផងដែរ។ តើគណៈមន្ទីរមជ្ឈិមនោះ មានប្រធានពីរនាក់ក្នុងពេលតែមួយ ឬក៏វាអាចមានប្រធានម្នាក់នៅក្នុងដំណាក់កាលខុសៗគ្នា?

**ឆ៖** អរគុណ។ សួរហ្នឹងត្រឹមត្រូវហើយ។ ខ្ញុំសូមបញ្ជាក់ថា ការងារនយោបាយ ដែលគេហៅថាការងារនយោបាយ គឺការងារក្រដាស។ មជ្ឈិមថ្ងៃណេះនិយាយពីរឿងអី ឲ្យ ខឿន ជួយចាំ ជួយព្ញ។ ដូច្នេះខាងការងារនយោបាយ ខឿន គេកាន់កាប់អាហ្នឹង។ ឯចំណែក ខៀវ សំផន ប្រធានគណៈកម្មាធិការមន្ទីរមជ្ឈិមហ្នឹង វាមានអង្គភាព។ អង្គភាពហ្នឹងយ៉ាងហោចណាស់ក៏មានរោងអគ្គិសនីចាក់អង្រែដែរ ក៏ប៉ុន្តែក្រោយមកបើអត់បានឃើញភស្តុតាងថាមានពាណិជ្ជកម្មមួយទៀត។

**ស៖** តើលោកដឹងទេ មានអ្វីកើតឡើងចំពោះលោក ខៀវ សំផន នៅពេលដែល ខឿន ចាកចេញទៅក្រសួងពាណិជ្ជកម្មនោះ? តើលោកបានដឹងដែរឬទេ?

**ឆ៖** ខ្ញុំដឹង ដូច្នេះ ខៀវ សំផន ដូចអត់មានអីប្រែប្រួលសម្រាប់គាត់ទេ។

[១៥:៤៣:១៨]

**ស៖** តើលោកដឹងចំណុចហ្នឹងដោយរបៀបណាដែរ?

**ឆ៖** ទេ ដូចជាអត់-- បុគ្គលមួយហ្នឹងអត់មានរង្គើទេ ពីតួនាទីរបស់គាត់ក្នុងការដឹកនាំ។

**ស៖** សូមអរគុណ។ ប្រសិនបើយើងមើលឯកសារនេះសាជាថ្មី IS.63 ជាសេចក្តីសម្រេចរបស់មជ្ឈិមពាក់ព័ន្ធទៅនឹងការកម្ទេច។ នៅក្នុងផ្នែកទីមួយ មានសរសេរថា៖ “សិទ្ធិសម្រេចកម្ទេចអាចសម្រេចដោយគណៈមន្ទីរមជ្ឈិម” ដែលលោកថាគណៈមន្ទីរមជ្ឈិមនេះ គឺមាន ខៀវ សំផន ជាប្រធាន ហើយ ខឿន ក៏មានតួនាទីក្នុងមន្ទីរមជ្ឈិមនេះផងដែរ។ ហើយប្រសិនបើលោកមើលខុះក្រោមបន្តិចឃើញមន្ទីរ៨៧០។ លោកអាចជម្រាបតុលាការបានដែរឬទេ តើលោកស្គាល់ និងដឹងមន្ទីរ៨៧០ ដែរឬទេ នៅចំណុចលេខ២ ក្នុងពេលដែលលោកធ្វើការងារជាប្រធានស-២១ នោះ គឺរបបរាយការណ៍ទៅមន្ទីរ៨៧០?

**ឆ៖** ៨៧០ ខ្ញុំស្គាល់ ខ្ញុំធ្លាប់ឮ មិនមែនស្គាល់ ខ្ញុំធ្លាប់ឮ គឺមន្ទីរមជ្ឈិមៗ ឬមន្ទីរ៨៧០។

[១៥:៤៥:១៨]

**ស៖** ជាដំបូង មន្ទីរមជ្ឈិមតើមានធ្លាប់សេចក្តីណែនាំ បង្គាប់ដល់ស-២១ ឬក៏ចេញសេចក្តីណែនាំទៅកន្លែងផ្សេងដែរឬទេ តាមអ្វីដែលលោកដឹង?

**ឆ៖** សេចក្តីណែនាំរបស់៨៧០ ឬក៏មន្ទីរមជ្ឈិមនេះ គឺមិនមែនចេញពី ខៀវ សំផន ទេ ក្នុងករណីណាក៏ដោយ គឺអត់។ គឺចេញពីប៉ុល ពត នួន ជា តាមរយៈ សុន សេន។ បន្ទាប់មក គឺចេញពី ប៉ុល ពត មក នួន ជា មកដល់ខ្ញុំ ឬក៏ជូនអីពី ប៉ុល ពត មកតាមរយៈ ប៉ង់ មកដល់ខ្ញុំ។ មិនដែលមានជាលាយលក្ខណ៍អក្សរទេ គឺជាមាត់ៗ។ គេហៅយើងទៅធ្វើការ យើងកត់ទៅ ថ្ងៃណោះធ្វើជាមួយនឹងបងពីរឿងអីខ្លះ ហ្នឹងយើងកត់។ ដូច្នេះ តែកាលណាគេនិយាយ៨៧០ណែនាំ មិនមែនសំដៅ ខៀវ សំផន ទេ គឺ ប៉ុល ពត។

**លោក វីណ្ឌៀម ស្មីត៖**

ចង់បង្ហាញលោក ឯកសារមួយទៀត ចំណាង-- ឯកសារ D248/3.3។ ខ្ញុំមានឯកសារនេះជាក្រដាសជូន សម្រាប់ជូនសាក្សី។ ហើយខ្ញុំសូមឱ្យមន្ត្រីតុលាការបញ្ចាំងឯកសារនេះ នៅលើអេក្រង់ផង។ សូមអរគុណ។

[១៥:៤៧:១៦]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត សូមអញ្ជើញ!

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ប្រសិនបើលោកមើលឯកសារនេះ មើលចំណងជើងឯកសារ ហើយនៅចុងកថាខណ្ឌនេះ តើលោកបានឃើញដែរឬទេ ឯកសារនេះ លោកធ្លាប់ឃើញដែរឬទេ? ហើយលោកធ្លាប់ស្គាល់ដែរឬទេកាលពីមុន? ហើយខ្ញុំអាចអានចំណងជើងឯកសារនេះ “សេចក្តីណែនាំរបស់គណៈមជ្ឈិបក្សកុម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភ័ន្តច្រឡំចូល សេ.អ៊ី.អា ឬធ្វើភ្នាក់ងារយួន ឬចូល កា.ហ្សេ.បេ ប្រឆាំងបក្ស បដិវត្តន៍ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ”។

**ឆ៖** ឯកសារនេះ ខ្ញុំឃើញ។ គេចែកមកឲ្យខ្ញុំ តែខ្ញុំភ្លេច មិនដឹងជាខាងណាចែក ក៏ប៉ុន្តែគេចែកមកដល់ខ្ញុំ។ មិនត្រឹមតែប៉ុននុ៎ងទេ បើខ្ញុំចាំ ដូចជាមានចុះនៅក្នុងទស្សនាវដ្ដីទង់បដិវត្តទៅទៀត។

**ស៖** ឯកសារនេះ ទំនងជាចេញមកពីគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ តាមអ្វីដែលលោកដឹង តើគណៈមជ្ឈិមមានធ្លាប់ចេញឯកសារមួយចំនួន ដូចជាសេចក្ដីណែនាំ ឬក៏សេចក្ដីសម្រេចដែរឬទេ? តើលោកធ្លាប់ដឹង ហើយមានដែលចេញសេចក្ដីណែនាំមួយនេះ ដូចដែលយើងលើកឡើងដែរឬទេ?

[១៥:៤៩:៣១]

**ឆ៖** អាឯកសារមួយនេះគឺច្បាស់។ ខ្ញុំបានទទួល បានឃើញ។

**ស៖** ប្រហែលជាខ្ញុំឲ្យលោកពិនិត្យមើល ថាតើគោលបំណងនៃឯកសារនេះ គឺអ្វីដែរ? ហើយឯកសារនេះ មានបំណងចង់ឲ្យធ្វើអីដែរ?

**ឆ៖** នៅពេលដែលបានអានឯកសារនេះ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំអរ ពីព្រោះអី ពីព្រោះបក្សមានគោលនយោបាយសណ្ដោសចំពោះអ្នកបានប្រព្រឹត្តខុស។ ដូច្នេះគ្នាវាមានមុខ មានមាត់មកជាប្រជាជនធម្មតា ក៏ប៉ុន្តែពិនិត្យមើលសព្វគ្រប់ទៅទៀតក្នុងន័យអនុវត្ត ខ្ញុំឃើញថា សភាពការណ៍ពេលនោះ បក្សសម្រិតសម្រាំងមនុស្សដល់កម្រិត។ ដូច្នេះ ឯកសារនេះ វាគ្រាន់តែល្បួងលោម កុំឲ្យប្រជាជនភ័យឲ្យមានជំនឿទៅលើបក្សតទៅទៀតតែប៉ុណ្ណឹងឯង។

**ស៖** តើលោកឯកភាពជាមួយខ្ញុំដែរទេដែលថា ខ្លឹមសារនៅក្នុងឯកសារនេះ គឺដើម្បីនិយាយអំពីគោលនយោបាយរបស់បក្ស អ្នកដែលត្រូវបានគេសង្ស័យចាត់ទុកថាជាខ្មាំង នៅក្នុងឆ្នាំ១៩៤៦ ទៅដល់៦៧ ពីឆ្នាំ៦៨ ដល់ឆ្នាំ៧៧-- ៧០ និងឆ្នាំ៧០ ដល់៧៥, ៧៥ ដល់៧៨ អ្នកទាំងអស់ហ្នឹងស្ថិតនៅក្នុងសង្ស័យក្នុងរបបហ្នឹង ទទួលការដាក់ទណ្ឌកម្មធូរស្រាល ហើយអាចត្រូវបានយកមកអប់រំ ដើម្បីឲ្យដើរតាមមនោគមន៍វិជ្ជារបស់បក្សវិញ។ តើនេះជាអ្វីដែលឯកសារហ្នឹងចង់ធ្វើដូច្នេះដែរឬទេ?

[១៥:៥២:០២]

**ឆ៖** ខ្លឹមសារដែលឯកសារនេះ ឃោសនាផ្សព្វផ្សាយគឺអ៊ីចឹង។ ក៏ប៉ុន្តែឥឡូវព្រះរាជអាជ្ញាមើលឯកសារនេះចុះនៅថ្ងៃណា? គឺចុះនៅក្នុងខែមិថុនា-- ថ្ងៃ២០ ខែមិថុនា ឆ្នាំ១៩៧៨ គឺជាខែដែលចាប់ សោ ភឹម បោសសម្អាតបូព៌ារួចហើយ។ ដូច្នេះឯកសារនេះ បើតាមពិត វាគ្រាន់តែល្បួងលោមមនុស្សមិនឲ្យកញ្ជ្រោល ហើយបោះបោលខ្លាំង។

**ស៖** តើលោកយកគោលនយោបាយ នៅក្នុងឯកសារនេះ យកទៅអនុវត្តនៅស-២១ ដែរឬទេ?

**ឆ៖** ខ្លឹមសារក្នុងឯកសារនេះមិនមានអី មិនមានសុពលភាពអនុវត្តនៅក្នុងស-២១ទេ។ បុគ្គលិក ស-២១ មិនទាន់មានអ្នកណាមានឈ្មោះថា ចូល សេ.អ៊ី.អា ពីខែណាឆ្នាំណាទេ។

**ស៖** សូមអរគុណ។ យើងបញ្ចប់ការដេញដោលទៅលើឯកសារនេះហើយ ប្រហែលយើងអាចត្រឡប់មើលសេចក្ដីសម្រេចរបស់គណៈមជ្ឈិម អំពីបញ្ហាផ្សេងៗមួយចំនួន គឺឯកសារ IS3.6។ សូមឲ្យលោកមើលទំព័រ៦ ជាភាសាខ្មែរ ដែលក្នុងនេះលើកឡើងថា សភាតំណាងប្រជាជនកម្ពុជា យ៉ាងហោចណាស់ក្នុងហ្នឹងមានបីនាក់។ ក្នុងហ្នឹងគឺរៀបរាប់មនុស្សចំនួនបីនាក់ គឺគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ដោយក្នុងនោះរៀបរាប់ឈ្មោះមនុស្សបីនាក់ ដែលប្រធានសមមិត្ត នួន អនុប្រធានទី១, សមមិត្ត ភឹម អនុប្រធានទី២, សមមិត្ត ម៉ុក។ តើវាត្រូវគ្នានឹងតាមអ្វីដែលលោកសង្កេតឃើញដែរឬទេ ដែលនៅពេលនោះគេជ្រើសតាំងអ្នកទាំងបីហ្នឹងជាសមាជិកនៃសភាតំណាងប្រជាជនកម្ពុជា?

[១៥:៥៥:០៣]

**ឆ៖** មុននឹងឆ្លើយខ្ញុំចង់អានពីលើមក ដើម្បីឲ្យន័យគ្រប់ជ្រុងជ្រោយ។

"ដំណើរការចាត់តាំងជាក់ស្ដែង: សភា របៀបរបបធ្វើការមានដូចតទៅ៖

តំណាងទាំងអស់ស្ថិតនៅជាមួយប្រជាជនរបស់ខ្លួនតទៅទៀត។ ពីរ គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ប្រធាន សមមិត្ត នួន, អនុប្រធានទីមួយ សមមិត្ត ភឹម, អនុប្រធានទីពីរ សមមិត្ត ម៉ុក។ សមាសភាពផ្សេងទៀតនៃគណៈអចិន្ត្រៃយ៍ ទុកឲ្យអចិន្ត្រៃយ៍បក្សរៀបចំពេលក្រោយទាំងអស់ប្រហែល១០នាក់"។ នេះខ្លឹមសារទាំងស្រុងរបស់វា។

ដូច្នេះរបៀបរបបធ្វើការ តំណាងទាំងអស់ស្ថិតនៅជាមួយប្រជាជនរបស់ខ្លួនតទៅទៀត។ អត់មានអ្នកណាមកប្រជុំទេ។ ដូចខ្ញុំបានរៀបរាប់ព្រឹកមិញជូនសហព្រះរាជអាជ្ញាជូនតុលាការអ៊ីចឹង។ មិត្តគន្ធ ប្រពន្ធ ណាត នៅធ្វើប្រធានរោងចក្រតទៅទៀតទៅ។ មិត្តសោម នៅធ្វើការជំនួយការសេនាធិការតទៅទៀតទៅ។ មិត្តសាយ នៅធ្វើខាងរោងចក្រតទៅទៀតទៅ គណៈកម្មាធិការឧស្សាហកម្មតទៅទៀតទៅ។

[១៥:៥៦:៤២]

ដូច្នេះសមមិត្ត នួន ក៏នៅធ្វើអនុលេខាទីមួយមជ្ឈិមបក្សតទៅទៀតទៅ។ សមមិត្ត ភឹម ក៏នៅធ្វើលេខាភូមិភាគបូព៌ាតទៅទៀតទៅ។ សមមិត្ត ម៉ុក នៅធ្វើលេខានិរតីតទៅទៀតទៅ។

សមាសភាពផ្សេងទៀត អចិន្ត្រៃយ៍ទុកៗ នៃគណៈអចិន្ត្រៃយ៍សភាទុកឲ្យអចិន្ត្រៃយ៍បក្សរៀបចំពេលក្រោយ ទាំងអស់ប្រហែល១០នាក់មែន។ មែន! នៅពេលទៅសម្ភោធសភាហ្នឹងមានប្រហែល ១០នាក់មែន។ ក៏ប៉ុន្តែខ្ញុំឃើញពីរនាក់គត់ មកនៅនឹងពុទ្ធកវិទ្យាល័យព្រះសុរាម្រិត គ្រាន់រៀបចំកន្លែងជូនបង ប៉ុល ធ្វើការជាមួយនឹងកម្មាភិបាលផ្សេងទៀត គឺ ស សៀន ហើយនិង ឆាំ ប៉ុនន៉ុង កិច្ចដំណើរការមានប៉ុនន៉ុង។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរពីរបន្ថែមលើឯកសារនេះ។ សំណួរទីមួយ ពាក់ព័ន្ធទៅនឹងគណៈប្រធានរដ្ឋ។ ក្នុងនេះបានដាក់ឈ្មោះសមមិត្ត ហែម អនុប្រធានទីមួយ, ប៉ែន នុត និងអនុប្រធានទីពីរសមមិត្ត ញឹម។ តើលោកដឹងទេ នរណាដែរជាសមមិត្ត ញឹម?

**ឆ៖** ព្រឹកមិញខ្ញុំបានជម្រាបសហព្រះរាជអាជ្ញាហើយ ថាសមមិត្ត ញឹម នេះ គឺ រស់ ញឹម។ លេខាភូមិភាគពាយ័ព្យ។

[១៥:៥៨:២៨]

**ស៖** ហើយប្រសិនបើយើងមើលទៅលើរដ្ឋាភិបាលនិយាយថា សមមិត្ត ប៉ុល, សមមិត្ត វ៉ាន់, សមមិត្ត វន, សមមិត្ត ខៀវ តើនរណាជាសមមិត្ត វ៉ាន់ ហើយអ្នកណាដែរ ជាសមមិត្ត វន?

**ឆ៖** អរគុណ។ សមមិត្ត វ៉ាន់ គឺ អៀង សារី។ បង វ៉ាន់ ហ្នឹង គឺ អៀង សារី។ សមមិត្ត វន នេះ គឺ វន វ៉េត។ សមមិត្ត ខៀវ នេះ គឺ សុន សេន។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ។ នៅក្នុងជួរទីមួយនិយាយថា រដ្ឋាភិបាលត្រូវជាអង្គការរបស់បក្សសុទ្ធសាធ ជាៗរបស់យើងផ្ទាល់។ ដូច្នេះថា តើរដ្ឋាភិបាលគ្រប់គ្រង រដ្ឋាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាគ្រប់គ្រងទិដ្ឋភាពការងារយ៉ាងម៉េចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១៥:៥៩:៥០]

**ឆ៖** រដ្ឋាភិបាលជារបស់បក្សសុទ្ធសាធ ជារដ្ឋរបស់យើងផ្ទាល់។ ដូច្នេះ រដ្ឋកម្ពុជាដែលមានវណ្ណៈពីរ កម្មករ កសិករនេះ គ្រប់គ្រងដោយរដ្ឋាភិបាលមួយដែលជារដ្ឋាភិបាលរបស់បក្សសុទ្ធសាធ។ មាននាយកម្នាក់គឺ ប៉ុល ពត មានឧបនាយកបីនាក់ គឺ បងវ៉ាន់ អៀង សារី, បងវន វន វ៉េត និងបង ខៀវ សុន សេន។ ដូច្នេះ បីនាក់ហ្នឹង បួននាក់ហ្នឹងរត់ការងាររដ្ឋបាលគ្រប់បែបយ៉ាងទាំងអស់។

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សូមអរគុណលោកសាក្សី។ លោកប្រធាននៅពេលនេះម៉ោងបួន

ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ សម្រាប់កិច្ចដំណើរការថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅព្រឹកថ្ងៃស្អែកចាប់ផ្ដើមពីម៉ោងប្រាំបួន។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក កាំង ហ្កេកអ៊ាវ ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់សវនាការនេះ កន្លែងផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកឲ្យបានត្រឹមម៉ោងប្រាំបួន។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*